ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

# របាយការណ៍

## បូកសរុបលទ្ធផលការងារពាណិជ្ជកម្មឆ្នាំ២០២៤ និងទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២៥



© រក្សាសិទ្ធិដោយក្រសួងពាណិជ្ជកម្ម ឆ្នាំ២០២៤

# មាតិកា


I. **សេចក្តីផ្តើម** ....... **១**

II. **ក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ និងគតិយុត្តវិស័យពាណិជ្ជកម្ម** ....... **៣**

III. **សមិទ្ធផលសម្រេចបានឆ្នាំ២០២៤** ....... **៦**

**១.កិច្ចការពាណិជ្ជកម្មអន្តរជាតិ** ....... **៦**

១.១.ការងារពាណិជ្ជកម្មទ្វេភាគី ....... ៦

១.២.ការងារពាណិជ្ជកម្មអនុតំបន់ និងពហុភាគី ....... ១៤

១.៣.ការងារប្រព័ន្ធពាណិជ្ជកម្មសកល ....... ២៥

១.៤.ការងារគ្រប់គ្រងជំនួយ ....... ២៩

១.៥.ការងារស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក ....... ៣១

១.៦.ការចូលរួមអមដំណើរកិច្ចប្រជុំថ្នាក់ដឹកនាំកម្រិតអន្តរជាតិ ....... ៣៥

**២.កិច្ចការពាណិជ្ជកម្មក្នុងប្រទេស** ....... **៣៧**

២.១.ការងារនីតិកម្ម ....... ៣៧

២.២.ការងារអភិវឌ្ឍន៍វិស័យឯកជន ....... ៤២

២.៣.ការងារផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម ....... ៤៥

២.៤.ការងារគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច (AIMS) ....... ៤៧

២.៥.ការងារការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ ....... ៤៧

២.៦.ការងារអាជីវកម្មស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ (ក្រុមហ៊ុនគ្រីនត្រេដ) ....... ៥៤

**៣.កិច្ចការសេវាពាណិជ្ជកម្ម** ....... **៥៦**

៣.១.ការងារចុះបញ្ជីពាណិជ្ជកម្ម ....... ៥៦

៣.២.ការងារកម្មសិទ្ធិបញ្ញា ....... ៦០

៣.៣.ការងារនាំចេញ-នាំចូល ....... ៦៥

**៤.កិច្ចការជំរុញពាណិជ្ជកម្ម** ....... **៧៨**

៤.១.ការងារកិច្ចការពិព័រណ៍ ....... ៧៨

៤.២.ការងារអភិវឌ្ឍន៍ទីផ្សារ ....... ៨២

៤.៣.ការងារគោលនយោបាយពាណិជ្ជកម្ម ....... ៨៤

**៥.កិច្ចការរដ្ឋបាលទូទៅ** ....... **៨៩**

៥.១.ការងាររដ្ឋបាល ....... ៨៩

៥.២.ការងារបុគ្គលិក ....... ៩០

៥.៣.ការងារគណនេយ្យ និងហិរញ្ញវត្ថុ ....... ៩១

៥.៤.ការងារបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ ....... ៩៣

**៦.អគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង** ....... **៩៤**

៦.១.ការងារអគ្គាធិការដ្ឋាន ........ ៩៤
៦.២.ការងារសវនកម្មផ្ទៃក្នុង ........ ៩៥
**៧.កិច្ចការយេនឌ័រ ........ ៩៦**
៧.១.សហគ្រិនស្ត្រី ........ ៩៦
៧.២.ស្ថិតិមន្ត្រីរាជការជាស្ត្រី ........ ៩៦
៧.៣.ការលើកកម្ពស់យេនឌ័រក្នុងវិស័យពាណិជ្ជកម្ម ........ ៩៧
**៨.កិច្ចការកែទម្រង់ ........ ៩៨**
៨.១.ការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........ ៩៨
៨.២.ការងារកែទម្រង់រដ្ឋបាលសាធារណៈ ........ ៩៩
៨.៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........ ១០០
៨.៤.ការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ........ ១០១
**៩.កិច្ចការមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ........ ១០២**
៩.១.ការគ្រប់គ្រងស្ថានភាពទីផ្សារ និងអង្គភាពអាជីវកម្ម ........ ១០២
៩.២.ការអនុវត្តការងារប្រតិភូកម្ម និងការងារពាក់ព័ន្ធតំបន់សេដ្ឋកិច្ចពិសេស ........ ១០៣
៩.៣.កិច្ចសហការជាមួយសាខា ក.ប.ប. ........ ១០៤
៩.៤.ការអនុវត្តគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច ........ ១០៤
**១០.កិច្ចការគណៈកម្មាធិការជាតិពាក់ព័ន្ធវិស័យពាណិជ្ជកម្ម ........ ១០៥**
១០.១.ការងារគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.» ........ ១០៥
១០.២.គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក» ........ ១០៥
១០.៣.គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា «គ.ត.ផ.ហ.ក» ........ ១០៥
១០.៤.គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា ........ ១០៦
១០.៥.គណៈកម្មការរៀបចំឯកសារត្រួតពិនិត្យការអនុវត្តគោលនយោបាយពាណិជ្ជកម្មក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ........ ១០៧
**១១.សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត ១០៧**
IV. **បញ្ហាប្រឈម និងវិធានការដោះស្រាយ ........ ១០៩**
V. **ទិសដៅការងារអនុវត្តឆ្នាំ២០២៥ ........ ១១០**
១.កិច្ចការពាណិជ្ជកម្មអន្តរជាតិ ........ ១១០
២.កិច្ចការពាណិជ្ជកម្មក្នុងប្រទេស ........ ១១០
៣.កិច្ចការសេវាពាណិជ្ជកម្ម ........ ១១១
៤.កិច្ចការជំរុញពាណិជ្ជកម្ម ........ ១១២
៥.កិច្ចការរដ្ឋបាលទូទៅ ........ ១១៣

៦.កិច្ចការអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង ........ ១១៤
៧.កិច្ចការយេនឌ័រ ........ ១១៤
៨.កិច្ចការងារកែទម្រង់ ........ ១១៤
VI. **សេចក្តីសន្និដ្ឋាន** ........ **១១៧**

# I. សេចក្តីផ្តើម

ក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្រសួងពាណិជ្ជកម្ម បានបុរេសកម្មអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព និងទទួលបានជោគជ័យគួរជាទីកត់សម្គាល់ក្នុងការធ្វើពិពិធកម្មទីផ្សារ តាមរយៈការពង្រឹងទីផ្សារចាស់ និងពង្រីកទីផ្សារថ្មីៗ ព្រមទាំងធ្វើពិពិធកម្មផលិតផល ដើម្បីធានាភាពសម្បូរបែបនិងទាក់ទាញនៃទំនិញផលិតនៅកម្ពុជា (Made in Cambodia) សម្រាប់បម្រើការនាំចេញ និងធ្វើពាណិជ្ជកម្មលើថ្នាលពាណិជ្ជកម្មអេឡិចត្រូនិកធំៗ ដើម្បីច្បាមយកកាលានុវត្តភាពទីផ្សារដោយប្រើយន្តការពាណិជ្ជកម្មឌីជីថល សំដៅរួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គមកម្ពុជា។ ទន្ទឹមនឹងនេះ ក្រសួងពាណិជ្ជកម្មបានដកស្រង់បទពិសោធន៍ពីបញ្ហាប្រឈម ដែលជះឥទ្ធិពលអវិជ្ជមាន ដល់សេដ្ឋកិច្ចសកលបានធ្វើឱ្យប៉ះពាល់ដល់ទីផ្សារនាំចេញរបស់កម្ពុជា និងបានជំរុញអនុវត្តវិធានការដំណោះស្រាយ ដែលផ្តល់ផលវិជ្ជមានភ្លាមៗ ដូចជា៖ (១)-ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងកិច្ចសម្រួលពាណិជ្ជកម្ម (២)-ជំរុញការនាំចេញតាមរយៈការកែលម្អបរិយាកាសអំណោយផលដល់ធុរកិច្ច និង(៣)-សម្របសម្រួលពង្រឹងទីផ្សារក្នុងស្រុកតាមរយៈគំនិតផ្តួចផ្តើមបង្កើតផ្សារលក់ដុំ បង្វិតប្រភពផ្គត់ផ្គង់ឱ្យជិតនឹងទីផ្សារ ព្រមទាំងសម្រួលដល់ផលិតករនិងកសិករខ្នាតតូច ដើម្បីធានាថ្លៃ និងបរិមាណទំនិញផ្គត់ផ្គង់លើទីផ្សារ។

ក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា តាមការផ្តល់អនុសាសន៍សំខាន់ៗក្នុងពិធីបិទសន្និបាតបូកសរុបការងារក្រសួងពាណិជ្ជកម្មឆ្នាំ២០២៣ និងទិសដៅការងារសម្រាប់ឆ្នាំ២០២៤ ដែលជាវិភាគទានបន្ថែមសម្រាប់កំណត់ទិសដៅការងារពាណិជ្ជកម្ម ក្រសួងបានដាក់ចេញនូវវិធានការគន្លឹះទាំង ៧រួមមាន៖ (១)-បន្តពង្រីកការធ្វើឌីជីថលភាវូបនីយកម្មសេវាសាធារណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងបន្តពង្រឹងសមត្ថភាពមន្ត្រីឌីជីថលគ្រប់លំដាប់ថ្នាក់ជាប់ជាប្រចាំ និងការពិនិត្យលទ្ធភាពក្នុងការបង្កើតអង្គភាពបរិវត្តកម្មឌីជីថល តាមអង្គភាពនានាក្រោមឱវាទក្រសួង (២)-ជំរុញ និងពង្រឹងកម្មវិធីបង្កើនជំនាញ ពង្រីកការបណ្តុះបណ្តាលជំនាញ និងកម្មវិធីរៀបចំជំនាញឡើងវិញ (៣)-បន្តពង្រឹងការធ្វើអភិបាលកិច្ច និងអភិវឌ្ឍវិស័យឯកជន តាមរយៈការកសាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងសមាគមពាណិជ្ជកម្ម និងសហគ្រាសឯកជន

ហើយត្រូវបង្កើនការគ្រប់គ្រងការធ្វើពាណិជ្ជកម្មក្នុងស្រុកនិងអន្តរជាតិ តាមរយៈពង្រឹងការអនុវត្ត កែលម្អ និងដាក់ចេញបន្ថែមទៀតនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងក្រមសីលធម៌ទាក់ទងនឹងអភិបាលកិច្ចក្រុមហ៊ុននិងសហគ្រាសឯកជន កិច្ចការប្រកួតប្រជែង ការពារអ្នកប្រើប្រាស់និងច្បាប់ស្តីពីម្ហូបអាហារ ដើម្បីរក្សាសុខភាព សុវត្ថិភាព និងសុខុមាលភាពអ្នកប្រើប្រាស់ (៤)-បន្តសហការពង្រឹងការផលិតនូវផលិតផលក្នុងស្រុក និងរៀបចំយុទ្ធសាស្ត្រជំរុញការប្រើប្រាស់ផលិតផលខ្មែរ (៥)-តាមរយៈយុទ្ធសាស្ត្រពង្រឹងទីផ្សារចាស់ និងពង្រីកទីផ្សារថ្មី ក្រសួងបានបន្តការចរចាបើកទីផ្សារ និងជំរុញការនាំចេញតាមរយៈការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី ពហុភាគី និងតំបន់ (៦)-បានពិនិត្យ និងសិក្សាស្រាវជ្រាវល្អិតល្អន់ពីផលប៉ះពាល់ នៃការចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួច(LDCs) និង(៧)-បានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចឌីជីថល ធុរកិច្ចឌីជីថល និងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយសម្រេចបានលទ្ធផលសំខាន់ៗ និងដាក់ចេញនូវទិសដៅសកម្មភាពការងារពាណិជ្ជកម្មដូចខាងក្រោម។

## II. ក្របខ័ណ្ឌគោលនយោបាយ និងបទដ្ឋានគតិយុត្តវិស័យពាណិជ្ជកម្ម

ក្រសួងពាណិជ្ជកម្មមានច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយមួយចំនួនសម្រាប់គាំទ្រដល់ការបំពេញបេសកកម្ម និងអនុវត្តតួនាទី ភារកិច្ចការងាររបស់ខ្លួន ដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមដូចខាងក្រោម៖

- <u>ច្បាប់៖</u> (១)-ច្បាប់ស្តីពីសភាពាណិជ្ជកម្មកម្ពុជា (២)-ច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្ម (៣)-ច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម (៤)-ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម (៥)-ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញនិងសេវា (៦)-ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (៧)-ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម (៨)-ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម (៩)-ច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម (១០)-ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា(១១)-ច្បាប់ស្តីពីក្បួយធន(១២)-ច្បាប់ស្តីពីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ (១៣)-ច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្ម (១៤)-ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ (១៥)-ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១៦)-ច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ (១៧)-ច្បាប់ស្តីពីការប្រកួតប្រជែង និង(១៨)-ច្បាប់ស្តីពីវិធានដើមកំណើតទំនិញ។
- <u>កិច្ចព្រមព្រៀងពាណិជ្ជកម្ម៖</u> (១)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ និងពិធីសារសម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន (២)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌ សម្រាប់តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (៣)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន (៤)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបង្កើតតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-ណូវ៉ែលហ្សេឡង់ (៥)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា និងកិច្ចព្រមព្រៀងស្តីពី

ពាណិជ្ជកម្មទំនិញក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា និងកិច្ចព្រមព្រៀង ស្តីពីយន្តការដោះស្រាយជម្លោះនៅក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយ រវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា (៦)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន (៧)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន (៨)-ច្បាប់ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន (៩)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP) (១០)-ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ និង(១១)-ច្បាប់ស្តីពីការអនុម័តយល់ព្រម លើកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួម។

- <u>គោលនយោបាយ និងយុទ្ធសាស្ត្រ៖</u> (១)-គោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥ (២)-គោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ (៣)-គោលនយោបាយជាតិស្តីពីកម្មសិទ្ធិបញ្ញាឆ្នាំ២០២៣-២០២៨ (៤)-យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា២០១៩-២០២៣ និង (៥)-យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។
- <u>អនុក្រឹត្យ៖</u> (១)-អនុក្រឹត្យលេខ៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការអនុវត្តច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់ (២)-អនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម (៣)-អនុក្រឹត្យលេខ១៣៤អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ ស្តីពីការកំណត់ប្រភេទបែបបទនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណ

ដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង (៤)-អនុក្រឹត្យលេខ២៣២ អនក្រ.បក ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការគ្រប់គ្រងការផ្សាយពាណិជ្ជកម្មលើផលិតផលទំនិញ និងសេវា (៥)-អនុក្រឹត្យលេខ១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការអង្កេតនិងការដកហូតម្ហូបអាហារ និង(៦)-អនុក្រឹតលេខ៦០ អនក្រ.បក ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៣ ស្តីពីលក្ខខណ្ឌ និងនីតិវិធីអំពីការរួមបញ្ចូលគ្នានៃធុរកិច្ច។

## III. សមិទ្ធផលសម្រេចបានឆ្នាំ២០២៤

## ១.កិច្ចការពាណិជ្ជកម្មអន្តរជាតិ

### ១.១.ការងារពាណិជ្ជកម្មទ្វេភាគី

### ១.១.១.តំបន់អាស៊ីប៉ាស៊ីហ្វិក

❖ អូស្ត្រាលី

- ក្រុមហ៊ុន សហគ្រាសអូស្ត្រាលី ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា មានចំនួន ១៩
- ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ៥៤៦,៥៧លានដុល្លារអាម៉េរិក កើនឡើង ២០,៩៥% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ៤៤៤លានដុល្លារអាម៉េរិក កើនឡើង ៣៦,៦៦%។

❖ ព្រុយណេដារូស្សាឡាម

- រៀបចំផ្តល់ធាតុចូល និងរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ព្រុយណេ ដើម្បីរៀបចំសេចក្តីព្រាងកំណត់ហេតុស្តីពីកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី១ នៅខេត្តសៀមរាប។

❖ សាធារណរដ្ឋប្រជាមានិតចិន

- ក្រុមហ៊ុន សហគ្រាសចិន ដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជាមានចំនួន ២ ៩២១ កើនឡើង ២០,៦៥%
- ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ១៣ ៧៦២លានដុល្លារអាម៉េរិក កើនឡើង ២៤,២៣% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ១ ៦០៧លានដុល្លារអាម៉េរិក កើនឡើង ២២,២៧%
- ជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយ គណៈប្រតិភូមកពីរដ្ឋបាលខេត្ត និងប្រតិភូមកពីវិស័យឯកជន នៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពិនិត្យលទ្ធភាព ក្នុងការទាក់ទាញធុរជនពីតំបន់នោះមកធ្វើធុរកិច្ចនៅកម្ពុជា និងផ្សព្វផ្សាយផលិតផលសក្តានុពលរបស់កម្ពុជា សម្រាប់អតិថិជនក្នុងតំបន់ និងជម្រាបជូនពីគោលនយោបាយ ឱកាសពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា សំដៅបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែប្រសើរឡើង។

❖ សាធារណរដ្ឋឥណ្ឌា

- កិច្ចប្រជុំលើកទី២ នៃក្រុមការងារចម្រុះស្តីពីពាណិជ្ជកម្ម និងវិនិយោគ

(2nd JWGTI) រវាងកម្ពុជានិងឥណ្ឌា។ ភាគីទាំងពីរបានផ្លាស់ប្តូរយោបល់ពីដំណោះស្រាយបញ្ហាប្រឈមដែលបានលើកឡើង ជាពិសេសកិច្ចសហប្រតិបត្តិការលើវិស័យឱសថ និងសន្ធិសញ្ញាវិនិយោគទ្វេភាគី។ កិច្ចប្រជុំបានឯកភាពឱ្យបន្តពិភាក្សាលើការរៀបចំអនុស្សរណៈ នៃការយោគយល់គ្នាលើវិស័យអភិបាលកិច្ចអេឡិចត្រូនិក និងវិស័យគយ។

❖ **សាធារណរដ្ឋឥណ្ឌូណេស៊ី**

- កិច្ចប្រជុំគណៈកម្មការចម្រុះសម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគី រវាងកម្ពុជា-ឥណ្ឌូណេស៊ីលើកទី៥ ដោយភាគីទាំងពីរបានឯកភាពធ្វើបច្ចុប្បន្នភាពលើអនុស្សរណៈនៃការយោគយល់គ្នាស្តីពីពាណិជ្ជកម្មអង្ករ។ ជាក់ស្តែងកម្ពុជាបាននាំចេញអង្ករទៅឥណ្ឌូណេស៊ីបានចំនួន ២២ ៥០០តោន។

❖ **ជប៉ុន**

- ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ១ ៩៥០លានដុល្លារអាម៉េរិក កើនឡើង ១៨,៩៤% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ១ ២៧២លានដុល្លារអាម៉េរិក កើនឡើង ១៩,៣៨%
- ក្រុមហ៊ុន សហគ្រាសជប៉ុនដែលបានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា មានចំនួន ៨៨ កើនឡើង ២០,៥៥%
- ចូលរួមប្រជុំពិភាក្សាលើការងារពាណិជ្ជកម្មកម្ពុជា-ជប៉ុន ក្រោមប្រធានបទ "ធុរកិច្ចឥណទានកាបូន និងបរិយាកាសវិនិយោគនៅកម្ពុជា"។

❖ **សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ**

- ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ២៣៦លានដុល្លារអាម៉េរិក កើនឡើង ៣០,៧០% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ១៦លានដុល្លារអាម៉េរិក កើនឡើង ៣១២,៨១%
- ផលិតផលសំខាន់កម្ពុជានាំចេញរួមមាន៖ បន្ទះសូឡា ថ្នាំសម្លាប់សត្វល្អិត និងស្មៅ សម្ភារសំណង់ និងជ្រូករស់។

❖ **ម៉ាឡេស៊ី**

- រៀបចំបញ្ចប់អនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពីគណៈកម្មាធិការពាណិជ្ជកម្មចម្រុះកម្ពុជា-ម៉ាឡេស៊ីដើម្បីបង្កើតយន្តការពិភាក្សាការងារពាណិជ្ជកម្ម និងលើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី កម្ពុជា-ម៉ាឡេស៊ី។

- **សាធារណរដ្ឋហ្វីលីពីន**
  - ជំនួបសម្ដែងការគួរសមនិងពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋហ្វីលីពីន ដោយភាគីទាំងពីរបានឯកភាពលើការធ្វើពាណិជ្ជកម្មអង្ករវាងហ្វីលីពីននិងកម្ពុជា។ ជាលទ្ធផលជាក់ស្ដែងបាននាំចេញអង្ករទៅហ្វីលីពីនបានចំនួន ២ ៦៥០តោន។
- **សាធារណរដ្ឋសិង្ហបុរី**
  - ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ១ ១៥១លានដុល្លារអាម៉េរិក ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ២៦១លានដុល្លារអាម៉េរិក
  - ភាគីទាំងពីរបានឯកភាពបញ្ចប់ការចរចាសេចក្ដីព្រាងអនុស្សរណៈ នៃការយោគយល់គ្នាស្ដីពីពាណិជ្ជកម្មអង្ករវាងភាគីទាំងពីរ (G2G)។ ជាក់ស្ដែងបាននាំចេញអង្ករទៅសិង្ហបុរីបានចំនួន ១០ ៥៤០តោន។
- **សាធារណរដ្ឋកូរ៉េ**
  - ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ៧៦២លានដុល្លារអាម៉េរិក កើនឡើង ១១,៤៩% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ២៨៨លានដុល្លារអាម៉េរិក កើនឡើង ១៣,៧៧%
  - កិច្ចប្រជុំលើកទី១ នៃគណៈកម្មាធិការចម្រុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ នៅសាធារណរដ្ឋកូរ៉េ ជាលទ្ធផលសម្រេចបាន៖
    - អនុម័តលើវិធាន នៃនីតិវិធីសម្រាប់គណៈកម្មាធិការចម្រុះ
    - ពិនិត្យ និងផ្ដល់អនុសាសន៍លើលទ្ធផល នៃកិច្ចពិភាក្សារបស់គណៈកម្មការក្រោមចំណុះចំនួន៣ រួមមាន៖ (១)-គណៈកម្មការពាណិជ្ជកម្មទំនិញ (២)-គណៈកម្មការវិធានដើមកំណើតទំនិញ និងនីតិវិធីគយ និង(៣)-គណៈកម្មការសហប្រតិបត្តិការសេដ្ឋកិច្ច
    - លើកទឹកចិត្តឱ្យគណៈកម្មាធិការរៀបចំកិច្ចប្រជុំជាទៀងទាត់ និងប្រឹងប្រែងផ្សព្វផ្សាយពី កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ ដើម្បីទាញយកប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងនេះ
    - ឯកភាពបន្តការពិភាក្សា ដើម្បីផ្ដួចផ្ដើមការចរចាលើផ្នែកពាណិជ្ជកម្មសេវាកម្ម និងវិនិយោគ និងគ្រោងរៀបចំកិច្ចប្រជុំគណៈកម្មាធិការចម្រុះលើកទី២ នៅកម្ពុជាក្នុងឆ្នាំ២០២៥
  - ជួបពិភាក្សាជាមួយប្រធាន និងនាយកប្រតិបត្តិទីភ្នាក់ងារជំរុញពាណិជ្ជកម្ម

និងវិនិយោគកូរ៉េ និងឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីជំរុញពាណិជ្ជកម្មរវាងកម្ពុជានិងកូរ៉េ លើវិស័យបច្ចេកវិទ្យាឌីជីថល គ្រឿងបង្គុំអេឡិចត្រូនិក យានយន្ត ការកែច្នៃកសិផល និងម្ហូបអាហារ។

❖ **សាធារណរដ្ឋសង្គមនិយមវៀតណាម**

- កិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាស្រាវជ្រាវ និងរៀបចំកិច្ចព្រមព្រៀងគ្រប់គ្រងច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាមនិងដំឡើងកម្រិតច្រកទ្វារព្រំដែនកម្ពុជា-វៀតណាម
- ជួបពិភាក្សាការងារជាមួយឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចពាណិជ្ជកម្មប្រទេសទាំងពីរ។

❖ **ព្រះរាជាណាចក្រថៃ**

- ក្រុមហ៊ុន សហគ្រាសថៃ ចំនួន ៧៤ បានចុះបញ្ជីពាណិជ្ជកម្មនៅកម្ពុជា
- ទំហំពាណិជ្ជកម្មទ្វេភាគីសម្រេចបាន ៣ ៩១២លានដុល្លារអាម៉េរិក កើនឡើង ១៣,៧២% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ៧៨០លានដុល្លារអាម៉េរិក។

## ១.១.២.តំបន់អឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិក

❖ **សហភាពអឺរ៉ុប**

- ទំហំពាណិជ្ជកម្មសម្រេចបាន៤ ៨៨៦លានដុល្លារអាម៉េរិកកើនឡើង១៥,១០% ក្នុងនោះការនាំចេញរបស់កម្ពុជាសម្រេចបាន ៤ ០៣២លានដុល្លារអាម៉េរិក កើនឡើង២០,៤៥%។
- ចូលរួមកិច្ចប្រជុំអនុក្រុមពាណិជ្ជកម្ម និងវិនិយោគលើកទី១២ (Subgroup on Trade and Investment – SGTI) ក្រោមកិច្ចប្រជុំគណៈកម្មាធិការចម្រុះកម្ពុជា-សហភាពអឺរ៉ុបលើកទី១២ (JC១២) និងកិច្ចប្រជុំពាក់ព័ន្ធ។ ជាលទ្ធផលភាគីទាំងពីរ បានពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យសេដ្ឋកិច្ចពាណិជ្ជកម្ម វិនិយោគ ជំនួយបច្ចេកទេសសម្រាប់វិស័យពាណិជ្ជកម្ម និងវិស័យដទៃទៀត
- ជួបពិភាក្សាការងារជាមួយសមាជិកសភាអឺរ៉ុប និងធុរជនអឺរ៉ុប ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា-សហភាពអឺរ៉ុប

ដែលក្នុងនោះប្រតិភូធុរជនមកពីប្រទេសប៉ូឡូញបានចូលរួមពិគ្រោះយោបល់ក្នុងការពង្រីកចំណែកទីផ្សារបន្ថែមទៀត សម្រាប់ធ្វើពិពិធកម្មទំនិញកម្ពុជាទៅកាន់ប្រទេសប៉ូឡូញ។

❖ **គណៈកម្មការសហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី**

- កិច្ចប្រជុំគណៈកម្មការសេដ្ឋកិច្ចចម្រុះកម្ពុជា-សហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី បានចំនួន ៣លើក និងត្រៀមរៀបចំកិច្ចប្រជុំលើកទី៤ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងកម្ពុជាជាមួយបណ្តាប្រទេសទាំង៥ នៃសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី។

❖ **អង្គការហ្វ្រង់កូហ្វូនី**

- ជួបពិភាក្សាការងារជាមួយប្រធានសម្ព័ន្ធនិយោជកហ្វ្រង់កូហ្វូន (APF) អំពីវឌ្ឍនភាព និងកាលានុវត្តភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីលើវិស័យពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា និងសមាជិកប្រទេសនិយាយភាសាបារាំង ព្រមទាំងផ្លាស់ប្តូរមតិយោបល់លើការត្រៀមរៀបចំកិច្ចប្រជុំសហគ្រិនហ្វ្រង់កូហ្វូនលើកទី៦ ដែលជាព្រឹត្តិការណ៍អមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ឆ្នាំ២០២៦ ដោយកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

❖ **អាស៊ែបៃហ្សង់**

- បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងកម្ពុជា-អាស៊ែបៃហ្សង់។

❖ **បេឡារុស**

- កិច្ចប្រជុំលើកទី៤ នៃគណៈកម្មាធិការចម្រុះ ស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចកម្ពុជា-បេឡារុស ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការរវាងទាំងប្រទេសពីរ។

❖ **ចក្រភពអង់គ្លេស**

- ទំហំពាណិជ្ជកម្មជាមួយចក្រភពអង់គ្លេសសម្រេចបាន ៩៣២លានដុល្លារអាម៉េរិក កើនឡើង ១៦,៤៣%
- រៀបចំវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមកម្ពុជា-អង់គ្លេស (Joint Trade and Investment Forum) លើកទី២ ដើម្បីពង្រីកទំហំពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ
- ពិភាក្សាជាមួយភាគីពាក់ព័ន្ធ ដើម្បីពិនិត្យលទ្ធផលវេទិកាពាណិជ្ជកម្ម និងវិនិយោគរួមកម្ពុជា-អង់គ្លេសលើកទី១ និងវិធានការរាជរដ្ឋាភិបាលកម្ពុជា

សម្រាប់ជាការឆ្លើយតបនឹងបញ្ហាប្រឈមរបស់វិស័យឯកជនអង់គ្លេស

- ពិភាក្សាជាមួយតំណាងស្ថានទូតចក្រភពអង់គ្លេស និងសភាពាណិជ្ជកម្មចក្រភពអង់គ្លេស ព្រមទាំងក្រុមហ៊ុនអង់គ្លេសចំនួន៧ ក្នុងវិស័យហិរញ្ញវត្ថុ ធានារ៉ាប់រង មូលប័ត្រ ពន្ធដារ និងអចលនទ្រព្យ ដើម្បីផ្សព្វផ្សាយអំពីកាលានុវត្តភាពវិនិយោគនៅកម្ពុជា។

❖ **សាធារណរដ្ឋបារាំង**

- ជួបពិភាក្សាការងារជាមួយ ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំកម្ពុជា ដែលបានពិភាក្សាអំពីវឌ្ឍនភាព និងកាលានុវត្តភាពនៃកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម និងវិនិយោគរវាងភាគីទាំងពីរ ព្រមទាំងពិភាក្សាលើលទ្ធភាពបង្កើតផ្សារបោះដុំទំនិញនៅកម្ពុជា។

❖ **សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់**

- ជួបពិភាក្សាជាមួយសមាជិកសភា និងធុរកិច្ចអាល្លឺម៉ង់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មទ្វេភាគីក្នុងវិស័យកម្មន្តសាល ទេសចរណ៍ ឧស្សាហកម្ម ការគ្រប់គ្រងទឹក បច្ចេកវិទ្យា សុខាភិបាល និងកសិកម្ម ដើម្បីស្វែងយល់ពីកាលានុវត្តភាពវិនិយោគ និងធុរកិច្ចនៅកម្ពុជា។

❖ **ហុងគ្រី**

- កិច្ចប្រជុំលើកទី២ នៃគណៈកម្មការចម្រុះស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា-ហុងគ្រី នៅទីក្រុងប៊ុយដាប៉េស ប្រទេសហុងគ្រី ជាលទ្ធផលភាគីទាំងពីរបានចុះហត្ថលេខាឯកភាពលើកំណត់ហេតុរួមនៃកិច្ចប្រជុំ ដោយផ្តោតលើកិច្ចសហប្រតិបត្តិការវិស័យជាអាទិភាពចំនួន៩ រួមមានៈ (១)-វិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ច (២)-កិច្ចសហប្រតិបត្តិការលើគម្រោងឥណទាន (៣)-កិច្ចសហប្រតិបត្តិការលើវិស័យគ្រប់គ្រងធនធានទឹក និងបរិស្ថាន (៤)-កិច្ចសហប្រតិបត្តិការលើវិស័យកសិកម្ម (៥)-កិច្ចសហប្រតិបត្តិការលើការអភិវឌ្ឍអន្តរជាតិ (៦)-កិច្ចសហប្រតិបត្តិការលើវិស័យមូលនិធិហិរញ្ញវត្ថុដែលគ្រប់គ្រងដោយគណៈកម្មការអឺរ៉ុប (៧)-វិស័យអប់រំ យុវជន និងកីឡា (៨)-វិស័យវប្បធម៌ និង(៩)-វិស័យអាកាសចរស៊ីវិល។

❖ **កាហ្សាក់ស្ថាន**

- បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីកិច្ចសហ

ប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មកម្ពុជា-កាហ្សាក់ស្ថាន និងបានផ្ញើជូនភាគីកាហ្សាក់ស្ថានតាមផ្លូវការទូត ដើម្បីបន្តនីតិវិធី។

❖ **ម៉ូរីស**

- បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នារវាងកម្ពុជា-ម៉ូរីស ស្តីពីសហករណ៍ ពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា-ម៉ូរីស ទៅភាគីម៉ូរីសតាមផ្លូវការទូត។

❖ **នីហ្សេរីយ៉ា**

- បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នារវាងកម្ពុជា-នីហ្សេរីយ៉ាស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងសេដ្ឋកិច្ចរវាងកម្ពុជា-នីហ្សេរីយ៉ា។

❖ **កាតា**

- បានបញ្ចប់កិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងបច្ចេកទេសរវាងកម្ពុជា-កាតា។

❖ **សហព័ន្ធរុស្ស៊ី**

- បន្តនីតិវិធី ដើម្បីឈានទៅរកការចុះហត្ថលេខាលើពិធីសាររវាងសេវាគយសហព័ន្ធរុស្ស៊ី និងកម្ពុជា លើកិច្ចសហប្រតិបត្តិការផ្នែករដ្ឋបាល ការផ្លាស់ប្តូរព័ត៌មាន និងការជួយគ្នាទៅវិញទៅមក ដែលបានស្នើឡើងដោយភាគីរុស្ស៊ី ដើម្បីជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ក្រោមប្រព័ន្ធអនុគ្រោះពន្ធរបស់សហភាពសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី។

❖ **អារ៉ាប៊ីសាអូឌីត**

- បានបញ្ចប់សេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីការជំរុញទំនាក់ទំនងពាណិជ្ជកម្មរវាងកម្ពុជា-អារ៉ាប៊ីសាអូឌីត។

❖ **តួកគី**

- បានធ្វើទស្សនកិច្ចសិក្សា ស្តីពីគោលនយោបាយ និងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មរបស់តួកគី នៅប្រទេសតួកគី ព្រមទាំងបានបញ្ជូនសេចក្តីព្រាងតបរបស់ភាគីកម្ពុជានៃលក្ខខណ្ឌយោង (ToR) ស្តីពីការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្ពុជា-តួកគី ទៅភាគីតួកគី។

❖ **អេមីរ៉ាតអារ៉ាប់រួម**

- កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងរាជរដ្ឋាភិបាលនៃ

ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃអេមីរ៉ាតអារ៉ាប់រួមត្រូវបានចូលជាធរមាននៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤

- ចូលរួមវេទិកាធុរកិច្ច និងវិនិយោគកម្ពុជា-អេមីរ៉ាតអារ៉ាប់រួមលើកទី៣ នៅអេមីរ៉ាតអារ៉ាប់រួម និងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីអត្ថប្រយោជន៍កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា-អេមីរ៉ាតអារ៉ាប់រួម ដោយមានការចូលរួមពីធុរជន វិនិយោគិន ក្រុមហ៊ុននាំចេញ និងភាគីពាក់ព័ន្ធ នៅរាជធានីភ្នំពេញ
- ចូលរួមវេទិកា «World FZO 10th World Congress 2024» នៅអេមីរ៉ាតអារ៉ាប់រួម ដើម្បីទទួលបទពិសោធន៍ពាក់ព័ន្ធនឹងការរៀបចំតំបន់សេដ្ឋកិច្ចពិសេស សំដៅទាក់ទាញការវិនិយោគ លើផ្នែកភស្តុភារកម្ម កម្មន្តសាលថាមពល ឌីជីថល និងការទទួលបានហិរញ្ញវត្ថុ (Access to Finance)។

### ១.១.៣.តំបន់អាម៉េរិក

❖ **សហរដ្ឋអាម៉េរិក**

- កិច្ចប្រជុំបច្ចេកទេសចំនួន២លើកជាមួយឧបការីតំណាងពាណិជ្ជកម្មអាម៉េរិក (Assistant USTR) និងនាយិកានៃការិយាល័យតំណាងពាណិជ្ជកម្មអាម៉េរិក (Director of USTR) ប្រចាំតំបន់អាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក ពាក់ព័ន្ធនឹងការងារក្របខ័ណ្ឌវិនិយោគ និងពាណិជ្ជកម្ម (TIFA) រវាងកម្ពុជា និងសហរដ្ឋអាម៉េរិក ដើម្បីរក្សាទំនាក់ទំនងទីផ្សារល្អ និងជំរុញទាក់ទាញវិនិយោគិន និងធុរជនអាម៉េរិកមកធ្វើអាជីវកម្មនៅកម្ពុជា
- បន្តពិភាក្សា ពិគ្រោះយោបល់ និងតាមដាន ដើម្បីបន្តទទួលបានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មសហរដ្ឋអាម៉េរិកដែលផុតសុពលភាព ដោយធ្វើការរួមគ្នាជាមួយនឹងសម្ព័ន្ធក្រុមប្រទេសដែលទទួលបានប្រព័ន្ធ GSP អាម៉េរិក (GSP Alliance) សំដៅរក្សាលទ្ធភាពនៃការនាំចេញផលិតផលកម្ពុជាដែលបានទទួលការអនុគ្រោះរួចហើយ និងផលិតផលថ្មីៗទៀតចូលទៅទីផ្សារសហរដ្ឋអាម៉េរិក
- រៀបចំរបាយការណ៍សិក្សា ស្តីពីស្ថានភាពនៃការនាំចេញផលិតផលសម្លៀកបំពាក់ទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក ដើម្បីផ្ញើជូនគណៈកម្មការពាណិជ្ជកម្មអន្តរជាតិសហរដ្ឋអាម៉េរិក (USITC)

- សម្របសម្រួលរៀបចំឯកសារពាក់ព័ន្ធ និងទិន្នន័យសេដ្ឋកិច្ច-ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-អាម៉េរិក និងផលិតផលសក្តានុពលនាំចេញពីកម្ពុជាទៅកាន់ទីផ្សារសហរដ្ឋអាម៉េរិក សម្រាប់ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

❖ **កាណាដា**

- ពិភាក្សាការងារជាមួយភាគីកាណាដា ទាក់ទងទៅនឹងការចរចាពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា និងជំរុញកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគទ្វេភាគីកម្ពុជា-កាណាដា លើវិស័យអាទិភាពរួមមាន៖ ទេសចរណ៍ អប់រំ កសិ្មការកម្ម និងវិនិយោគបៃតង លើផ្នែកថាមពលព្រះអាទិត្យ និងខ្យល់ ពិភាក្សាការងារជាមួយក្រុមប្រឹក្សាធុរកិច្ចអាស៊ាន-កាណាដា Canada-ASEAN Business Council ( CABC ) ទាក់ទងទៅនឹងការជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច-ពាណិជ្ជកម្មរវាងអាស៊ាន-កាណាដា
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី ការជំរុញផលិតផលសក្តានុពលកម្ពុជាទៅកាន់ទីផ្សារកាណាដា ជូនដល់ធុរជន និងវិនិយោគិនក្នុង និងក្រៅតំបន់សេដ្ឋកិច្ចពិសេស។

❖ **អាម៉េរិកខាងត្បូង**

- រៀបចំវេទិកាជំរុញពាណិជ្ជកម្ម និងវិនិយោគរវាងកម្ពុជា-ប្រេស៊ីល ក្នុងនោះពាណិជ្ជករ និងវិនិយោគិនទាំងពីរប្រទេសបានស្វែងយល់ពីទំនិញសក្តានុពលសម្រាប់ធ្វើពាណិជ្ជកម្មនិងវិនិយោគទៅវិញទៅមក និងបានទទួលចំណេះដឹងទាក់ទងគោលនយោបាយគាំពារវិនិយោគ ឱកាសធ្វើធុរកិច្ច និងលក្ខខណ្ឌគាំពារ ដែលជានាដោយបទប្បញ្ញត្តិ និងច្បាប់របស់កម្ពុជា។

## ១.២.ការងារពាណិជ្ជកម្មអនុតំបន់ និងពហុភាគី

### ១.២.១.កិច្ចការអាស៊ាន

ក្នុងឆ្នាំ២០២៤ មន្ត្រីបច្ចេកទេស និងមន្ត្រីជាន់ខ្ពស់បានចូលរួមជាប្រចាំនៅក្នុងកិច្ចប្រជុំអាស៊ាន និងកិច្ចប្រជុំពាក់ព័ន្ធជាមួយនឹងមន្ត្រីនៃក្រសួង ស្ថាប័នដទៃទៀត ដើម្បីរៀបចំកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៦ និងកិច្ចប្រជុំពាក់ព័ន្ធ ព្រមទាំងកិច្ចប្រជុំកំពូលលើកទី៤៤ និង៤៥ នៅទីក្រុងវៀងច័ន្ទន៍ ប្រទេសឡាវ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖




- កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន លើកទី១ លើកទី២ និងលើកទី៣ (SEOM 1/55, 2/55, 3/55) ជាលទ្ធផលអនុម័តលើរបាយការណ៍របស់ឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន សម្រាប់រាយការណ៍ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៦ ដែលរបាយការណ៍នោះរួមបញ្ចូល៖
  - វឌ្ឍនភាពសមិទ្ធផលអាទិភាពសេដ្ឋកិច្ច (Priority Economic Deliverables) ក្រោមភាពជាប្រធានប្តូរវេនអាស៊ានរបស់ឡាវ
  - វឌ្ឍនភាពការងារអាទិភាព (Priority Works) ប្រចាំឆ្នាំ២០២៤
  - វឌ្ឍនភាពការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងអាស៊ានស្តីពីពាណិជ្ជកម្មទំនិញ (ATIGA)
  - វឌ្ឍនភាពការចរចាកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលអាស៊ាន (DEFA)
  - វឌ្ឍនភាពការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា (ACAFTA)
  - វឌ្ឍនភាពការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ (ACFTA 3.0)
  - វឌ្ឍនភាពការពិនិត្យឡើងវិញកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា (AITIGA)
  - លទ្ធផលនៃកិច្ចពិភាក្សា លើការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ (AKFTA)។

- **កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម (CLMV)៖** បានពិនិត្យ និងពិភាក្សាលើវឌ្ឍនភាព នៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២៣-២០២៤ ក្រោមក្របខ័ណ្ឌសម្រាប់ការអភិវឌ្ឍនៃប្រទេស CLMV និងបានអនុម័តលក្ខខណ្ឌយោងនៃឧត្តមមន្ត្រីសេដ្ឋកិច្ចប្រទេស CLMV ហើយបានបញ្ជូនទៅឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ានដើម្បីផ្តល់ការឯកភាព។
- **កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ សម្រាប់ចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ២០២៥ (HLTF-ACV)៖** ពិភាក្សាលើវឌ្ឍនភាពនៃការរៀបចំចក្ខុវិស័យអាស៊ានក្រោយឆ្នាំ២០២៥ ដោយមានធាតុចូលពីសសរស្តម្ភទាំងបីរបស់អាស៊ាន។
- **កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពីសមាហរកម្មសេដ្ឋកិច្ចអាស៊ាន (HLTF-EI) សម្រេចបាន៖**
  - រៀបចំរបាយការណ៍អនុសាសន៍ដល់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ស្តីពីការសិក្សាលើបញ្ហាប្រឈម និងនិន្នាការថ្មីៗក្រោមការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូក
  - វឌ្ឍនភាពនៃឧត្តមានុវត្តបទប្បញ្ញត្តិច្បាប់
  - របាយការណ៍ពិនិត្យឡើងវិញចុងអាណត្តិ លើផែនការលម្អិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥
  - វឌ្ឍនភាពការអនុវត្តរបៀបវារៈចីរភាពអាស៊ាន និងរបៀបវារៈឌីជីថលអាស៊ាន
  - វឌ្ឍនភាពការរៀបចំចក្ខុវិស័យអាស៊ានក្រោយឆ្នាំ២០២៥ ជាពិសេសការរៀបចំផែនការយុទ្ធសាស្ត្រ សហគមន៍សេដ្ឋកិច្ចអាស៊ាន ២០២៦-២០៣០ សម្រាប់សសរស្តម្ភសហគមន៍សេដ្ឋកិច្ចអាស៊ាន។
- **កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ស្តីពី សមាហរណកម្មសេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០២៥ (WG AEC Post ២០២៥)៖** ផ្លាស់ប្តូរយោបល់អំពីសកម្មភាពអាទិភាពដែលអាចសម្រេចបានរហ័ស (Quick Wins) អាទិភាពសេដ្ឋកិច្ចក្រោមភាពជាប្រធានអាស៊ានតាមឆ្នាំនីមួយៗ (PEDs) និងកិច្ចការអាទិភាពប្រចាំឆ្នាំ និងបានបន្តពិនិត្យនិងពិភាក្សាលើវិធានយុទ្ធសាស្ត្រ (Strategic

Measures) នៃផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ាន ឆ្នាំ ២០២៦-២០៣០ សម្រាប់អនុវត្តទិដ្ឋភាពសេដ្ឋកិច្ច នៃចក្ខុវិស័យ សហគមន៍សេដ្ឋកិច្ចឆ្នាំ២០៤៥។ បច្ចុប្បន្នបានបញ្ចប់វិធានយុទ្ធសាស្ត្រ៧១% (ស្មើនឹង ១៤៩ នៃវិធានយុទ្ធសាស្ត្រសរុប២១០)។

- កិច្ចប្រជុំចង្អៀតថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣០ (30th AEM Retreat) និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៦ (56th AEM and Related Meeting)៖




- ផ្តល់ការឯកភាព និងកត់សម្គាល់លើឯកសារចំនួន ២៥ ដែលត្រូវបញ្ជូនទៅក្រុមប្រឹក្សាសហគមន៍សេដ្ឋកិច្ចអាស៊ាន និងថ្នាក់ដឹកនាំកំពូលអាស៊ានដើម្បីអនុម័ត ដែលមានឯកសារចំនួន ១៦ ស្ថិតក្រោមសមត្ថកិច្ចរបស់រដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន
- ផ្តល់ការឯកភាព និងវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព នៃសមិទ្ធផលអាទិភាពសេដ្ឋកិច្ច (Priority Economic Deliverables) ទាំង១៤ ក្រោមភាពជាប្រធានអាស៊ានប្តូរវេនរបស់ឡាវ ដែលក្នុងនោះសមិទ្ធផល៧ បានអនុវត្តបញ្ចប់ទាំងស្រុង សមិទ្ធផល៣ បានអនុវត្តបញ្ចប់ជាដុំកំភួន និងសមិទ្ធផល៤ ទៀតកំពុងអនុវត្តបន្ត

- ផ្តល់អនុសាសន៍លើវឌ្ឍនភាពការងារអាទិភាពប្រចាំឆ្នាំ២០២៤ ចំនួន ៤៣ ក្នុងនោះ ៣ បានចប់ពេញលេញ, ៣ ចប់ជាដុំកំភួន និង៣៧ កំពុងអនុវត្ត
- ផ្តល់អនុសាសន៍លើវឌ្ឍនភាពការចរចាកិច្ចព្រមព្រៀងថ្មី និងដំឡើងកម្រិតកិច្ចព្រមព្រៀងរួមមាន៖
  - ដំឡើងកម្រិតកិច្ចព្រមព្រៀងអាស៊ាន ស្តីពីពាណិជ្ជកម្មទំនិញ (ATIGA)៖ សម្រេចបាន ៦៨% នៃកថាខណ្ឌសរុប គ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៥
  - កិច្ចព្រមព្រៀងក្របខ័ណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន (DEFA)៖ សម្រេចបានចំនួន ១៤% នៃកថាខណ្ឌសរុប គ្រោងនឹងបញ្ចប់នៅឆ្នាំ២០២៥
  - កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា (ACAFTA), កិច្ចព្រមព្រៀងដំឡើងកម្រិតអាស៊ាន-ចិន ៣.0 (ACFTA 3.0), អាស៊ាន-សាធារណរដ្ឋកូរ៉េ (AKFTA) និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន-ឥណ្ឌា (AITIGA)។
- អនុម័តអនុសាសន៍កិច្ចប្រជុំក្រុមការងារជាន់ខ្ពស់ ស្តីពីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ជូនកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៥៦
- ពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានដៃគូ ក្នុងកិច្ចប្រជុំចំនួន ១៧ រួមមាន៖ កិច្ចប្រជុំជាមួយ WTO, ក្រុមប្រឹក្សាពិគ្រោះយោបល់ធុរកិច្ចអាស៊ាន ចក្រភពអង់គ្លេស កាណាដា សហភាពអឺរ៉ុប ស្វីស ហុងកុង សហរដ្ឋអាម៉េរិក ឥណ្ឌា រុស្ស៊ី អូស្ត្រាលីនិងនូវែលសេឡង់ ជប៉ុន ចិន សាធារណរដ្ឋកូរ៉េ អាស៊ានបូក៣ អាស៊ីបូព៌ា និងកិច្ចប្រជុំរដ្ឋមន្ត្រីអាសិប ដើម្បីតាមដានវឌ្ឍនភាពសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន ជាមួយដៃគូសន្ទនាអាស៊ាន។

**- កិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម លើកទី១៦ (16th CLMV EMM) បានកត់សម្គាល់ និងឯកភាពលើ៖**

- ផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៣-២០២៤
- អនុម័តផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៥-២០២៦ ក្នុងគោលបំណងដើម្បីបន្តកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយគម្លាតនៃការអភិវឌ្ឍក្នុងចំណោម

បណ្តារដ្ឋសមាជិកអាស៊ាន

- ពិភាក្សារៀបចំលក្ខខណ្ឌប្រតិបត្តិ របស់កិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច CLMV និងបានណែនាំឱ្យលេខាធិការដ្ឋានអាស៊ានសម្របសម្រួលស្នើការអនុម័តពីឧត្តមមន្ត្រីសេដ្ឋកិច្ចអាស៊ាន។

- កិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារនៃក្រុមប្រឹក្សាសម្របសម្រួលអាស៊ាន ស្តីពីការស្នើសុំចូលជាសមាជិកភាពអាស៊ាន របស់ប្រទេសទីម័រខាងកើត បានពិភាក្សា និងកត់សម្គាល់លើការងារដូចជា៖
  - វឌ្ឍនភាពការអនុវត្តផែនទីបង្ហាញផ្លូវ សម្រាប់ចូលជាសមាជិកភាពអាស៊ានពេញលេញរបស់ទីម័រខាងកើត។ ទីម័រខាងកើតត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ នៃកិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន ដើម្បីចូលជាសមាជិកពេញសិទ្ធិនៅឆ្នាំ២០២៥
  - ការចូលរួមរបស់ទីម័រខាងកើតក្នុងកិច្ចប្រជុំ និងសកម្មភាពនានាក្នុងក្របខ័ណ្ឌអាស៊ាន និងការកសាងសមត្ថភាពសម្រាប់ទីម័រខាងកើត។

- កិច្ចប្រជុំកំពូលអាស៊ានលើកទី៤៤និង៤៥នៅទីក្រុងវៀងច័ន្ទន៍សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមភាពជាប្រធានអាស៊ានប្តូរវេនរបស់ឡាវ កិច្ចប្រជុំកំពូលសម្រេចលទ្ធផល៖



- លើកកម្ពស់ការតភ្ជាប់ និងភាពធន់ ដែលផ្តោតលើការធ្វើសមាហរណកម្មសេដ្ឋកិច្ច បង្កើតអនាគតប្រកបដោយបរិយាបន្ននិងនិរន្តរភាព និងការផ្លាស់ប្តូរសម្រាប់យុគសម័យឌីជីថល ព្រមទាំងការពង្រឹងភាពធន់ដោយគាំទ្រដល់ការអភិវឌ្ឍចក្ខុវិស័យសហគមន៍អាស៊ាន២០៤៥ តាមរយៈការអនុម័តផែនការយុទ្ធសាស្ត្រដើម្បីអនុវត្តចក្ខុវិស័យនេះ
- ពង្រឹងមជ្ឈភាព និងឯកភាពអាស៊ាន នៅក្នុងបរិបទនិម្មាបនកម្មតំបន់ដែលកំពុងវិវត្ត និងទិដ្ឋភាពភូមិសាស្ត្រនយោបាយដែលមិនច្បាស់លាស់
- សង្កត់ធ្ងន់លើភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការសន្ទនាអាស៊ាន និងដៃគូខាងក្រៅ លើបញ្ហាដែលជាប្រយោជន៍រួម និងកង្វល់រួម ដើម្បីលើកកម្ពស់សន្តិភាព ស្ថិរភាព និងវិបុលភាពក្នុង និងក្រៅតំបន់
- ប្តេជ្ញាចិត្តចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគី ដែលមានលក្ខណៈសេរីបើកចំហ បរិយាបន្ន យុត្តិធម៌និងតម្លាភាព និងបង្កើនកិច្ចសហប្រតិបត្តិការក្នុងចំណោមប្រទេសសមាជិក និងដៃគូ។

- **ការងារគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន (IAI)** ៖ ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់តំបន់ស្តីពីការពង្រឹងការអនុវត្តផែនការការងារទី៤ នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន ២០២១-២០២៥, កិច្ចប្រជុំក្រុមការងារនៃគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ានលើកទី៧៤ និងកិច្ចពិគ្រោះយោបល់ IAI Task Force លើកទី១៤ ហើយជំហានបន្ទាប់គឺបន្តធ្វើការជាមួយសមាជិកដែលស្ថិតនៅក្រោមគម្រោង IAI និងស្វែងរកជំនួយមូលនិធិពីដៃគូអភិវឌ្ឍន៍នានាក្នុងការជំរុញសមាហរណកម្មអាស៊ាន។

### ១.២.២.កិច្ចការដៃគូអាស៊ាន

❖ **អាស៊ាន-កាណាដា (ASEAN – CANADA)**

- សម្រេចបានវឌ្ឍនភាពប្រមាណ ១១,៧% នៃការចរចាអត្ថបទទាំងមូល ហើយគ្រោងបញ្ចប់ការចរចា ជាដុំកំភួន (Substantial Negotiation) នៅចុងឆ្នាំ២០២៥។

❖ **អាស៊ាន-ចិន (ASEAN – CHINA)**

- បានបញ្ចប់ការចរចាជាដុំកំភួន (Substantial Conclusion) នៃការចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ៣.០ ដើម្បីដាក់ជូន

កិច្ចប្រជុំកំពូលអាស៊ាន-ចិន លើកទី២៧ ដើម្បីប្រកាសជាផ្លូវការ។ កិច្ចព្រមព្រៀងដំឡើងកម្រិតនេះ នឹងរួមចំណែកបន្ថែមទៀតដល់ការពង្រឹងសមាហរណកម្មសេដ្ឋកិច្ចតំបន់ តាមរយៈកិច្ចសហប្រតិបត្តិការកសិកម្ម និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែមានលក្ខណៈប្រសើរជាងមុន។

❖ **អាស៊ាន-ឥណ្ឌា (ASEAN – INDIA)**

- បន្តពិភាក្សា លើការពិនិត្យឡើងវិញកិច្ចព្រមព្រៀងទំនិញអាស៊ាន-ឥណ្ឌា ជាពិសេសលើបញ្ហាប្រឈមនឹងការចរចាធ្វើសេរីភាវូបនីយកម្ម បើកច្រកទីផ្សារទំនិញបន្ថែម ដែលភាគីឥណ្ឌាបានស្នើសុំរៀបចំតារាងកាត់បន្ថយ ឬលុបបំបាត់ពន្ធគយ សម្រាប់សមាជិកអាស៊ានដោយឡែករៀងៗខ្លួន។

❖ **អាស៊ាន-កូរ៉េ (ASEAN – KOREA)**

- បានពិភាក្សាលើរបាយការណ៍សិក្សារួមគ្នាលើកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងបានអនុម័តឱ្យរៀបចំការសិក្សាកំណត់វិសាលភាពចរចាដំឡើងកម្រិតកិច្ចព្រមព្រៀងឱ្យចប់នៅក្នុងឆ្នាំ២០២៥ និងចាប់ផ្តើមការចរចានៅឆ្នាំ២០២៦។

❖ **អាស៊ាន-សហភាពអឺរ៉ុប (ASEAN – EUROPEAN UNION)**

- កត់សម្គាល់លទ្ធផលកិច្ចប្រជុំក្រុមការងាររួមអាស៊ាន-សហភាពអឺរ៉ុប ស្តីពីពាណិជ្ជកម្ម និងវិនិយោគលើកទី២ និងបានពិភាក្សា លើសេចក្តីប្រកាសរួមស្តីពីកិច្ចសហប្រតិបត្តិការរវាងអាស៊ាន និងសមាគមន៍ពាណិជ្ជកម្មសេរីអឺរ៉ុប និងកម្មវិធីការងារអាស៊ាន-សហភាពអឺរ៉ុប ស្តីពីពាណិជ្ជកម្ម និងវិនិយោគ ២០២៤-២០២៥។

❖ **កិច្ចប្រជុំក្រោមកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (RCEP)**

- អនុម័តនីតិវិធីចូលជាសមាជិកកិច្ចព្រមព្រៀងអាសិប ផ្លាស់ប្តូរយោបល់ជំរុញសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ឱ្យកាន់តែស៊ីជម្រៅ និងការជ្រើសរើសនាយកប្រតិបត្តិអង្គភាពគាំទ្រអាសិបសម្រាប់អាណត្តិ២ឆ្នាំ។

❖ **អាស៊ាន-អូស្ត្រាលី-នូវ៉ែលសេឡង់ (ASEAN – AUSTRALIA & NEW ZEALAND)**

- ឯកភាព លើបញ្ហាទាក់ទងនឹងការស្នើសុំកែសម្រួលតារាងវិធានបដិលោម (Non- Conformity Measures) នៃពាណិជ្ជកម្មសេវារបស់នូវ៉ែលសេឡង់ ម៉ាឡេស៊ី និងកម្ពុជា ដើម្បីអាចឱ្យរដ្ឋសមាជិកយកពិធីសារនេះទៅបំពេញនីតិវិធីស្នើសុំការផ្តល់សច្ចាប័នពីអង្គនីតិបញ្ញត្តិរបស់ខ្លួន។

❖ អាស៊ាន-ជប៉ុន (ASEAN – JAPAN)

- **បានពិភាក្សា និងកត់សម្គាល់លើ៖**
  - ផែនការសកម្មភាពនៃការបង្កើតសេដ្ឋកិច្ចរួមគ្នារវាងអាស៊ាន និងជប៉ុន ប្រកបដោយនវានុវត្តន៍ និងចីរភាពឆ្នាំ២០២៣-២០៣៣
  - របាយការណ៍បឋម ស្តីពីការបង្កើតផែនការមេ សម្រាប់ឧស្សាហកម្មយានយន្តជំនាន់ក្រោយ ដែលបានរៀបចំដោយវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់កិច្ចការអាស៊ាន និងអាស៊ីបូព៌ា (ERIA)
  - វិសោធនកម្មលក្ខខណ្ឌប្រតិបត្តិរបស់ AMEICC ស្តីពីក្រុមការងារឧស្សាហកម្មយានយន្ត។

❖ **អាស៊ានបូកបី** (ASEAN PLUS 3)

- ពិភាក្សា និងកត់សម្គាល់វឌ្ឍនភាពការអនុវត្តកម្មវិធីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ានបូកបី ឆ្នាំ២០២៣-២០២៤ និងឆ្នាំ២០២៥-២០២៦។ គួរបញ្ជាក់ផងដែរថា យន្តការអាស៊ានបូកបី បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការកសាងសហគមន៍តំបន់ និងការជំរុញសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍន៍ក្នុងតំបន់ តាមរយៈការជំរុញពាណិជ្ជកម្ម និងវិនិយោគ ការពង្រឹងការតភ្ជាប់ក្នុងតំបន់ និងការកសាងភាពធន់ក្នុងតំបន់។

❖ **អាស៊ាន-ចក្រភពអង់គ្លេស** (ASEAN – UNITED KINGDOM)

- ពិភាក្សា និងកត់សម្គាល់លើការចាប់ផ្តើមអនុវត្តកម្មវិធីសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន-ចក្រភពអង់គ្លេស ដែលគាំទ្រដល់សមាហរណកម្មសេដ្ឋកិច្ចអាស៊ាន សំដៅជំរុញកំណើនប្រកបដោយបរិយាបន្ន និងបានកត់សម្គាល់លើវឌ្ឍនភាព នៃការអនុវត្តសកម្មភាពក្រោមផែនការការងារអាស៊ាន-ចក្រភពអង់គ្លេសស្តីពីសហប្រតិបត្តិការសេដ្ឋកិច្ច។

❖ **អាស៊ាន-ហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន** (ASEAN – HONG KONG, China)

- ពិភាក្សា និងកត់សម្គាល់លើវឌ្ឍនភាពនៃការចុះហត្ថលេខាលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុង នៃប្រទេសចិន និងជំរុញការផ្តល់សច្ចាប័ននៃពិធីសារទី១។

❖ **អាស៊ាន-សហរដ្ឋអាម៉េរិក** (ASEAN – UNITED STATES)

- បានពិភាក្សា និងកត់សម្គាល់លើរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការការងារក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-សហរដ្ឋអាមេរិក (TIFA) និងផែនការការងារពង្រីកការចូលរួមសេដ្ឋកិច្ច (E3) ឆ្នាំ២០២៣-២០២៤ និងឆ្នាំ២០២៤-២០២៥។

❖ **អាស៊ាន-រុស្ស៊ី (ASEAN – RUSSIA)**

- បានពិភាក្សា និងកត់សម្គាល់លើវឌ្ឍនភាពការអនុវត្តកម្មវិធីការងារពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-រុស្ស៊ី ឆ្នាំ២០២១-២០២៥។

### ១.២.៣.ការងារអនុតំបន់

❖ **កិច្ចការក្របខ័ណ្ឌយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច អាយេយ៉ាវ៉ាឌី-ចៅប្រាយ៉ា-មេគង្គ (ACMECS)**

- រៀបចំរបាយការណ៍វឌ្ឍនភាពរួម របស់គណៈកម្មាធិការសម្របសម្រួលការតភ្ជាប់ផ្នែកទន់ទទួលបន្ទុកសសរស្តម្ភទី២ ស្តីពីសេដ្ឋកិច្ចអេកម៉ិកមានភាពស៊ីសង្វាក់ក្រោមផែនការមេអេកម៉ិកឆ្នាំ២០១៩-២០២៣ សម្រាប់ដាឯកសារចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី១០ នៅទីក្រុងគុនមិញ សាធារណរដ្ឋប្រជាមានិតចិន
- ជំរុញការបង្កើតលក្ខខណ្ឌអំណោយផល ដល់សមាហរណកម្មសេដ្ឋកិច្ចក្នុងចំណោមប្រទេសសមាជិក ACMECS តាមរយៈការទទួលយក និងជំរុញការប្រើបច្ចេកវិទ្យាឌីជីថលសម្រាប់វិស័យពាណិជ្ជកម្ម និងវិស័យពាក់ព័ន្ធផ្សេងៗ ដែលក្នុងនោះការធ្វើបរិវត្តកម្មពាណិជ្ជកម្មឌីជីថល និងការប្រើប្រាស់មធ្យោបាយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដែលជាកត្តាគន្លឹះសម្រាប់ការតភ្ជាប់ និងការធ្វើសមាហរណកម្មនេះ។

❖ **កិច្ចការក្របខ័ណ្ឌមហាអនុតំបន់មេគង្គ (GMS)**

- ចូលរួមកិច្ចប្រជុំក្រុមការងារចំពោះកិច្ចស្តីពីពាណិជ្ជកម្ម និងវិនិយោគលើកទី៤ និងទី៦ នៅប្រទេសវៀតណាម ដោយពិភាក្សាលើ GMS Digitalization Action Plan (2025-2027) និងការរៀបចំយុទ្ធសាស្ត្រពាណិជ្ជកម្មឌីជីថលរបស់ GMS ឆ្នាំ២០៣០ (GMS Digital Trade Strategy 2030)។ ក្រុមការងារនេះនឹងត្រូវបានដំឡើងកម្រិតទៅជាក្រុមការងារ ដែលមានលក្ខណៈអចិន្ត្រៃយ៍

ដើម្បីបន្តនិរន្តរភាពចូលរួមធ្វើសមាហរណកម្មអនុតំបន់ និងកសាងសហគមន៍មួយប្រកបដោយភាពធន់ និងវិបុលភាពស្របតាមអនុសាសន៍របស់ប្រមុខដឹកនាំនៃបណ្តាប្រទេស GMS

- ចូលរួមក្នុងក្រុមការងារ GMS ស្តីពីពាណិជ្ជកម្ម និងវិនិយោគ ដើម្បីជំរុញលើកកម្ពស់កិច្ចសហប្រតិបត្តិការស្តីពីពាណិជ្ជកម្ម និងវិនិយោគក្នុងប្រទេសជាសមាជិក GMS សំដៅប្រើប្រាស់ឱ្យអស់សក្តានុពលដែលមានក្នុងតំបន់តាមរយៈការកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគ បង្កើនជំនឿចិត្ត និងប្រើប្រាស់បច្ចេកវិទ្យានិងភាពច្នៃប្រឌិតថ្មីៗ
- ចូលរួមអនុវត្តយុទ្ធសាស្ត្រនវានុវត្តន៍ GMS សម្រាប់ការអភិវឌ្ឍន៍ ២០៣០ ដើម្បីដោះស្រាយបញ្ហាប្រឈម និងកង្វះខាតក្នុងវិស័យពាក់ព័ន្ធ តាមរយៈការអនុវត្តវិធានយុទ្ធសាស្ត្រដូចជា បរិវត្តកម្មឌីជីថល អន្តរកម្មឆ្ពោះទៅ សេដ្ឋកិច្ចបៃតង និងធ្វើឱ្យប្រសើរឡើងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្នែកទន់និងរឹងពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្មវិនិយោគ ជាពិសេស ជំរុញការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងធុរកិច្ចឌីជីថល។

❖ កិច្ចការក្របខ័ណ្ឌសហប្រតិបត្តិការ AMEICC (AEM-METI Economic and Industrial Cooperation Committee)

- កិច្ចប្រជុំច្រករបៀងទិសបស្ចិម និងទិសបូព៌ា (AMEICC WEC) បានពិភាក្សាលើ៖
    - ការអនុវត្តគម្រោងស្តីពី ទស្សនវិស័យអភិវឌ្ឍន៍ឧស្សាហកម្មតំបន់មេគង្គ ដើម្បីលើកកម្ពស់បរិយាកាសធុរកិច្ចរវាងជប៉ុន និងបណ្តាប្រទេសមេគង្គ
    - ផែនការកម្មវិធីក្រោមការតភ្ជាប់ដែលមានគម្រោងចំនួន ១២៤ កំពុងអនុវត្ត
    - គម្រោង Global South Future-Oriented Co-Creation នឹងបង្កើនសកម្មភាពធុរកិច្ចពិសេសលើទិសដៅបណ្តុះបណ្តាល សហគ្រាសធុនតូចនិងមធ្យម ចំនួន ១៥០ សម្រាប់ឆ្នាំ២០២៤-២០២៦ ព្រមទាំងផ្តល់ចំណេះដឹង និងការចែករំលែកបច្ចេកវិទ្យា អភិវឌ្ឍនវានុវត្តន៍ និងការដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យារបស់ក្រុមហ៊ុនជប៉ុន ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងបណ្តាប្រទេសអភិវឌ្ឍន៍តិចតួច ក្នុងនោះភាគីជប៉ុននឹងចំណាយថវិកាចំនួន ១ប៊ីលានដុល្លារអាម៉េរិក។

❖ កិច្ចការក្របខ័ណ្ឌមេគង្គ-ឡានឆាង

- ផ្តល់ធាតុចូល លើសេចក្តីព្រាងឯកសារសម្រាប់កិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី៩ និងសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពស្តីពីការអនុវត្តផែនការសកម្មភាពនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

❖ កិច្ចការក្របខ័ណ្ឌមេគង្គ-ជប៉ុន

- ផ្តល់ធាតុចូល សម្រាប់ដាក់បញ្ចូលក្នុងសេចក្តីព្រាងយុទ្ធសាស្ត្រទីក្រុងតូក្យូឆ្នាំ២០២៤ ក្នុងការត្រៀមឯកសារសម្រាប់កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-ជប៉ុនលើកទី១៥។

## ១.៣.ការងារប្រព័ន្ធពាណិជ្ជកម្មសកល

### ១.៣.១.កិច្ចការអង្គការពាណិជ្ជកម្មពិភពលោក (WTO)



- រៀបចំព្រឹត្តិការណ៍អបអរសាទរខួប២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិក WTO នៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។ ក្នុងរយៈពេលជាង ២ទសវត្សរ៍ ចាប់តាំងពីកម្ពុជាក្លាយជាសមាជិក WTO ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី** និងក្រោមការដឹកនាំដ៏ស្វាហាប់ និងឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលជាមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និងពោរពេញដោយ

សមត្ថភាព ចំណេះដឹង និងថាមពល កម្ពុជាសម្រេចបានសមិទ្ធផលសំខាន់ៗ ជាច្រើនដូចខាងក្រោម៖

- ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ២០០៤ មានប្រមាណ ៥,៣ ពាន់លានដុល្លារអាម៉េរិក ខណៈពេលក្នុងឆ្នាំ២០២២ បានកើនរហូតដល់ ២៩,៦១ ពាន់លានដុល្លារអាម៉េរិក
- ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ អត្រាភាពក្រីក្របានធ្លាក់ចុះជាលំដាប់ក្នុងអត្រាមធ្យមប្រចាំឆ្នាំ១,៦% ពី ៦០% ក្នុងឆ្នាំ២០០០ មកត្រឹម ១៦% ក្នុងឆ្នាំ២០២២ ហើយសេដ្ឋកិច្ចរបស់កម្ពុជាបានកើនឡើងជាង ៧%ក្នុងមួយឆ្នាំ។ កំណើនដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជា ចាកចេញពីឋានៈជាប្រទេសក្រីក្រ និងបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥
- ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងពី ១១០លានដុល្លារអាម៉េរិក នៅឆ្នាំ២០០០ រហូតដល់ ៤,៩ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣
- ទំហំពាណិជ្ជកម្មរបស់កម្ពុជាមានប្រមាណ ៤,៥ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០០៤ ហើយបានកើនឡើងជាបន្តបន្ទាប់រហូតដល់ ៤៧,៨៨ពាន់លានដុល្លារអាម៉េរិក នៅឆ្នាំ២០២៣ ក្នុងនោះការនាំចេញសរុបរបស់កម្ពុជាមានប្រមាណ ២៣,៤៧ពាន់លានដុល្លារអាម៉េរិក
- ទំនិញនាំចេញរបស់កម្ពុជាត្រូវធ្វើពិពិធកម្មជាបន្តបន្ទាប់ ដោយបន្ថែមពីលើទំនិញសម្លៀកបំពាក់ ដែលជាទំនិញនាំចេញចម្បង កម្ពុជាបានបង្កើនមុខទំនិញនាំចេញបន្ថែម ដូចជា អង្ករ សម្ភារធ្វើដំណើរនិងកាបូប ស្បែកជើង គ្រឿងអេឡិចត្រូនិក និងភាគបង្គុំនិងកង់ ព្រមទាំងផលិតផលជាច្រើនទៀត។ ក្នុងឆ្នាំ២០២៣ ទំហំនាំចេញនៃទំនិញសំខាន់ៗរបស់កម្ពុជា រួមមាន៖
    - សម្លៀកបំពាក់ ៧,៨៦ពាន់លានដុល្លារអាម៉េរិក
    - អង្ករ ១,៧២ពាន់លានដុល្លារអាម៉េរិក
    - សម្ភារធ្វើដំណើរនិងកាបូប ១,៦៣ពាន់លានដុល្លារអាម៉េរិក

- ស្បែកជើងនិងស្រោមជើង ១,៣៦៣ពាន់លានដុល្លារអាម៉េរិក
- គ្រឿងអេឡិចត្រូនិកនិងភាគបង្គុំ ៣,១២ពាន់លានដុល្លារអាម៉េរិក
- កង់ ៤៨៩,៦១លានដុល្លារអាម៉េរិក។

- អនុវត្តយ៉ាងយកចិត្តទុកដាក់នូវកិច្ចព្រមព្រៀងពហុភាគីទាំងអស់របស់ WTO រួមមាន៖ កិច្ចព្រមព្រៀងទូទៅស្តីពីពន្ធគយ និងពាណិជ្ជកម្មឆ្នាំ១៩៩៤ (GATT 1994) កិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មសេវាកម្ម (GATS) កិច្ចព្រមព្រៀងស្តីពីកសិកម្ម (AOA) កិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (TRIPS) កិច្ចព្រមព្រៀង ស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម (TFA) និងកិច្ចព្រមព្រៀងពាក់ព័ន្ធ
- ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក៏ដូចជាការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រផ្សេងៗដូចជាកិច្ចសម្រួលពាណិជ្ជកម្មនិងប្រព័ន្ធបញ្ជរតែមួយជាតិ
- ចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៣ (MC13) របស់ WTO និងកិច្ចប្រជុំតុមូលចិនលើកទី១២ នៅប្រទេសអេមីរ៉ាតអារ៉ាប់រួម ដោយបានឯកភាពលើសេចក្តីសម្រេច និងសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីសរុបចំនួន 10 ហើយបន្តចរចាបញ្ហាដែលនៅសេសសល់ រួមមាន៖ (១)-កិច្ចព្រមព្រៀងឧបត្ថម្ភធនជលផលដំណាក់កាលទី២ (២)-ការធ្វើកំណែទម្រង់កសិកម្ម៖ ការស្តុកទុកសាធារណៈ យន្តការការពារពិសេសការឧបត្ថម្ភធនក្នុងស្រុក (៣)-វិធានការគាំទ្រការផ្លាស់ប្តូរដោយរលូនសម្រាប់ប្រទេស ដែលបានចាកចេញពីចំណាត់ថ្នាក់ប្រទេសអភិវឌ្ឍន៍តិចតួចបំផុតទី២ និង(៤)-កំណែទម្រង់ WTO និងប្រព័ន្ធដោះស្រាយវិវាទ។ល។
- ដាក់លិខិតុបករណ៍ទទួលយក កិច្ចព្រមព្រៀងស្តីពីឧបត្ថម្ភធនជលផលជូន WTO។ កិច្ចព្រមព្រៀងនេះមានសមាជិកចំនួន ៨៦បានផ្តល់សច្ចាប័ន។ ដើម្បីឱ្យកិច្ចព្រមព្រៀងនេះចូលជាធរមាន តម្រូវឱ្យប្រទេសចំនួន ១១១ ផ្តល់សច្ចាប័ន។ កម្ពុជាកំពុងទាញយកជំនួយពីមូលនិធិជលផល (Fish Fund) ដើម្បីយកមកអភិវឌ្ឍសមត្ថភាពក្នុងវិស័យជលផល
- ធ្វើបច្ចុប្បន្នភាពលើតារាងកិច្ចសន្យាសេវាកម្ម (GATS Commitments) ក្រោមក្របខ័ណ្ឌ WTO ត្រង់វិស័យ (១)-Financial Services: Reinsurance and Retrocession (CPC 81299) និង(២)-Banking and Other Financial Services។

### ១.៣.២. ការងារផ្ដល់ព័ត៌មាន

អនុវត្តតាមកាតព្វកិច្ច នៃការសន្យាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្រសួងពាណិជ្ជកម្មដើរតួនាទីជាចំណុចកណ្ដាលក្នុងការផ្ដល់ព័ត៌មាន ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

- ផ្ដល់ព័ត៌មានពីការអនុវត្តច្បាប់ស្ដីពីវិធានដើមកំណើតទំនិញ
- ផ្ដល់ព័ត៌មានអំពីវិធានការផ្អាកការនាំចូលជាបណ្ដោះអាសន្ននូវ គ្រឿងក្នុង និងបំណែកសាច់បង្កក
- ផ្ដល់ព័ត៌មានតាមកាតព្វកិច្ចរៀងរាល់ ២ឆ្នាំម្ដង ក្រោមកិច្ចព្រមព្រៀងស្ដីពីការឧបត្ថម្ភធន និងវិធានការពន្ធប៉ះប៉ូវ
- ផ្ដល់ព័ត៌មានស្ដីពីការអនុវត្តពន្ធគយក្រោមគោលការណ៍ប្រជាជាតិ ដែលទទួលបានភាពអនុគ្រោះបំផុត (MFN Applied 2024 tariff) និងការមិនទាន់បានផ្ដល់ព័ត៌មានអំពី (MFN Applied Tariff Information for the year 2004) និង (Detailed Import Statistics for the years 2004, 2012-2015)
- ផ្ដល់ព័ត៌មានស្ដីពីនីតិវិធីអាជ្ញាបណ្ណនាំចូលទំនិញ
- ផ្ដល់ព័ត៌មានក្រោម សេចក្ដីសម្រេចស្ដីពីនីតិវិធីផ្ដល់ព័ត៌មានសម្រាប់ការរឹតត្បិតបរិមាណនាំចេញ នាំចូលទំនិញសម្រាប់ឆ្នាំ២០២២-២០២៤
- ផ្ដល់ព័ត៌មានច្បាប់ស្ដីពីការការពារ រុក្ខជាតិ និងភូតគាមអនាម័យ និងច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារ។

### ១.៣.៣.ការងារត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្ម

- ការងារត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី៣ (3rd TPR)៖ សហការជាមួយលេខាធិការដ្ឋាន WTO រៀបចំរបាយការណ៍លេខាធិការដ្ឋាន និងរបាយការណ៍របស់រាជរដ្ឋាភិបាល និងប្រមូលទិន្នន័យ ស្ថិតិ និងឯកសារចាំបាច់សម្រាប់ចងក្រងជារបាយការណ៍ចប់សព្វគ្រប់
- សម្របសម្រួលជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីបំពេញកម្រងសំណួរស្ទង់មតិពាក់ព័ន្ធនឹងការវិនិយោគថ្នាក់ជាតិ និងកិច្ចព្រមព្រៀងវិនិយោគអន្តរជាតិ ដែលកម្រងសំណួរទាំងនេះត្រូវបានឆ្លើយតប និងផ្ញើត្រលប់ទៅអង្គការ UNCTAD វិញរួចរាល់។

## ១.៤.ការងារគ្រប់គ្រងជំនួយ

### ១.៤.១.ការងារកៀរគរជំនួយ

- បានទទួលជំនួយហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស បន្ថែមក្នុងឆ្នាំ២០២៤ មកពីអង្គភាព EIF (៩៨ ៩៨០ ដុល្លារអាម៉េរិក) សហគមន៍អឺរ៉ុបនិងរដ្ឋាភិបាលអាល្លឺម៉ង់ (៩,៩ លានអឺរ៉ូ) អង្គការ IFAD (២០លានដុល្លារអាម៉េរិក) អង្គការ CAPRED/DFAT Australia (១០២ ៥០០ដុល្លារអាម៉េរិក) និងជំនួយបច្ចេកទេសពី ADB ក្រោមអនុកម្មវិធីទី២+៣ (១០០លានដុល្លារអាម៉េរិក) សរុបជាទឹកប្រាក់ប្រមាណជាង ១៣០លានដុល្លារអាម៉េរិក។ ក្រៅពីនេះ បានសម្របសម្រួលបញ្ជូនសំណើគម្រោងចំនួន ៦ ទៅរដ្ឋាភិបាលចិន សំណើគម្រោងចំនួន ៩ ពីគម្រោង EU GATE និងសំណើគម្រោងចំនួន ១ ទៅមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC)
- ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់គោលនយោបាយលើរបាយការណ៍សេដ្ឋកិច្ច និងសង្គមនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ឆ្នាំ២០២៤ របស់ UN-ESCAPS ស្តីពី "Boosting Affordable and Longer-Term Financing for Governments" ជាលទ្ធផលរាជរដ្ឋាភិបាលកម្ពុជានៅតែត្រូវការការគាំទ្រ និងជំនួយបន្ថែមពីដៃគូ ដោយបន្តការកៀរគរសម្បទានពីសហគមអន្តរជាតិ និងបន្តពង្រឹងការប្រមូលចំណូលពន្ធ
- បានប្រជុំជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបន្តតាមដានលើការសិក្សាពីច្បាប់ស្តីពីកំណត់ត្រាដែលអាចផ្ទេរបានតាមប្រព័ន្ធអេឡិចត្រូនិក (MLETR)
- បានរៀបចំសំណើគម្រោង ក្នុងការស្នើសុំហិរញ្ញប្បទានចំនួន ២៥ ០០០ ដុល្លារអាម៉េរិក សម្រាប់ការរៀបចំសិក្ខាសាលាប្រមូលធាតុចូលលើប្រធានបទ High Level Policy Dialogue on Sustainable Trade and Tourism
- បានដាក់សំណើគម្រោងចំនួន ៦ ទៅស្ថានទូតចិនប្រចាំនៅកម្ពុជា ដើម្បីទទួលបានជំនួយជាបច្ចេកទេស និងហិរញ្ញវត្ថុក្នុងការអនុវត្តគម្រោង
- សហការជាមួយ UNDP Cambodia ក្នុងការអនុវត្តគម្រោងថ្មី និងបង្កើតយុទ្ធសាស្ត្រគោលនយោបាយ សម្រាប់ក្រសួងពាណិជ្ជកម្មនៅរយៈពេល ៥ឆ្នាំបន្ទាប់លើការងារអាទិភាពចំនួន២ រួមមាន៖ (១)-ការរៀបចំគោលនយោបាយ ឬយុទ្ធសាស្ត្រសូត្រកម្ពុជា (២)-រៀបចំសំណើគម្រោងរួមគ្នា

ជាមួយ UNDP ដើម្បីស្នើជំនួយសម្រាប់វិស័យអាទិភាពដែលមានតម្លៃបន្ថែម (Value Addition Sectors) ពីប្រភពដៃគូអភិវឌ្ឍន៍ផ្សេងៗ

- សហការជាមួយអង្គការ UNDP Cambodia ដើម្បីបង្កើត Green Trade Standards Roadmap សម្រាប់កម្ពុជា ឱ្យស្របតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក និងបទដ្ឋានគតិយុទ្ធផ្សេងៗនៃពាណិជ្ជកម្មបៃតងរបស់សហគមន៍អឺរ៉ុប។

### ១.៤.២.ការងារគ្រប់គ្រងជំនួយ

- គម្រោង EIF ជំនួយហិរញ្ញវត្ថុសម្រាប់រៀបចំបង្កើតក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០
- គម្រោង EU-German GATE ជំនួយហិរញ្ញវត្ថុសម្រាប់រៀបចំ៖ (១)-ធ្វើគោលនយោបាយពាណិជ្ជកម្ម (២)-កិច្ចសម្រួលពាណិជ្ជកម្ម (៣)-គ្រប់គ្រងហានិភ័យ (៤)-ពាណិជ្ជកម្មឌីជីថល (៥)-ការបង្កើនភាពប្រកួតប្រជែងរបស់សហគ្រាសធុនតូច និងមធ្យម
- គម្រោង CAPRED/DFAT Australia ជំនួយហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់រៀបចំបង្កើតថ្នាលកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី FTAs Portal
- គម្រោង ADB ជំនួយបច្ចេកទេសលើការរៀបចំ៖ (១)-ប្រកាសស្តីពីការអនុវត្តសិទ្ធិរបស់គូភាគីនៃប្រតិបត្តិការដែលមានកិច្ចធានា (២)-អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម។

### ១.៤.៣.ការងារត្រួតពិនិត្យ និងវាយតម្លៃគម្រោង

- បញ្ចប់ការអនុវត្តគម្រោងអភិវឌ្ឍន៍ពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក (Go4eCAM) ដែលជាជំនួយសម្បទានពីអង្គការ EIF ដោយបានបង្កើតផ្សារខេមបូឌាត្រេដ និងផ្តល់ការបណ្តុះបណ្តាលជំនាញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងជំនាញសហគ្រិនភាពទៅដល់បណ្តាសហគ្រាសធុនតូច និងមធ្យមដែលមានសក្តានុពល
- បញ្ចប់ការអនុវត្តគម្រោង សមាហរណកម្មតំបន់អាស៊ានជំនួយពាក់ព័ន្ធពាណិជ្ជកម្មកម្ពុជា (ARISE Plus Cambodia) ជាមួយអង្គការ GIZ Cambodia ដែលជាជំនួយបច្ចេកទេសពីសហភាពអឺរ៉ុប និងរដ្ឋាភិបាលអាល្លឺម៉ង់ ដោយទទួលបានសមិទ្ធផលដូចជា៖ (១)-ការធ្វើឌីជីថលភាវូប

នីយកម្មគយកម្ពុជា (២)-ការកសាងសមត្ថភាពមន្ត្រីរាជការលើកិច្ចចរចាពាណិជ្ជកម្មសេរី (៣)-បង្កើតគណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម និង(៤)-ការផ្តល់ជំនួយបច្ចេកទេសលើ ការស្នើសុំស្តង់ដានិងវិញ្ញាបនបត្រ សម្រាប់ការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមផងដែរ។

## ១.៥.ការងារស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំអង្គការពាណិជ្ជកម្មពិភពលោក

### ១.៥.១.ការងារជាមួយអង្គការពាណិជ្ជកម្មពិភពលោក (WTO)

- ចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីលើកទី១៣ (MC13) នៅទីក្រុងអាប៊ូដាប៊ី អេមីរ៉ាតអារ៉ាប់រួមបានឯកភាពលើខ្លឹមសារៈ
  - សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីអាប៊ូដាប៊ី
  - សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីស្តីពីកំណែទម្រង់អង្គភាពដោះស្រាយវិវាទ
  - សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីលើកទី១៣ ស្តីពីប្រព្រឹត្តកម្មពិសេស និងដោយឡែក (Special and Differential Treatment) ក្រោមកិច្ចព្រមព្រៀងអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសចំពោះពាណិជ្ជកម្ម សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍និងប្រទេសអភិវឌ្ឍន៍តិចតួច
  - សម្រេចជាផ្លូវការឱ្យប្រទេសទីម័រខាងកើត និងប្រទេសកូម៉ូរ៉ូស ក្លាយជាសមាជិក WTO
  - សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រី លើកម្មវិធីការងារស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងការបន្តពន្យារពេលការមិនយកពន្ធលើទំនិញបញ្ជូនតាមប្រព័ន្ធអេឡិចត្រូនិករហូតដល់កិច្ចប្រជុំ MC14
  - សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រី លើការបន្តពន្យារពេលការលើកលែងស្តីពីបណ្តឹងពុំមានវិការៈ និងការបំពាន (Non-violation and Situation Complaints) ក្រោមកិច្ចព្រមព្រៀង TRIPS រហូតដល់កិច្ចប្រជុំ MC14
  - សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីស្តីពីវិធានការគាំទ្រ របស់ WTO ដល់ប្រទេសដែលចាកចេញពីឋានៈប្រទេសអភិវឌ្ឍន៍តិចតួចដោយរលូន
  - សេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រី ស្តីពីកម្មវិធីការងារ សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចតូច (Small Economy)។
- ចូលរួម និងផ្តល់បទអន្តរាគមន៍នៅក្នុងកិច្ចប្រជុំអគ្គក្រុមប្រឹក្សានៃ WTO

ចំនួន៥ លើក លើបញ្ហាដែលនៅមិនទាន់បានឯកភាពក្នុងកិច្ចប្រជុំ MC13៖

- បញ្ហាពាក់ព័ន្ធនឹងការចរចាស្តីពីកសិកម្ម និងឧបត្ថម្ភធនជលផល
- សំណើក្រុមប្រទេស LDCs ស្តីពីការចាកចេញពីឋានៈប្រទេស LDCs
- កំណែទម្រង់អង្គភាពដោះស្រាយវិវាទ
- សេចក្តីសម្រេចស្តីពីការដាក់កិច្ចព្រមព្រៀង (Investment Framework for Development-IFD) ចូលក្នុងកិច្ចព្រមព្រៀង WTO E-commerce Work Program។

- ចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា នៃកិច្ចព្រមព្រៀងទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា (The Council for Trade-Related Aspects of Intellectual Property Rights-TRIPS) ចំនួន ៣លើក៖
  - កិច្ចប្រជុំលើកទី១ និងទី២៖ បានអនុម័តលើរបាយការណ៍ចំនួន ២ គឺ (១)-របាយការណ៍ពាក់ព័ន្ធនឹងកថាខណ្ឌទី៨ នៃសេចក្តីសម្រេចថ្នាក់រដ្ឋមន្ត្រីលើកទី១២ ស្តីពីកិច្ចព្រមព្រៀង TRIPS, (២)-របាយការណ៍ពាក់ព័ន្ធនឹងកថាខណ្ឌទី២៣-២៤ នៃសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីការឆ្លើយតបរបស់ WTO ចំពោះជំងឺឆ្លងរាតត្បាតកូវីដ-១៩ និងការត្រៀមខ្លួនសម្រាប់ជំងឺឆ្លងផ្សេងទៀតនាពេលអនាគត
  - កិច្ចប្រជុំលើកទី៣៖ ពិភាក្សាលើខ្លឹមសារនៃវាក្យខណ្ឌទី២ នៃសេចក្តីសម្រេចស្តីពីការអនុវត្តមាត្រា៦៦ នៃកិច្ចព្រមព្រៀង TRIPS (LDCs) ក្នុងនោះកម្ពុជាបានលើកឡើងអំពី ការចាំបាច់នៃការផ្ទេរបច្ចេកវិទ្យា និងជំនាញ សម្រាប់បង្កើនគុណភាព តម្លៃបន្ថែម និងការប្រកួតប្រជែងដែលគាំទ្រដល់ខ្សែច្រវាក់ផលិតកម្មក្នុងស្រុក។
- សម្របសម្រួលតម្កល់លិខិតុបករណ៍ ក្នុងការទទួលយកកិច្ចព្រមព្រៀងស្តីពីការឧបត្ថម្ភធនជលផលនៅអង្គការពាណិជ្ជកម្មពិភពលោក
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងលេខាធិការដ្ឋាន WTO ទាក់ទងនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន និងកម្ពុជា-កូរ៉េ ហើយបានបញ្ជូនព័ត៌មាន និងទិន្នន័យ សម្រាប់ការឆ្លើយតបទៅនឹងសំណួររបស់សមាជិក WTO ពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងពាណិជ្ជកម្មខាងលើនេះ
- ចូលរួមកិច្ចប្រជុំរបស់អង្គភាពដោះស្រាយវិវាទចំនួន ១០លើក ជាលទ្ធផល

ក្នុងនាមជាជនបង្គោលរបស់ក្រុមប្រទេសអភិវឌ្ឍន៍តិចតួច សម្រាប់ការងារកំណែទម្រង់អង្គភាពនេះ៖

- កម្ពុជាបន្តចូលរួមជាមួយសមាជិក ១៣០ប្រទេសផ្សេងទៀត ស្នើសុំចាប់ផ្តើមនីតិវិធីជ្រើសរើសសមាជិកអង្គភាពឧទ្ធរណ៍ ដែលជាប់គាំងតាំងពីឆ្នាំ២០១៩ និងស្នើសុំឱ្យមានកិច្ចប្រជុំចរចាជាផ្លូវការស្របតាមប្រព័ន្ធពាណិជ្ជកម្មពហុភាគី
- បានចូលរួមពិភាក្សា ចរចា និងផ្តល់យោបល់លើសេចក្តីព្រាងអត្ថបទអំពី Accessibility និង Appeal Review។

- ធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សាតុមូលជាន់ខ្ពស់ស្តីពី វិធានដើមកំណើតទំនិញក្នុងបរិបទពាណិជ្ជកម្មពិភពលោក (Rules of Origin in a Fractioned World Trade) ជាលទ្ធផល បានធ្វើបទបង្ហាញស្តីពីការសិក្សានៃវិធានដើមកំណើតទំនិញលើវិស័យឧស្សាហកម្មផលិតកម្មទោចក្រយាន។

### ១.៥.២.ការងារជាមួយសន្និសីទសហប្រជាជាតិស្តីពីពាណិជ្ជកម្មនិងការអភិវឌ្ឍ(UNCTAD)

- ក្នុងតួនាទីផ្លូវការជាប្រធានក្រុម៧៧និងចិន (G77 and China) ដែលមានសមាជិកចំនួន ១៣៤ប្រទេស កម្ពុជាបានដឹកនាំសម្របសម្រួលការចរចា និងកិច្ចប្រជុំជាច្រើនលើក។ ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖
  - កិច្ចចរចាក្នុងក្របខ័ណ្ឌអង្គការ UNCTAD និងក្រោមក្របខ័ណ្ឌក្រុម៧៧ និងចិនសរុបចំនួន៨៩លើក រួមមាន ការធ្វើជាតំណាងក្រុមក្នុងកិច្ចប្រជុំផ្លូវការចំនួន ២៥លើក និងកិច្ចប្រជុំចង្អៀត ៦៤លើក ព្រមទាំងសម្របសម្រួលនិងថ្លែងបទអន្តរាគមន៍ផ្លូវការតំណាងឱ្យក្រុមចំនួន ៤៧លើក
  - បង្កើតក្រុមការងារចំនួន ៣៖ (១)-ក្រុមការងារការប្រែប្រួលអាកាសធាតុ ពាណិជ្ជកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព (២)-ក្រុមការងារសេដ្ឋកិច្ចឌីជីថល និងឌីជីថលសម្រាប់ការអភិវឌ្ឍ (៣)-ក្រុមការងារហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ
  - សម្របសម្រួលផ្តល់ធាតុចូលរបស់ក្រុមហ្សីណែវ ស្តីពីអន្តរកម្មចាំបាច់ស្តីពីការប្រើប្រាស់ថាមពល ដែលបានពីប្រភពរ៉ែឆ្ពោះទៅការប្រើប្រាស់ថាមពលបានពីប្រភពស្អាត (CETMs)
  - សម្រេចបានការគាំទ្រជាឯកច្ឆន្ទ លើមូលបទសម្រាប់សន្និសីទរដ្ឋមន្ត្រី

លើកទី១៦ របស់អង្គការ UNCTAD

- សហការដឹកនាំកិច្ចប្រជុំចង្អៀតក្រុម៧៧និងចិន ដើម្បីត្រៀមឯកសារជំហរសម្រាប់ក្រុមក្នុងការចរចា UNCTAD 16 Outcomes ដែលគ្រោងនឹងបញ្ចប់នៅចុងខែមករា/កុម្ភៈ ឆ្នាំ២០២៥ ស្របនឹងការផ្ទេរតួនាទីប្រធានជូនប្រទេសប៉េរូ។

- សម្របសម្រួលចូលរួមរៀបចំឯកសារ និងចូលរួមកិច្ចប្រជុំលើកទី៧របស់ UNCTAD ស្តីពី Intergovernmental Group of Experts (IGE) on E-commerce and the Digital Economy UNCTAD បានរៀបចំជំនួបទ្វេភាគីរវាងកម្ពុជាជាមួយអង្គការ UNCTAD, WTO, ITC, WIPO, និងEIF ក្នុងគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី និងស្នើសុំការគាំទ្រនៅមុននិងក្រោយកម្ពុជាចាកចេញពីឋានៈជាក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ដោយទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា។

### ១.៥.៣.ការងារជាមួយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO)

- ការចូលរួមប្រជុំ និងកិច្ចសហប្រតិបត្តិការទាញយកប្រយោជន៍ពី WIPO ចូលរួមជាវាគ្មិនក្នុងការពិភាក្សាតុមូលក្នុងនាមជា Friends of Lisbon ស្តីពីកិច្ចសហប្រតិបត្តិការត្បូង-ជើង លើទំនិញម៉ាកសម្គាល់ភូមិសាស្ត្រព្រមទាំងតាំងបង្ហាញផលិតផលម៉ាកសម្គាល់ភូមិសាស្ត្រកម្ពុជា (ម្រេចកំពតស្ករត្នោតកំពង់ស្ពឺ ទឹកឃ្មុំព្រៃមណ្ឌលគិរី និងផ្កាអំបិលកំពត-កែប)

- សន្និសីទការទូតស្តីពី សន្ធិសញ្ញាអន្តរជាតិ ស្តីពីធនធានសេនេទិច និងធនធានសេនេទិចទាក់ទងនឹងចំណេះដឹងប្រពៃណី ជាលទ្ធផលបានបញ្ចប់សន្ធិសញ្ញាអន្តរជាតិនេះ ហើយមានប្រទេសចំនួន៣១ រួមទាំងកម្ពុជាបានចុះហត្ថលេខាផងដែរ។

### ១.៥.៤.ការងារជាមួយអង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)

- ចូលរួមប្រជុំជាមួយ UNIDO តាមប្រព័ន្ធវីដេអូ អំពីប្រធានបទពាក់ព័ន្ធនឹងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចឧស្សាហកម្ម និងពាណិជ្ជកម្ម ព្រមទាំងបន្តតាមដានគម្រោងនានា ដែលពាក់ព័ន្ធនឹងការឧបត្ថម្ភជំនួយបច្ចេកទេសដល់កម្ពុជា និងសម្របសម្រួលបញ្ជូនព័ត៌មាន និងឯកសារផ្លូវការរបស់ UNIDO ទៅក្រសួង ស្ថាប័នពាក់ព័ន្ធទាក់ទងនឹងកម្មវិធីជំនួយបច្ចេកទេសដូចជា៖

Program for Country Partnership (PCP) និងការអនុវត្តគម្រោង CAPFish Project។

### ១.៥.៥.ការងារជាមួយអង្គការមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ (ITC)

- ចូលរួមសម្របសម្រួលការអនុវត្តគម្រោង SheTrades Outlook គម្រោងនេះជួយពង្រឹងដល់ការប្រកួតប្រជែងរបស់ SMEs និងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកនៅកម្ពុជា និងបានរៀបចំសិក្ខាសាលាថ្នាក់ជាតិស្តីពី SheTrades Outlook ដើម្បីពិនិត្យលើរបាយការណ៍អនុវត្តគម្រោង ដែលជាលទ្ធផលនៃការសិក្សាស្រាវជ្រាវ។
- ចូលរួមសម្របសម្រួលការអនុវត្តគម្រោង UKTP Program គម្រោងនេះជួយពង្រឹងនិងស្វែងរកទីផ្សារ សម្រាប់ផលិតផលកសិកម្មរបស់កម្ពុជាទៅចក្រភពអង់គ្លេស និងសហគមន៍អឺរ៉ុបតាមរយៈការតាំងពិព័រណ៍ផលិតផល
- ចូលរួមសម្របសម្រួល ការអនុវត្តគម្រោងជំនួយផ្នែកគោលនយោបាយពាណិជ្ជកម្មរបស់អង្គការ ITC ដែលបានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអនុវត្តពាក់ព័ន្ធនឹងគោលនយោបាយពាណិជ្ជកម្មឌីជីថលរបស់កម្ពុជា
- កិច្ចសហប្រតិបត្តិការដើម្បីត្រៀមអនុវត្តគម្រោងអាទិភាពនានា ស្របតាមតម្រូវការនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដូចជាគម្រោង៖ (១)-ក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្ម (២)-ការដំឡើងកម្រិតពាណិជ្ជកម្មសេវាកម្ម (៣)-ផែនការជាតិសម្រាប់បរិវត្តកម្មឌីជីថល (៤)-ការចូលរួមរបស់សហគ្រាសធុនតូចនិងមធ្យមក្នុងសេដ្ឋកិច្ចឌីជីថល (៥)-ការចាកចេញពី LDCs (៦)-ការវិនិយោគ ការអភិវឌ្ឍដោយចីរភាព និងការប្រកួតប្រជែង (៧)-ការពង្រឹងសេដ្ឋកិច្ចរបស់ស្ត្រីនិងសមភាពយេនឌ័រ និង (៨)-ការពង្រឹងប្រព័ន្ធអេកូឡូស៊ីធុរកិច្ចនិងពាណិជ្ជកម្មសម្រាប់ស្ត្រី។

### ១.៦.ការចូលរួមអមដំណើរកិច្ចប្រជុំថ្នាក់ដឹកនាំកម្រិតអន្តរជាតិ

សម្របសម្រួល រៀបចំឯកសារ និងអមដំណើរ **សម្តេចធិបតីនាយករដ្ឋមន្ត្រី៖**

- ក្នុងការអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋកូរ៉េ ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-សាធារណរដ្ឋកូរ៉េ និងធាតុចូលផ្សេងៗ។ សម្រេចបានការចុះហត្ថលេខាទ្វេភាគីស្តីពី ការពង្រឹងកិច្ចសហប្រតិបត្តិការ

កម្មសិទ្ធិបញ្ញារវាងភាគីទាំងពីរ

- ក្នុងការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសម៉ាឡេស៊ី ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ម៉ាឡេស៊ី។ ជាលទ្ធផលសម្រេចបានការលើកកម្ពស់ទំនាក់ទំនងពាណិជ្ជកម្ម-សេដ្ឋកិច្ច និងជំរុញកាលានុវត្តភាពធុរកិច្ចរវាងកម្ពុជា និងម៉ាឡេស៊ី
- ក្នុងការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសថៃ ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ថៃ។ ជាលទ្ធផលបានពិភាក្សាការងារលើកិច្ចសហប្រតិបត្តិការទ្វេភាគី និងពហុភាគី ដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកក្នុងវិស័យពាណិជ្ជកម្មធុរកិច្ច និងវិនិយោគ ព្រមទាំងវិស័យពាក់ព័ន្ធសំខាន់ៗមួយចំនួនទៀត
- ការអញ្ជើញចូលរួមកិច្ចប្រជុំកំពូលអបអរសាទរខួបអនុស្សាវរីយ៍ លើកទី៥០ នៃទំនាក់ទំនងដៃគូសន្ទនា អាស៊ាន-អូស្ត្រាលី នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ព្រមទាំងរៀបចំចំណុចពិភាក្សា និងជំនួយស្មារតីស្តីពីរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលី កម្ពុជា-ឥណ្ឌូណេស៊ី កម្ពុជា-ហ្វីលីពីន កម្ពុជា-សិង្ហបុរី និងកម្ពុជា-នូវែលសេឡង់ ដើម្បីជាធាតុចូលសម្រាប់កិច្ចប្រជុំ និងរៀបចំសុន្ទរកថាគន្លឹះបើកសម្រាប់ចូលរួមជាអធិបតីក្នុង «វេទិកាធុរកិច្ចអូស្ត្រាលី-កម្ពុជា»
- ក្នុងឱកាសទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតី ស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា-ឡាវ និងធាតុចូលសម្រាប់កិច្ចប្រជុំ និងសម្រាប់ការជួបសម្តែងការគួរសមជាមួយប្រធានក្លឹបធុរកិច្ចកម្ពុជាប្រចាំប្រទេសឡាវ។ ជាលទ្ធផល ក្នុងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្មភាគីទាំងពីរបានពិភាក្សាគ្នាលើសារៈសំខាន់នៃការរៀបចំកិច្ចប្រជុំលើកទី១៥ នៃគណៈកម្មការរួមសម្រាប់កិច្ចសហប្រតិបត្តិការ JCBC, ការដាក់ឱ្យដំណើរការឡើងវិញគណៈកម្មការពាណិជ្ជកម្មចម្រុះ ជាមួយការរៀបចំវេទិកាធុរកិច្ច និងវិនិយោគ និងការពង្រីកសមាហរណកម្មសេដ្ឋកិច្ចតាមរយៈ

ការផ្លាស់ប្តូរពាណិជ្ជកម្មលើវិស័យសេវាកម្ម ដូចជាសេវាហិរញ្ញវត្ថុ ដឹកទំនិញផ្លូវគោក និងទេសចរណ៍

- ក្នុងការអញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសសិង្ហបុរី ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតី ស្តីពីរបាយការណ៍វឌ្ឍនភាព នៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-សិង្ហបុរី។ ជាលទ្ធផលសម្រេចបានកិច្ចសហប្រតិបត្តិការជំរុញវិស័យពាណិជ្ជកម្ម និងការវិនិយោគសមភាគីទាំងពីរបានឯកភាពគ្នាក្នុងការរៀបចំក្រុមការងាររួម ដើម្បីពិភាក្សាអំពីមធ្យោបាយ និងផែនការសកម្មភាព ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវកិច្ចសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម និងការវិនិយោគនៃប្រទេសទាំងពីរ
- ការចូលសម្តែងការគួរសមនិងពិភាក្សាការងារជាមួយប្រធានប្រតិបត្តិនៃតំបន់រដ្ឋបាលពិសេសហុងកុង និងគណៈប្រតិភូ ព្រមទាំងបានរៀបចំចំណុចពិភាក្សា និងជំនួយស្មារតី ស្តីពីរបាយការណ៍វឌ្ឍនភាព ស្តីពីកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-តំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២៤ នៃវេទិកាសេដ្ឋកិច្ចពិភពលោក ព្រមទាំងរៀបចំឯកសារ ព័ត៌មានពាក់ព័ន្ធ និងបដិសណ្ឋារកិច្ច។ **សម្តេចធិបតី** បានអញ្ជើញថ្លែងបទអន្តរាគមន៍លើប្រធានបទ «ការស្តារទំនុកចិត្តឡើងវិញលើប្រព័ន្ធសកលលោក»
- ក្នុងជំនួបជាមួយអគ្គលេខាធិការ នៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ (OECD) ព្រមទាំងធុរជននៃក្រុមហ៊ុនឈានមុខមួយចំនួន ដើម្បីបង្ហាញពីសក្តានុពល និងបរិយាកាសធុរកិច្ចរបស់កម្ពុជាសំដៅទាក់ទាញវិនិយោគ និងធុរកិច្ច។

## ២.កិច្ចការពាណិជ្ជកម្មក្នុងប្រទេស

### ២.១.ការងារនីតិកម្ម

### ២.១.១.ការងារច្បាប់ពាណិជ្ជកម្ម

លិខិតបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានបង្កើតឡើង និងធ្វើវិសោធនកម្មឡើងវិញសំដៅទ្រទ្រង់ទាំងសកម្មភាពពាណិជ្ជកម្មក្នុងប្រទេស និងពាណិជ្ជកម្មអន្តរជាតិ។ ជាលទ្ធផលក្នុងឆ្នាំ២០២៤ សម្រេចបាន៖

❖ <u>ច្បាប់៖</u> ច្បាប់ស្តីពីនិរាករណ៍ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី

ការជំរុញនិងសម្រួលពាណិជ្ជកម្មតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម។

- **<u>អនុក្រឹត្យ និងសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលៈ</u>** (១)-អនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ (២)-អនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំឯកសារ សម្រាប់ការត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក (៣)-អនុក្រឹត្យលេខ៦៧, ៦៦, ៧១, ២៩, ៦៨, ៧៤, ៦៥, ៧៥, ៧០, ៧៣, ៧៦, ៧២, និង ៧៧ អនក្រ.បក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤ ស្ដីពីការបង្កើតសភាពាណិជ្ជកម្ម (ខេត្តកណ្ដាល, កែប, ក្រចេះ, កំពង់ចាម, កំពង់ឆ្នាំង, កំពង់ធំ, កំពត, ព្រះវិហារ, មណ្ឌលគិរី, រតនគិរី, សៀមរាប, ស្ទឹងត្រែង និងឧត្តរមានជ័យ) (៤)-អនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់(៥)-អនុក្រឹត្យលេខ៩២៥ អនក្រ.តត ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ ស្ដីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តបន្ទាយមានជ័យអាណត្តិទី៣ លើកទី១ (៦)-អនុក្រឹត្យលេខ១៩៤ អនក្រ.បក ចុះថ្ងៃទី២៧ សីហា ឆ្នាំ២០២៤ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិឧបាស្រ័យពាណិជ្ជកម្ម (៧)-អនុក្រឹត្យលេខ៧៨១ អនក្រ.តត ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តពោធិ៍សាត់ អាណត្តិទី៣ លើកទី១ (៨)-អនុក្រឹត្យលេខ ២៦១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលអនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ចកម្ពុជា-បេឡារុស (៩)-សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៦ សសរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិ ស្ដីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ (១០)-សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១១ សសរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្ដីពីការទទួលស្គាល់ប្រធាន និងសមាជិកការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជា ប្រចាំរដ្ឋកាលីហ្វ័រញ៉ា

សហរដ្ឋអាម៉េរិកអាណត្តិទី១លើកទី១(១១)-សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១០សសរ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់ប្រធាន និងសមាជិកការិយាល័យតំណាងសភាពាណិជ្ជកម្មកម្ពុជានៅទីក្រុងម៉ុងរ៉េអាល់ ខេត្តកេប៊ិច ប្រទេសកាណាដា អាណត្តិទី១ លើកទី១ (១២)-សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ២៣ សសរ ចុះនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំនិងចូលរួមពិព័រណ៍ពិភពលោក និងពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ (១៣)-សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាលេខ១៣៦ សសរ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញសមាសភាពនៃគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់។

- <u>ប្រកាស៖</u> (១)-ប្រកាសលេខ០៧០ ព.ណ គនព ប្រក ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការបង្កើតលេខាធិការដ្ឋានតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ (២)-ប្រកាសលេខ០៧៣ ព.ណ.អវង.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់ការិយាល័យប្រតិបត្តិនិងសមាជិកទីប្រឹក្សាសភាពាណិជ្ជកម្មខេត្តពោធិ៍សាត់អាណត្តិទី៣ លើកទី១ (៣)-ប្រកាសលេខ០៧៩ ព.ណ.នគក.ប្រក ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមប្រឹក្សានីតិកម្មនៃក្រសួងពាណិជ្ជកម្ម(៤)-ប្រកាសលេខ០៣៦ ព.ណ.អវង.ប្រក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការជំរុញនិងអភិវឌ្ឍន៍វិស័យសូត្រកម្ពុជា(៥)-ប្រកាសលេខ០៩៥ ព.ណ.អ.កបប.ប្រក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០២៤ ស្តីពីការអនុវត្តមិនសុចរិតក្នុងធុរកិច្ចពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្ម និងការជំរុញលក់
- <u>សេចក្តីសម្រេច៖</u> (១)-សេចក្តីសម្រេចលេខ០១៥ ព.ណ.គនព.សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសក្រសួងពាណិជ្ជកម្ម សម្រាប់តាមដានការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥(២)-សេចក្តីសម្រេចលេខ០១៦ ព.ណ.គនព.សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរស្ថាប័ន សម្រាប់ពិនិត្យ តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡូងមី ២០២០-២០២៥ (៣)-សេចក្តីសម្រេចលេខ ០១៨ ព.ណ.បល.សសរ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ស្តីពី

ការបង្កើតក្រុមប្រឹក្សាធុរកិច្ចនៃក្រសួងពាណិជ្ជកម្ម(៤)-សេចក្តីសម្រេចលេខ០២៦ ព.ណ.ផសព.សសរ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីរៀបចំបរិវត្តកម្មពាណិជ្ជកម្មឌីជីថល នៃក្រសួងពាណិជ្ជកម្ម (៥)-សេចក្តីសម្រេចលេខ០៨៧ ព.ណ.អ.កបប.សសរ ចុះថ្ងៃទី២ ខែមេសា ឆ្នាំ២០២៤ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការស្នើសុំការអនុញ្ញាតលើកលែងក្រោមច្បាប់ស្តីពីការប្រកួតប្រជែង (៦)-សេចក្តីសម្រេចលេខ ១០៧ ព.ណ.អ.កបប.សសរ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃគោលការណ៍អនុគ្រោះក្រោមច្បាប់ស្តីពីការប្រកួតប្រជែង (៧)-សេចក្តីសម្រេចលេខ១៤០ ព.ណ.កព.សសរ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបង្កើតក្រុមការងារជំរុញការនាំចេញ (៨)-សេចក្តីសម្រេចលេខ១៤៣ ព.ណ.សហអ.សសរ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការរៀបចំក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ (៩)-សេចក្តីសម្រេចលេខ១៥២ ព.ណ.គនព.សសរ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលសមាសភាពក្រុមការងារអន្តរស្ថាប័ន សម្រាប់ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡូងមី ២០២០-២០២៥។

❖ <u>សេចក្តីព្រាងច្បាប់ អនុក្រឹត្យ និងប្រកាសះ</u> (១)-សេចក្តីព្រាងច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម(២)-សេចក្តីព្រាងច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម(៣)-សេចក្តីព្រាងច្បាប់សភាពាណិជ្ជកម្មថ្មី (៤)-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា (៥)-សេចក្តីព្រាងអនុក្រឹត្យស្តីពីអនាម័យ នៃម្ហូបអាហារសម្រាប់មនុស្ស (៦)-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងទីផ្សារពហុកម្រិត (៧)-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកំណត់លក្ខខណ្ឌអប្បបរមាសម្រាប់ការលក់ទិញផលិតផលគ្រឿងស្រវឹង ក្នុងព្រះរាជាណាចក្រកម្ពុជា (៨)-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ១៣៣ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារក និងកុមារ (៩)-សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខខណ្ឌ បែបបទ និងនីតិវិធីក្នុងការតម្កល់ព័ត៌មាន និងកិច្ចសន្យាតំណាងម្ចាស់ភាគហ៊ុន (១០)-សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការវាយតម្លៃផ្តល់វិញ្ញាបនបត្រ នៃសញ្ញាទំនុកចិត្តចំពោះអ្នកប្រើប្រាស់ (១១)-សេចក្តីព្រាងប្រកាសស្តីពីសញ្ញាទំនុកចិត្ត

ចំពោះអ្នកប្រើប្រាស់ (១២)-សេចក្តីព្រាងប្រកាសស្តីពីលក្ខខណ្ឌតម្រូវសម្រាប់វាយតម្លៃផ្តល់វិញ្ញាបនបត្រ និងសញ្ញាទំនុកចិត្តចំពោះអ្នកប្រើប្រាស់ក្នុងវិស័យប្រេងឥន្ធនៈ ឬឧស្ម័នឥន្ធនៈ (១៣)-សេចក្តីព្រាងប្រកាសថ្មីស្តីពីការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១៤)-សេចក្តីព្រាងប្រកាសថ្មីស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (១៥)-សេចក្តីព្រាងប្រកាសថ្មីស្តីពីបែបបទ និងនីតិវិធីចុះក្នុងបញ្ជីពាណិជ្ជកម្មនូវរាល់ការផ្លាស់ប្តូរ និងកែប្រែរបស់សហគ្រាស ក្រុមហ៊ុនតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (១៦)-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីក្រមប្រតិបត្តិសម្រាប់អន្តរការី និងបុគ្គលផ្តល់សេវាពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (១៧)-សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ (១៨)-សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការគ្រប់គ្រងសមាគម និងសហព័ន្ធអាជីវកម្ម-ពាណិជ្ជកម្ម (១៩)-សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា រវាងក្រសួងពាណិជ្ជកម្ម និងអង្គភាពកម្មសិទ្ធិបញ្ញាហុងកុង (២០)-សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការសម្រួលការផ្ទេរបច្ចេកវិទ្យាសមស្រប រវាងក្រសួងពាណិជ្ជកម្ម និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក។

### ២.១.២.ការងារតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

- ទទួលតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា រួមមាន៖

| ល.រ | បរិយាយ | ១១ខែ ឆ្នាំ២០២៤ |
|---|---|---|
| ១ | តម្កល់លិខិតជូនដំណឹងដំបូងលើសិទ្ធិប្រាតិភោគ | ៣ ៧២២ |
| ២ | តម្កល់វិសោធនកម្មលើលិខិតជូនដំណឹង | ៥៩ |
| ៣ | តម្កល់លិខិតសុំបន្តសុពលភាព | ៦៤ |
| ៤ | តម្កល់លិខិតសុំកែតម្រូវ | ១៦ |
| ៥ | តម្កល់លិខិតសុំបញ្ចប់ | ៣ ០១៨ |
| ៦ | សេវារៀបចំរបាយការណ៍ស្រាវជ្រាវដែលមានការបញ្ជាក់ | ៩០ |
| សរុប | | ៦ ៩៦៩ |

- បានដោះស្រាយបញ្ហា ដើម្បីឆ្លើយតបទៅអ្នកប្រើប្រាស់ប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា និងបន្តសុពលភាពវិញ្ញាបនបត្រសម្រាប់ប្រើប្រាស់ប្រព័ន្ធតម្កល់លិខិតជូនដំណឹង នៃប្រតិបត្តិការដែលមានកិច្ចធានា (SSL Certificate)។

## ២.២.ការងារអភិវឌ្ឍន៍វិស័យឯកជន

### ២.២.១.ការងារពិនិត្យឃ្លាំមើលសកម្មភាពពាណិជ្ជកម្ម

- សេចក្តីជូនដំណឹងស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយរៀងរាល់១០ថ្ងៃម្តង ត្រូវបានផ្សព្វផ្សាយតាមគេហទំព័រផ្លូវការរបស់ក្រសួងពាណិជ្ជកម្ម ក្រសួងព័ត៌មាន និងកម្មវិធីផ្សព្វផ្សាយព័ត៌មានផ្សេងៗ បានចំនួន ២៧លើកព្រមទាំងបានដាក់ QR Code Verify ផ្ទៀងផ្ទាត់នៅលើសេចក្តីជូនដំណឹងដោយអាចស្កេនផ្ទៀងផ្ទាត់តាមរយៈ go.gov.kh របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ប្រមូល និងបូកសរុបរបាយការណ៍ និងចុះត្រួតពិនិត្យ និងវាយតម្លៃជាក់ស្តែងពីបរិមាណសន្និធិប្រេងឥន្ធនៈ និងហ្គាសរបស់ក្រុមហ៊ុននាំចូលប្រេង បានចំនួន ៨លើក ដើម្បីធានានិរន្តរភាពនៃការប្រើប្រាស់នៅលើទីផ្សារ
- ដើម្បីធានាឱ្យបានការធ្វើអន្តរាគមន៍ទាន់ពេលវេលា ឆ្លើយតបតម្រូវការទីផ្សារ និងការឡើង ឬចុះថ្លៃខ្លាំងពីតម្លៃគោល ក្រសួងបានរៀបចំរបាយការណ៍ស្តីពីថ្លៃទំនិញចំនួន ១១៩មុខ និង៣៨មុខពាក់ព័ន្ធនឹងជីវភាពប្រចាំថ្ងៃ
- សន្ទស្សន៍តម្លៃបោះដុំ-លក់រាយទំនិញប្រចាំជីវភាព២៤មុខ ក្នុងស្រុក និងនាំចូល ព្រមទាំងរៀបចំជាតារាងប្រៀបធៀបតម្លៃបោះដុំទំនិញនាំចូល ដើម្បីធ្វើការតាមដានព័ត៌មានប្រចាំថ្ងៃ
- រៀបចំបញ្ជីស្ថិតិផ្សារចំនួន១២ប្រភេទតាមបណ្តារាជធានី-ខេត្តដើម្បីគ្រប់គ្រងព័ត៌មានទីផ្សារ និងរៀបចំបោះពុម្ពសៀវភៅព័ត៌មានអំពីផ្សារ
- តាមដាន និងរាយការណ៍ជារៀងរាល់ ២ថ្ងៃម្តង អំពីតម្លៃស្វាយកែវរមៀតដែលទទួលបានចំនួន៣ប្រភពគឺ៖ ពីចម្ការ ពីឈ្មួញប្រមូលទិញនិងនៅលើទីផ្សារបរិមាណប្រមូលទិញរបស់ឈ្មួញប្រមូលទិញ និងទីផ្សារស្វាយកែវរមៀតក្នុង និងក្រៅប្រទេស។ ការរាយការណ៍បានបញ្ចប់ក្នុងខែកក្កដា (បញ្ចប់រដូវប្រមូលផល) ហើយជាលទ្ធផល ស្ថានភាពថ្លៃ និងការផ្គត់ផ្គង់មានស្ថិរភាព
- រាយការណ៍តម្លៃស្រូវសើមជាប្រចាំថ្ងៃ ក្នុងអំឡុងពេលប្រភពផ្គត់ផ្គង់អន្តរជាតិ

ផ្អាកការនាំចេញលើទីផ្សារអន្តរជាតិនិងដើម្បីក្តាប់ព័ត៌មានតម្លៃស្រូវសើមក្នុងស្រុក

- រៀបចំរបាយការណ៍គោរពជូនទៅ **សម្តេចមហាបវរធិបតី** ស្តីពីស្ថានភាពនៃការនាំចេញស្រូវទៅប្រទេសវៀតណាម តាមច្រករបៀងព្រៃវល្លិ៍ និងច្រករបៀងក្រសាំងជ្រំ នៅខេត្តស្វាយរៀង





















### ២.២.២.ការងារអភិវឌ្ឍន៍ស្ថាប័ន

- គិតត្រឹមឆ្នាំ២០២៤ ក្រសួងបានសម្របសម្រួលការចងក្រងសមាគមអាជីវកម្ម បានចំនួន ៤១សមាគមអាជីវកម្ម ដែលធ្វើធុរកិច្ចវិស័យកសិ-ពាណិជ្ជកម្ម លើមុខដំណាំដំឡូងមី ម្រេច ស្វាយចន្ទី សូត្រ ស្វាយ និងកសិផលផ្សេងៗ
- សហព័ន្ធដំឡូងមីកម្ពុជា ត្រូវបានបង្កើតនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤
- សមាគមលើកកម្ពស់ម្រេចកំពតលើកទី២ ត្រូវបានបង្កើតនៅថ្ងៃទី១ ខែមេសា ឆ្នាំ២០២៤
- គណៈកម្មការប្រតិបត្តិ នៃសមាគមអ្នកផលិតចម្លាក់ប្រាក់-ស្ពាន់ខេត្តកណ្ដាល ត្រូវបានបង្កើតនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤
- រៀបចំកិច្ចប្រជុំអាហារពេលព្រឹក ជាមួយសមាគមពាណិជ្ជកម្មនៅកម្ពុជា និងសមាគមពាណិជ្ជកម្មបរទេសបានចំនួន ៤លើក ក្នុងគោលបំណងក្ដាប់បានបញ្ហាប្រឈមរបស់ សមាគមពាណិជ្ជកម្មទាំងនោះទាក់ទងនឹងសិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់ម៉ាក ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ការទូទាត់កម្រៃសេវាសាធារណតាមប្រព័ន្ធបាគង KHQR ការធ្វើទំនើបកម្មប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា ការស្នើសុំអន្តរាគមន៍របស់សមាគមធនាគារ លើកិច្ចការពារអ្នកប្រើប្រាស់ ចំពោះបញ្ហានានាទាក់ទងនឹងការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក។







### ២.២.៣.ការងារអភិវឌ្ឍន៍ផលិតផល

- បានចុះស្រាវជ្រាវប្រមូលទិន្នន័យអំពីផលិតផលសូត្រនិងធ្វើបច្ចុប្បន្នភាពកីតម្បាញ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប មណ្ឌលគិរី និងខេត្តតាកែវ
- រៀបចំសិក្ខាសាលាពិភាក្សា និងពិគ្រោះយោបល់រវាងផលិតករ អាជីវករ និងភាគីពាក់ព័ន្ធក្នុងវិស័យសូត្រ ចំនួន២លើក
- រៀបចំយុទ្ធនាការជំរុញនិងប្រើប្រាស់ផលិតផលធ្វើពីសូត្រ ដោយមានសិប្បករ

ចូលរួមក្នុងកម្មវិធីចំនួន ១១សិប្បកម្ម មានលក់ស៊ីង អាវស៊ឹង កន្សែង សារ៉ុង កាបូប ខ្សែក សូត្រ ហូល ផាមួង និងក្រមាសូត្រ

- ផ្សព្វផ្សាយអំពីលក្ខខណ្ឌតម្រូវទីផ្សារទំនិញពោតក្រហម ដំឡូងមី កញ្ចុងអង្ករ និងកន្ទក់  ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌប្រមូលទិញរបស់ក្រុមហ៊ុនស៊ី.ភី ខេមបូឌា។

### ២.២.៤.ការងារអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាជាមួយវិស័យឯកជន




- អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនស៊ី.ភី.ខេមបូឌា ដើម្បីប្រមូលទិញពោតក្រហម ដំឡូងមី កញ្ចុងអង្ករ និងកន្ទក់ ជាលទ្ធផលអនុវត្តបាន៖ ពោតក្រហមចំនួន ៣៦៦ ៣៨៦តោន ដំឡូងមីចំនួន ១៣២ ៣៩៧តោន និងកន្ទក់ចំនួន ១១០ ៨៣៦តោន
- អនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ចំនួន៥ រវាងក្រុមហ៊ុនបន្លែ រួមមាន៖ CamAgri Lala CSDS ផ្សារកូនកាំបិត ផ្សារខ្មែរបន្លែធម្មជាតិ និងផ្សារស្នាដៃម៉ែ ជាលទ្ធផលក្រុមហ៊ុនទទួលទិញមាន់ចំនួន ៥ ២៨១គីឡូក្រាមស្មើនឹងទឹកប្រាក់ ៣០ ៤៧១ដុល្លារអាម៉េរិក និងផលិតផលបន្លែចំនួន ១៩៦ ៣១១គីឡូក្រាម ស្មើនឹងទឹកប្រាក់ ៩៨ ១០០ដុល្លារអាម៉េរិក។

## ២.៣.ការងារផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម

### ២.៣.១.ការងារបច្ចេកទេសព័ត៌មានវិទ្យា

- បានបន្តធ្វើបច្ចុប្បន្នភាព ជួសជុល ថែទាំ និងបង្កើតមុខងារប្រើប្រាស់ថ្មី៖
  - អភិវឌ្ឍន៍គេហទំព័រផ្លូវការក្រសួងពាណិជ្ជកម្ម
  - ប្រព័ន្ធគ្រប់គ្រងស្វ័យប្រវត្តកម្មរដ្ឋបាលទូទៅ
  - ប្រព័ន្ធវិភាគទិន្នន័យស្ថិតិ (SAS)
  - ពិនិត្យដំណើរការម៉ាស៊ីនមេ (Servers) ទាំងអស់នៅក្នុងមជ្ឈមណ្ឌលទិន្នន័យរបស់ក្រសួង
  - ដំឡើងម៉ាស៊ីនមេ (Servers) សម្រាប់ផ្ទុកប្រព័ន្ធផ្សេងៗរបស់ក្រសួង
  - ដោះស្រាយបញ្ហាបច្ចេកទេសប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មតាមថ្នាលCamDX

- ជួសជុលកុំព្យូទ័រ ម៉ាស៊ីនព្រីន និងSoftware ផ្សេងៗ។

### ២.៣.២.ការងារផែនការពាណិជ្ជកម្ម

- ផ្តល់ធាតុចូលលើសេចក្តីព្រាងក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ២០២៤-២០៣០ ដើម្បីអនុវត្តកម្មវិធីសកម្មភាពនៃសន្និសីទអន្តរជាតិស្តីពី ប្រជាជន និងអភិវឌ្ឍន៍
- ផ្តល់ធាតុចូលជូនធនាគារអភិវឌ្ឍន៍អាស៊ី ស្តីពីការអភិវឌ្ឍ National Spatial Data Infrastructure នៅកម្ពុជា ដើម្បីបង្កើតយន្តការថ្មីមួយទៀត ក្នុងការទទួលបានទិន្នន័យពាក់ព័ន្ធផ្សេងៗដូចជាៈ កំលាំងពលកម្ម មុខរបរ បរិមាណកសិផលដែលប្រមូលបាន និងបរិមាណផ្ទៃដីដាំដុះ ដើម្បីជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍវិស័យពាណិជ្ជកម្ម
- បញ្ចប់ការរៀបចំធាតុចូល សម្រាប់ផែនការសកម្មភាពវិស័យពាណិជ្ជកម្ម ដើម្បីគាំទ្រដល់ ការអនុវត្តវិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨
- ផ្តល់ធាតុចូល លើសេចក្តីព្រាងយុទ្ធសាស្ត្រ និងតារាងសូចនាករក្នុងវិស័យពាណិជ្ជកម្ម ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០២៤-២០២៨
- ផ្តល់ធាតុចូល និងតារាងសូចនាករសម្រាប់អនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១
- កសាងផែនការមេបច្ចេកវិទ្យាឌីជីថលក្នុងវិស័យពាណិជ្ជកម្ម ដោយសម្រេចបានសេចក្តីព្រាងបឋមសម្រាប់បន្តកិច្ចពិភាក្សា និងបញ្ចប់ការផ្តល់ធាតុចូលវិស័យពាណិជ្ជកម្ម ស្តីពីសកម្មភាពការងារសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ជូនគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល
- បង្កើនសមត្ថភាពបច្ចេកទេសស្តីពី វិធីសាស្ត្រចងក្រង និងប្រើប្រាស់កម្មវិធីថ្នាលទិន្នន័យសម្រាប់ចងក្រងសៀវភៅ កម្រងទិន្នន័យស្ថិតិកម្ពុជាប្រចាំឆ្នាំ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល។

### ២.៣.៣.ការងារសរុបស្ថិតិ ព្រឹត្តិបត្រ និងផ្សព្វផ្សាយព័ត៌មានពាណិជ្ជកម្ម

- ធ្វើបច្ចុប្បន្នភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ចាំបាច់សំខាន់ៗ លើទីផ្សារក្នុងប្រទេសទៅក្នុងគេហទំព័ររបស់ក្រសួង
- បញ្ចូលទិន្នន័យស្ថិតិពាណិជ្ជកម្មអន្តរជាតិ ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មស្ថិតិ ដើម្បី

ងាយស្រួលទាញយកព័ត៌មានស្ថិតិពាណិជ្ជកម្មអន្តរជាតិ

- បោះពុម្ពផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មចំនួន ១១លេខ ស្មើនឹង ៣ ៣០០ក្បាល។

## ២.៤.ការងារគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច (AIMS)




គម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច (AIMS) បានអនុវត្តអស់រយៈពេល ៨ឆ្នាំ សម្រាប់ដំណាក់កាលទី១ ក្នុងទឹកប្រាក់ ៣៩លានដុល្លារអាម៉េរិក ជាទុនកម្ចីរបស់ IFAD ហើយសម្រាប់ដំណាក់កាលទី២ ក្នុងទឹកប្រាក់ ២០លានដុល្លារអាម៉េរិក។ ការអនុវត្តគម្រោងក្នុងឆ្នាំ២០២៤ សម្រេចបាន៖

- សម្របសម្រួលការចុះកិច្ចសន្យាទិញ-លក់ បានចំនួន ២៨ ២៣៩គ្រួសារ ស្មើនឹងទឹកប្រាក់ ៣៨ ០៨៨ ៧៦៩ដុល្លារអាម៉េរិក
- មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) អនុវត្តបាន ៩៣ទីតាំង ស្មើនឹងទឹកប្រាក់ ២ ៤៨៩ ២៥០ដុល្លារអាម៉េរិក
- ហិរញ្ញប្បទានឥតសំណង (VCIF) ផ្តល់ជូនគ្រួសារក្រីក្រចំនួន ៧០៩គ្រួសារ ស្មើនឹងទឹកប្រាក់ ១ ០១១ ៥០០ ដុល្លារអាម៉េរិក។

## ២.៥.ការងារការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ

### ២.៥.១.ការងារពង្រឹងសមត្ថភាពទាក់ទងនឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្ត

បានពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលការយល់ដឹង និងនីតិវិធីនៃការអនុវត្តច្បាប់និងបទប្បញ្ញត្តិបានចំនួន ១៤វគ្គ មានមន្ត្រីចូលរួមសរុប ២ ០៦៥នាក់។

### ២.៥.២.ការងារបច្ចេកទេស

#### ២.៥.២.១.ការងារបច្ចេកទេសផលិតផលម្ហូបអាហារ និងមិនមែនម្ហូបអាហារ

- សិក្សាស្រាវជ្រាវ ប្រមូល និងចងក្រងឯកសារពាក់ព័ន្ធនឹងស្តង់ដាទំនិញ ទឹកឃ្មុំ និងអង្ករ ដើម្បីជាធាតុចូលសំអាង (Reference) សម្រាប់មន្ត្រីស៊ើបអង្កេតយកទៅអនុវត្តលើបទល្មើសដែលអាចកើតមានឡើង
- រៀបចំវិធានការបង្ការ ចំពោះផលិតផលម្ហូបអាហារដែលអាចមានហានិភ័យដល់អ្នកបរិភោគ និងផលិតផលមិនមែនម្ហូបអាហារមិនមានអនុលោមភាពតាមបទប្បញ្ញត្តិ និងប្រព័ន្ធសុវត្ថិភាពផ្សេងៗរបស់សហរដ្ឋអាម៉េរិក និងគណៈកម្មការអឺរ៉ុប ដោយធ្វើការសិក្សាស្រាវជ្រាវលើផលិតផលម្ហូបអាហារចំនួន ៤៣មុខ និងផលិតផលតាមការប្រកាសចំនួន ៨៣ប្រកាស ដែលផលិតផលមានហានិភ័យ និងមិនអនុលោមភាពទាំងនោះត្រូវបានរកឃើញ និងប្រមូលមកវិញពីទីផ្សារអន្តរជាតិ ហើយអាចនឹងត្រូវបាននាំចូលមកកាន់ទីផ្សារកម្ពុជា
- សិក្សា និងរៀបចំចងក្រងឯកសារពាក់ព័ន្ធនឹងផលិតផល «Genetically Modified Organisms-GMOs» សម្រាប់វាយតម្លៃ និងបង្កើតឯកសារគតិយុត្តក្នុងការអនុវត្តការគ្រប់គ្រងផលិតផល GMOs។

#### ២.៥.២.២.ការងារផ្តល់ចម្លើយការអនុវត្តវិធានសុវត្ថិភាពផលិតផលម្ហូបអាហារ

បានជូនដំណឹង ទៅក្រសួង ស្ថាប័ន និងវិស័យឯកជន ពីសេចក្តីជូនដំណឹងស្តីពីវិធានអនាម័យ និងភូតគាមអនាម័យ ដែលចេញផ្សាយដោយបណ្តាប្រទេសជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក បានចំនួន ២៨៨លើក។

### ២.៥.៣.ការងារកិច្ចការពារអ្នកប្រើប្រាស់

#### ២.៥.៣.១.ការងារស៊ើបអង្កេត

- ស៊ើបអង្កេត និងអនុវត្តវិធានការច្បាប់ចំពោះការរំលោភកម្មសិទ្ធិបញ្ញា និងបំពានសិទ្ធិផ្តាច់មុខចំនួន ២៥ករណី
- ស៊ើបអង្កេត និងអនុវត្តវិធានការច្បាប់ចំពោះក្រុមហ៊ុនចំនួន៦ ពាក់ព័ន្ធនឹងការអនុវត្តមិនសុចរិតក្នុងធុរកិច្ចយោងតាមបណ្តឹងរបស់បុគ្គលពាក់ព័ន្ធ។

#### ២.៥.៣.២.ការងារគ្រប់គ្រងការផ្សាយពាណិជ្ជកម្ម និងបង្ក្រាបការក្លែងបន្លំ

- ពិនិត្យ និងវិភាគខ្លឹមសារនៃអត្ថបទ និងរូបភាពផ្សាយពាណិជ្ជកម្មគ្រប់ទម្រង់

ចំនួន ៣១ស្លុត ក្នុងនោះបានរកឃើញ និងអនុវត្តវិធានការច្បាប់ចំពោះម្ចាស់ស្លុតចំនួន២២ ដែលមិនអនុលោមនឹងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ

- បានទទួលពាក្យស្នើសុំបញ្ជាក់អនុលោមភាព លើអត្ថបទ និងរូបភាពផ្សាយពាណិជ្ជកម្ម ចំនួន៤៣ ដែលក្នុងនោះបានផ្តល់លិខិតបញ្ជាក់អនុលោមភាពជូនក្រុមហ៊ុនចំនួន ៤១លិខិត និងបដិសេធចេញលិខិតបញ្ជាក់អនុលោមភាពចំនួន ២សំណើ ដោយក្រុមហ៊ុនមិនបំពេញតាមលក្ខខណ្ឌតម្រូវនៃច្បាប់
- កសាងសំណុំរឿងបញ្ជូនទៅតុលាការ ២ករណី ស្តីពីការមិនគោរពកាតព្វកិច្ចបង់ប្រាក់ពិន័យអន្តរការណ៍។

### ២.៥.៣.៣.ការងារដោះស្រាយបណ្តឹងអ្នកប្រើប្រាស់

- ពិនិត្យ និងដោះស្រាយបណ្តឹងចំនួន ១៧ និងបណ្តឹង ២ទៀតកំពុងពិនិត្យ និងដោះស្រាយបន្ត
- បង្កើតនីតិវិធីស្តង់ដាប្រតិបត្តិ (SOP) សម្រាប់អនុវត្តការដោះស្រាយបណ្តឹង។

### ២.៥.៣.៤.ការងារផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអ្នកប្រើប្រាស់

- ផលិតវីដេអូអប់រំអំពីសិទ្ធិរបស់អ្នកប្រើប្រាស់ កាតព្វកិច្ចរបស់ធុរជន និងសុវត្ថិភាពម្ហូបអាហារចំនួន ១៤វីដេអូ
- សម្របសម្រួល និងផ្តល់ប្រឹក្សាលើការបង្កើតសមាគមអ្នកប្រើប្រាស់ចំនួន ២៖ សមាគមអ្នកប្រើប្រាស់វិស័យសុវត្ថិភាពម្ហូបអាហារ និងសមាគមអ្នកប្រើប្រាស់វិស័យសុខាភិបាល។

### ២.៥.៣.៥.ការងារសហប្រតិបត្តិការកិច្ចការអ្នកប្រើប្រាស់

- សហការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ GIZ និង ACCC អនុវត្តគម្រោងពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីរៀបចំកសាងសេចក្តីព្រាងឯកសារគតិយុត្តរួមមាន៖ (១)-សេចក្តីព្រាងប្រកាសស្តីពីបែបបទ និងនីតិវិធីនៃការជូនដំណឹង របស់គណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ (២)-សេចក្តីព្រាងគោលការណ៍ណែនាំ GCC (Good Cooperate Code) ស្តីពីការដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ (ADR & ODR) ព្រមទាំងរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍នេះ
- ចូលរួមសន្និសីទ សិក្ខាសាលា កិច្ចប្រជុំ ដែលរៀបចំដោយគណៈកម្មាធិការ

ការពារអ្នកប្រើប្រាស់អាស៊ាន ACCP ចំនួន២៤លើក ដើម្បីពិនិត្យវឌ្ឍនភាពការងារពាក់ព័ន្ធនឹងកិច្ចការពារអ្នកប្រើប្រាស់របស់ប្រទេសជាសមាជិក។

**២.៥.៤.ការងារមន្ទីរពិសោធន៍**

**២.៥.៤.១.ការងារអភិវឌ្ឍគុណភាពមន្ទីរពិសោធន៍**

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងគុណភាពមន្ទីរពិសោធន៍៖ (១)-ទិន្នន័យរបស់មន្ទីរពិសោធន៍ CCF Lab_DMS (២)-ទិន្នន័យវិភាគសំណល់ថ្នាំកសិកម្ម Cabendazim (៣)-ទម្រង់គ្រប់គ្រងទិន្នន័យវិភាគអំបិលអ៊ីយ៉ូត (៤)-ទម្រង់គ្រប់គ្រងទិន្នន័យការវិភាគផលិតផលសាច់បង្កក (៥)-ទម្រង់ទិន្នន័យវិភាគមេតាណុលក្នុងផលិតផលម្ហូបអាហារនិងផលិតផលប្រើប្រាស់ (៦)-ដាក់ឱ្យប្រើប្រាស់ទម្រង់ស្នើសុំវិភាគសំណាកគំរូតាមប្រព័ន្ធអនឡាញ និងទម្រង់គ្រប់គ្រងបញ្ជីឧបករណ៍និងសម្ភារពិសោធន៍តាមប្រព័ន្ធអនឡាញ។

**២.៥.៤.២.ការងារកសាងវិធីសាស្ត្រវិភាគ**

- កសាងវិធីសាស្ត្រវិភាគតាមវិសាលភាព បានចំនួន ៤៥ ក្នុងនោះមាន៖ (១)-ផ្នែកគ្រប់គ្រងកិច្ចធានាគុណភាពមន្ទីរពិសោធន៍ចំនួន៧ (២)-ផ្នែកមីក្រូជីវសាស្ត្រចំនួន ១៤ (៣)-ផ្នែករូបសាស្ត្រ សមាសធាតុផ្សំ និងអាហារូបត្ថម្ភចំនួន ៣ (៤)-ផ្នែកសារធាតុគីមីបន្ថែមក្នុងម្ហូបអាហារចំនួន ១១ (៥)-ផ្នែកសារធាតុគីមីចម្លង និងសំណល់គីមីក្នុងម្ហូបអាហារចំនួន ៨ និង (៦)-ផ្នែកប្រេងឥន្ធនៈនិងផលិតផលប្រើប្រាស់ចំនួន ២
- បញ្ចប់ និងផ្តល់សុពលភាពលើនិតិវិធីប្រតិបត្តិស្តង់ដាចំនួន ២២ រួមមាន៖ (១)-ផ្នែកមីក្រូជីវសាស្ត្រចំនួន ២ (២)-ផ្នែករូបសាស្ត្រ សមាសធាតុផ្សំនិងអាហារូបត្ថម្ភចំនួន ៣ (៣)-ផ្នែកសារធាតុគីមីបន្ថែមក្នុងម្ហូបអាហារ ចំនួន ៤ (៤)-ផ្នែកសារធាតុគីមីចម្លងនិងសំណល់គីមីក្នុងម្ហូបអាហារចំនួន ៦ និង (៥)-ផ្នែកប្រេងឥន្ធនៈនិងផលិតផលប្រើប្រាស់ ចំនួន ៧។

**២.៥.៤.៣.ការងារវិភាគគុណភាពទំនិញ**

- បានទទួលសំណាកគំរូយកមកវិភាគចំនួន ១ ៦៦៣គំរូ និងបានរកឃើញសំណាកគំរូចំនួន ១០២មិនអនុលោមតាមបញ្ញត្តិបច្ចេកទេស
- ផ្តល់វិញ្ញាបនបត្រវិភាគជូនអតិថិជនចំនួន ៦៥៩ និងលទ្ធផលវិភាគផ្ទៃក្នុងចំនួន ៣៧២វិញ្ញាបនបត្រ។

២.៥.៤.៤.ការងារធ្វើតេស្តសមត្ថភាពជាមួយមន្ទីរពិសោធន៍នៃបណ្តាប្រទេស

- បានចូលរួមកម្មវិធី Proficiency Testing Program ដែលរៀបចំដោយ មន្ទីរពិសោធន៍នៃបណ្តាប្រទេសចំនួន ៥លើក លើប៉ារ៉ាម៉ែត្រចំនួន ៨ ហើយ ទទួលបានលទ្ធផលជោគជ័យចំនួន ៥ប៉ារ៉ាម៉ែត្រ ពិនិត្យឡើងវិញ ១ប៉ារ៉ាម៉ែត្រ និងលទ្ធផលមិនពេញចិត្ត ២ប៉ារ៉ាម៉ែត្រ។

២.៥.៤.៥.ការងារបណ្តុះបណ្តាលជំនាញវិភាគ

- រៀបចំបណ្តុះបណ្តាលជំនាញបច្ចេកទេស នៃការប្រើប្រាស់ឧបករណ៍ និង វិធីសាស្រ្តនៃការធ្វើតេស្តបឋមតាមប៉ារ៉ាម៉ែត្រចំនួន ១៨លើក
- ចាត់បញ្ជូនមន្ត្រីជំនាញមន្ទីរពិសោធន៍ទៅបណ្តុះបណ្តាលជំនាញ និងដកស្រង់ បទពិសោធន៍ នៅក្រៅប្រទេសចំនួន ៩លើក
- បានទទួលនិស្សិតធ្វើកម្មសិក្សានៅមន្ទីរពិសោធន៍ចំនួន ៩៨នាក់។

២.៥.៥.ការងារកិច្ចការប្រកួតប្រជែង

២.៥.៥.១.ការងារទទួលពាក្យបណ្តឹង និងការស៊ើបអង្កេត

- ទទួលពាក្យស្នើសុំជូនដំណឹងពីការរួមបញ្ចូលគ្នានៃធុរកិច្ចចំនួន ៩ករណី
- បានបញ្ចប់ ៧ករណី និងកំពុងត្រួតពិនិត្យ ២ករណី និងបានផ្តល់វិញ្ញាបនបត្រ ជាមុនពីការរួមបញ្ចូលគ្នានៃធុរកិច្ច ៣ករណី
- ផ្តល់ការប្រឹក្សាយោបល់ដល់ការិយាល័យមេធាវី និងក្រុមហ៊ុន សហគ្រាស ពាក់ព័ន្ធនឹងការរួមបញ្ចូលគ្នានៃធុរកិច្ចចំនួន ៣១លើក។

២.៥.៥.២.ការងារទំនាក់ទំនងអន្តរជាតិ

- កិច្ចប្រជុំចរចាកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការប្រកួតប្រជែងចំនួន ១២លើក ដែលមានសរុបចំនួន ១២មាត្រា។ បច្ចុប្បន្នកិច្ចព្រមព្រៀងនេះ កំពុងស្ថិតក្នុងដំណាក់កាលសម្អាតអត្ថបទដោយបណ្តារដ្ឋសមាជិកអាស៊ាន
- បញ្ចប់សេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មាធិការ ប្រកួតប្រជែងកម្ពុជា «គ.ប.ក.» និងគណៈកម្មាធិការប្រកួតប្រជែងហ្វីលីពីន (PCC) និងកំពុងបន្តនីតិវិធី ដើម្បីចុះហត្ថលេខាជាផ្លូវការ។

២.៥.៦.ការងារកិច្ចការហាឡាល

២.៥.៦.១.ការងារចុះបញ្ជី និងវិញ្ញាបនបត្រកម្ម

- ទទួលពាក្យស្នើសុំវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដាផលិតផលហាឡាល

កម្ពុជា ៨៩ច្បាប់ និងចេញវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសស្តង់ដាផលិតផលហាឡាលកម្ពុជា ៧៦ច្បាប់

- ចុះត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈបច្ចេកទេសស្តង់ដាផលិតផលហាឡាលកម្ពុជា ៧៧លើក

**២.៥.៦.២.ការងារលើកកម្ពស់ការយល់ដឹង និងការស៊ើបអង្កេតផលិតផលនិងសេវា**

- ផ្សព្វផ្សាយបញ្ញាបចំណេះដឹងផ្នែកកិច្ចការហាឡាល ដល់បណ្តាគ្រឹះស្ថានអប់រំ និងអាជីវករលក់ដូរក្នុង រាជធានី-ខេត្ត ចំនួន ១១២លើក ដែលមានអ្នកចូលរួមចំនួន ៥៦ ៦៧៣នាក់
- ស្រាវជ្រាវ និងចាត់វិធានការចំពោះភាពមិនអនុលោមនៃការប្រើប្រាស់ស្លាកសញ្ញាហាឡាលនៅតាមបណ្តាភោជនីយដ្ឋាន ក្រុមហ៊ុន និងសិប្បកម្មចំនួន ១១ទីតាំង ក្នុងនោះបានអប់រំ ណែនាំ និងធ្វើកិច្ចសន្យាបញ្ឈប់ការប្រើប្រាស់ស្លាកសញ្ញាហាឡាលដោយមិនមានវិញ្ញាបនបត្រចំនួន ៨ទីតាំង
- បន្តរៀបចំសម្រង់ករណី (Profiling) លើការប្រើប្រាស់ស្លាកសញ្ញាហាឡាលមិនប្រក្រតី ចំនួន ៦ករណី។

**២.៥.៧.ការងារពាក់ព័ន្ធនឹងការអនុវត្ត និងផ្សព្វផ្សាយច្បាប់**

**២.៥.៧.១.ការងារអនុវត្តច្បាប់**

- ឃ្លាំពិនិត្យទីផ្សារបាន ៥១៨លើក រកឃើញ និងដកហូតទំនិញមិនមានអនុលោមភាព ២៣តោន និង២៣៣គីឡូក្រាម មកកម្ទេចចោល
- ត្រួតពិនិត្យគុណភាព និងបរិមាណរង្វាស់រង្វាល់ប្រេងឥន្ធនៈ បានចំនួន ៥៥ស្ថានីយ/ដេប៉ូ រកឃើញដេប៉ូចំនួន ១៨ បានប្រកបអាជីវកម្មមិនសុចរិតផ្នែកបរិមាណ និងគុណភាព
- ឃ្លាំពិនិត្យថ្លៃលក់រាយប្រេងឥន្ធនៈបានចំនួន ១៨ ៧០០ ស្ថានីយ/ដេប៉ូ ដោយពុំបានរកឃើញ ករណីណាមួយលក់ខុសថ្លៃតាមសេចក្តីជូនដំណឹង
- ត្រួតពិនិត្យផលិតផលសាច់បង្កកនិងផលិតផលមានដើមកំណើតពីសាច់សត្វ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច នៅតាមទីតាំងស្តុកចែកចាយផលិតផលសាច់បាន ១៨ទីតាំង តាមមធ្យោបាយដឹកជញ្ជូន ៦ករណី រកឃើញ និងដកហូតសាច់បង្កក គ្រឿងសមុទ្រគ្រប់ប្រភេទ

និងស៊ុតមាន់ ដែលខូចគុណភាព មានសារធាតុគីមី និងចម្លងមេរោគ ចំនួន ២២៩តោន មកកម្ទេចចោល។

### ២.៥.៧.២.ការងារវិភាគតាមមន្ទីរពិសោធន៍ខ្នាតតូច និងរថយន្តពិសោធន៍ចល័ត

- មន្ទីរពិសោធន៍ខ្នាតតូចតាមបណ្តាសាខា ក.ប.ប. បានដំណើរការវិភាគបឋម លើគំរូសំណាកផលិតផល ចំនួន៧៥៣ រកឃើញផលិតផលចំនួន១១គំរូ មិនអនុលោមតាមបញ្ញត្តិបច្ចេកទេស និងបានបញ្ជូនគំរូផលិតផលទាំងនោះ មកវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួង ដើម្បីផ្ទៀងផ្ទាត់លទ្ធផល
- រថយន្តពិសោធន៍ចល័តផ្នែកម្ហូបអាហារ នៃសាខា ក.ប.ប. បានវិភាគបឋម លើគំរូផលិតផលនៅតាមបណ្តាផ្សារនានានៅទូទាំងប្រទេស បានចំនួន ១១៥លើក ដោយបានវិភាគបឋម លើគំរូផលិតផលចំនួន ៦២៩ និងរកឃើញ ផលិតផលចំនួន ២៣គំរូ មិនអនុលោមតាមបញ្ញត្តិបច្ចេកទេសនិងបានបញ្ជូន មកវិភាគនៅមន្ទីរពិសោធន៍របស់ក្រសួង ដើម្បីផ្ទៀងផ្ទាត់លទ្ធផល។

### ២.៥.៧.៣.ការងារផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិ



- ផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ ស្តីពីសុវត្ថិភាពម្ហូបអាហារនៅតាម បណ្តាគ្រឹះស្ថានសិក្សា ក្នុងរាជធានី ខេត្តបានចំនួន ១៨៣លើក ដែល មានអ្នកចូលរួមសរុបប្រមាណចំនួន ១០៦ ៦៣នាក់
- ផ្សព្វផ្សាយការយល់ដឹងអំពីច្បាប់ និងបទប្បញ្ញត្តិនានាដល់អាជីវករ តាមបណ្តាទីផ្សារចំនួន៤២៦លើកដែលមានអ្នកចូលរួមចំនួន៥៦ ៨២៤នាក់
- បិទផ្ទាំងរូបភាពផ្សព្វផ្សាយការយល់ដឹងនៅតាមបណ្តាទីផ្សារ ទីតាំងអាជីវកម្ម និងទីកន្លែងសាធារណៈ ពីការយល់ដឹងពីរបៀបពិនិត្យស្លាកសញ្ញាផលិតផល ម្ហូបអាហារមានសុវត្ថិភាព បានចំនួន ២៦ ៤៤២ផ្ទាំង ការយល់ដឹងពីអំពើ មិនសុចរិតក្នុងធុរកិច្ច ពាក់ព័ន្ធនឹងវិស័យប្រេងឥន្ទនៈបានចំនួន ២ ១០១ផ្ទាំង ការយល់ដឹងអំពីការវិភាគរកសារធាតុអាសបេស្តុសបានចំនួន ១ ១៧៧ផ្ទាំង។

### ២.៦.ការងារអាជីវកម្មស្រូវ-អង្ករ និងសន្និធិស្បៀងបម្រុងរដ្ឋ (ក្រុមហ៊ុនគ្រីនត្រេដ)

#### ២.៦.១.ប្រតិបត្តិការហិរញ្ញវត្ថុ

ប្រតិបត្តិការហិរញ្ញវត្ថុរយៈពេល ១១ខែ ក្នុងឆ្នាំ២០២៤ ៖

- ចំណូលចំនួន ៨៥ ៦៧១ ៩៥៨ ៧៦៥រៀល
- ចំណាយចំនួន ៨២ ៣២២ ១៥០ ៤៨៧រៀល
- ចំណេញចំនួន ៣ ៣៤៩ ៨០៨ ២៧៨រៀល

ធៀបផែនការឆ្នាំ២០២៤ កើន **១៦៦,៤%** ស្មើនឹង១ ៣៣៦ ៧១៦ ៣៧៣រៀល។

#### ២.៦.២.ការងារអាជីវកម្មស្រូវ-អង្ករ

❖ **ការធ្វើអាជីវកម្មស្រូវ-អង្ករទៅទីផ្សារអន្តរជាតិ**

- អបអរសាទរអង្ករក្រអូបប្រណិតកម្ពុជា ម៉ាក «ម្លិះអង្ករ» ពូជស្រូវផ្ការំដួល ដែលបានឈ្នះពានរង្វាន់អង្ករល្អប្រណិតផ្តាច់គេលើពិភពលោក ជាលើកទី៦ ក្នុងការប្រកួតអង្ករល្អផ្តាច់គេលើពិភពលោក ក្នុងកម្មវិធី «សន្និសីទស្រូវអង្ករពិភពលោកឆ្នាំ២០២៤» (World Best Rice) ប្រទេសហ្វីលីពីន
- អង្ករម៉ាកសម្ទូហាភាព SKO ពូជសែនក្រអូប០១ បានឈ្នះពានរង្វាន់មាស
- នៅក្នុងកម្មវិធីវាយតម្លៃគុណភាពរសជាតិ ចិន-អាស៊ានលើកទី២ (Gold award for the 2nd China-ASEAN Taste Quality Appraisal Activity of High-Quality Indica Rice Varieties) ដែលរៀបចំដោយវិទ្យាស្ថានវិទ្យាសាស្ត្រស្រូវនៃបណ្ឌិតសភាវិទ្យាសាស្ត្រខេត្ត Guangxi និងមណ្ឌលការគ្រប់គ្រងគ្រាប់ពូជនៃតំបន់ស្វយ័ត Guangxi នៃសាធារណរដ្ឋប្រជាមានិតចិន
- ក្នុង១១ខែ ឆ្នាំ២០២៤ កម្ពុជាបាននាំចេញអង្ករចំនួន ៥៨៧ ០១៨តោន និងស្រូវចំនួន ៤ ៥៣១ ៩៣៤តោន ទៅកាន់ទិសដៅទីផ្សារ ៨៧ប្រទេស។ ការនាំចេញស្រូវ-អង្ករក្នុងឆ្នាំនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងនោះទឹកប្រាក់បានពីការនាំចេញស្រូវមានចំនួន ១ ២៧១,៩៧លានដុល្លារអាម៉េរិក និងអង្ករមានចំនួន ៤៣៨,៥២លានដុល្លារអាម៉េរិក
- ក្រុមហ៊ុនគ្រីនត្រេដ បាននាំចេញអង្ករចំនួន ២៩ ៥០០តោន ទៅកាន់ទីផ្សារអន្តរជាតិ រួមមាន៖
  - សាធារណរដ្ឋប្រជាមានិតចិន ចំនួន ៣ ០០០តោន
  - ប្រទេសទីម័រខាងកើត ចំនួន ៤ ០០០តោន

- ប្រទេសឥណ្ឌូណេស៊ី ចំនួន ២២ ៥០០តោន

ធៀបនឹងផែនការឆ្នាំ២០២៤ ការនាំចេញកើនឡើង ៥១៩%។

❖ **ការធ្វើអាជីវកម្មអង្ករក្នុងស្រុក**

- ក្នុងរយៈពេល ១១ខែ ឆ្នាំ២០២៤ ក្រុមហ៊ុនបានធ្វើអាជីវកម្មអង្ករក្នុងស្រុក បានសរុបចំនួន ២១តោន ក្នុងនោះរួមមាន៖ អង្ករផ្កាម្លិះ ចំនួន ១២តោន និងអង្ករផ្កាខ្ញី ចំនួន ៩តោន។

**២.៦.៣.សន្និធិស្បៀងបម្រុងរដ្ឋ**

អនុវត្តតាមអនុក្រឹត្យលេខ១២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការបង្កើតប្រព័ន្ធស្បៀងបម្រុងកម្ពុជា «ប.ស.ប.ក» ក្រុមហ៊ុនហ្គ្រីនត្រេដបានគ្រប់គ្រងសន្និធិស្បៀងបម្រុងរដ្ឋរួមមាន៖ **អង្ករ ៣៣ន់តោន មី ២ម៉ឺនកេស ទឹកសុទ្ធ ១០ម៉ឺនកេស ទឹកត្រី ២៥៣ន់យួរ ទឹកស៊ីអ៊ីវ ២៥៣ន់យួរ និងត្រីខកំប៉ុង ៥៤ ០៣១យួរ**។ គណៈកម្មការគ្រប់គ្រងស្បៀងបម្រុង នៃក្រុមហ៊ុនហ្គ្រីនត្រេដតែងតែចុះត្រួតពិនិត្យសន្និធិស្បៀងត្រៀមបម្រុងរបស់រាជរដ្ឋាភិបាល នៅតាមបណ្តាក្រុមហ៊ុន សហគ្រាស ដែលជាដៃគូផ្គត់ផ្គង់ជាប្រចាំ ដើម្បីតាមដាន និងធានាឱ្យបាននូវបរិមាណសន្និធិស្របតាមកិច្ចសន្យាដែលត្រូវអនុវត្ត ដើម្បីបំពេញរាល់តម្រូវការរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចេញសន្និធិឱ្យទទួលលទ្ធផលវិជ្ជមាន បរិមាណគ្រប់គ្រាន់ និងដឹកជញ្ជូនដល់ទីតាំងទាន់ពេលវេលា។ ក្នុងរយៈពេល ១១ខែ កន្លងមកនេះក្រុមហ៊ុនបានបញ្ចេញសន្និធិស្បៀងតាមការណែនាំរបស់រាជរដ្ឋាភិបាល និងគណៈកម្មការគ្រប់គ្រងស្បៀងបម្រុងកម្ពុជា រួមមាន៖

- ជូនប្រជាពលរដ្ឋដែលរងគ្រោះ និងមានជីវភាពខ្វះខាតចំនួន ៣៥០គ្រួសារ ក្នុងនោះក្រុមហ៊ុនបានបញ្ចេញសន្និធិស្បៀងមានចំនួន៖ មី ៣៥០កេស ទឹកសុទ្ធ ៣៥០កេស ទឹកត្រី-ទឹកស៊ីអ៊ីវក្នុងមួយមុខ ៣៥០យួរ ត្រីខកំប៉ុង ៣៥០យួរ និងអង្ករ ៨ ៧៥០គីឡូក្រាម
- បានបញ្ចេញសន្និធិអង្ករត្រៀមបម្រុងកម្ពុជាចំនួន ១១៧ តោន ដើម្បីប្រគេនព្រះសង្ឃតាមបណ្តាវត្តអារាម ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌចំនួន ៣៨៧វត្ត
- បានបញ្ចេញសន្និធិអង្ករត្រៀមបម្រុងកម្ពុជា ១៧,៦តោន ត្រីខ ៧០៤យួរ មី ៧០៤កេស ទឹកសុទ្ធ ៧០៤កេស ទឹកត្រី ៧០៤យួរ ទឹកស៊ីអ៊ីវ ៧០៤យួរ ជូនគណៈកម្មាធិការគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងកម្ពុជា (ប.ស.ប.ក.) ដើម្បីផ្តល់ជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

- សហការជាមួយកម្មវិធីស្បៀងអាហារពិភពលោក «WFP» ក្នុងការលាយបញ្ចូលមីក្រូសារជាតិទៅក្នុងអង្ករ បានចំនួន ៧៣០,៥៥០គីឡូក្រាម។

### ២.៦.៤.ការជំរុញពាណិជ្ជកម្មអង្ករ និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា

- ចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការធ្វើពាណិជ្ជកម្មអង្កររវាងក្រុមហ៊ុនគ្រឿនត្រេដនៃក្រសួងពាណិជ្ជកម្ម និងក្រុមហ៊ុនសាជីវកម្ម COFCO Corporation ក្នុងបរិមាណ ៥០ម៉ឺនតោន
- ជំរុញការចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការធ្វើអាជីវកម្មអង្ករកម្ពុជាជាមួយប្រទេសដៃគូដូចជា៖ ឥណ្ឌូណេស៊ី ហ្វីលីពីន និងសិង្ហបុរី
- ក្រុមការងារចម្រុះក្នុងការសម្របសម្រួលខ្សែច្រវាក់តម្លៃផលិតផលកសិកម្ម និងស្ថានភាពទូទៅនៃសុវត្ថិភាពស្បៀងនិងការនាំចេញអង្ករ ក្នុងឆ្នាំ២០២៤ បានផ្តល់ឥណទានបានផ្តល់ជូនដល់ក្រុមហ៊ុននាំចេញអង្ករ និងរោងម៉ាស៊ីនកិនស្រូវ ចំនួន១៦ គិតជាថវិកាសរុប ២៨ ៥៥០ ០០០ដុល្លារអាមេរិក ដែលមានសន្និធិស្រូវមានចំនួន ៦៥ ២៧៤តោន និងសន្និធិអង្ករមានចំនួន ២៣ ៦៦៧តោន។

## ៣.កិច្ចការសេវាពាណិជ្ជកម្ម

### ៣.១.ការងារចុះបញ្ជីពាណិជ្ជកម្ម

ការចុះបញ្ជីពាណិជ្ជកម្មសម្រេចបានចំនួន៩៥៣០ក្រុមហ៊ុន/សហគ្រាសថយចុះចំនួន -១៧,១៧% ក្នុងនោះ៖ ក្រុមហ៊ុនមូលធន ចំនួន ៤៧២៥ កើនឡើង ៨% ក្រុមហ៊ុនពាណិជ្ជកម្មបរទេសចំនួន ៥៤ ថយចុះ -១៦,៩២% សហគ្រាសឯកបុគ្គលចំនួន ៤៧៥០ ថយចុះ -៣២,៧៧% និងក្រុមហ៊ុនសហកម្មសិទ្ធិ ចំនួន ១ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | យថាប្រភេទ | ប្រៀបធៀប | | |
|---|---|---|---|---|
| | | ១១ខែ ២០២៣ | ១១ខែ ២០២៤ | % |
| ក) ការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម | | | | |
| ១ | ក្រុមហ៊ុនមូលធន | 4,375 | 4,725 | 8%▲ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 65 | 54 | -16.92%▼ |
| ៣ | សហគ្រាសឯកបុគ្គល | 7,066 | 4,750 | -32.77%▼ |
| ៤ | ក្រុមហ៊ុនសហកម្មសិទ្ធិ | - | 1 | - |
| **សរុបការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម** | | **11,506** | **9,530** | **-17.17%▼** |

| ល.រ | យថាប្រភេទ | ប្រៀបធៀប | | |
|---|---|---|---|---|
| | | ១១ខែ ២០២៣ | ១១ខែ ២០២៤ | % |
| ខ) ការស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | | | | |
| ១ | ក្រុមហ៊ុនមូលធន | 836 | 1,062 | 27.03%▲ |
| ២ | ក្រុមហ៊ុនពាណិជ្ជកម្មបរទេស | 24 | 31 | 29.16%▲ |
| ៣ | សហគ្រាសឯកបុគ្គល | 107 | 191 | 78.50%▲ |
| ៤ | ក្រុមហ៊ុនសហកម្មសិទ្ធិ | - | - | - |
| **សរុបការស្នើសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម** | | **967** | **1,284** | **32.78%▲** |
| គ) ការស្នើសុំចុះបញ្ជីកែប្រែ | | | | |
| ១ | ផ្លាស់ប្តូរភាគហ៊ុន បន្ថយដើមទុន បង្កើនដើមទុន | 2,189 | 2,195 | 0.27%▲ |
| ២ | ផ្សេងៗ (អភិបាល កម្មវត្ថុអាជីវកម្ម នាមករណ៍...) | 10,304 | 10,117 | -1.81%▼ |
| ៣ | បង្កើតសាខាក្រុមហ៊ុនក្នុងស្រុក | 780 | 438 | -43.84%▼ |
| ៤ | សហគ្រាសឯកបុគ្គល | 492 | 646 | 31.30%▲ |
| ឃ) ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 71 | 21 | -70.42%▼ |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | 11 | 6 | -45.45%▼ |
| ៣ | អាជ្ញាបណ្ណ | 32 | 33 | 3.12%▲ |
| ង) ការបន្តសុពលភាពលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | - | - | - |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | - | - | - |
| ៣ | អាជ្ញាបណ្ណ | - | - | - |
| ច) ការកែប្រែលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | ការកែប្រែលិខិតអនុញ្ញាត | - | - | - |
| ២ | ការកែប្រែអាជ្ញាបណ្ណ | - | - | - |
| ឆ) ការផ្អាក ឬបិទអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក | | | | |
| ១ | លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | 9 | 3 | -66.66%▼ |
| ២ | លិខិតអនុញ្ញាតសម្រាប់សហគ្រាសឯកបុគ្គល | - | - | - |
| ៣ | អាជ្ញាបណ្ណ | - | 1 | - |
| **ជ) ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ** | | **24,244** | **24,347** | **0.42%▲** |
| **ឈ) ការថតចម្លងឯកសារចុះបញ្ជីពាណិជ្ជកម្ម** | | **-** | **-** | **-** |
| **ញ) ទទួលពាក្យស្នើអនុវត្តដីការក្សាការពារនិងដោះស្រាយវិវាទ** | | **-** | **-** | **-** |

| ល.រ | យថាប្រភេទ | ប្រៀបធៀប | | |
|---|---|---|---|---|
| | | ១១ខែ ២០២៣ | ១១ខែ ២០២៤ | % |
| **ង) ការស្នើសុំបម្រុងទុកនាមករណ៍** | | | | |
| ១ | ការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | 5,917 | 6,532 | 10.39%▲ |
| ២ | ពន្យារការបម្រុងទុកនាមករណ៍ក្រុមហ៊ុនមូលធន | 183 | 157 | -14.20%▼ |
| ៣ | ការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | 7,945 | 5,321 | -33.02%▼ |
| ៤ | ពន្យារការបម្រុងទុកនាមករណ៍សហគ្រាសឯកបុគ្គល | 170 | 89 | -47.64%▼ |
| **ច) ការពិន័យ** | | | | |
| ១ | យឺតយ៉ាវក្នុងការបំពេញបែបបទស្នើសុំផ្លាស់ប្តូរកែប្រែផ្សេងៗ | 67 | 211 | 214.9%▲ |
| ២ | មិនតម្កល់ទុកប្រតិវេទន៍ប្រចាំឆ្នាំ | 940 | 2,038 | 116.8%▲ |
| ៣ | ផ្តល់ព័ត៌មានមិនពិត និងឯកសារមិនត្រឹមត្រូវសម្រាប់ចុះបញ្ជី | - | - | - |
| ៤ | ធ្វើអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ដោយគ្មានការអនុញ្ញាត | 1 | 0 | - |
| ៥ | ផ្តល់ព័ត៌មានមិនពិត ឬឯកសារផ្សេងៗដែលត្រូវតម្កល់ទុក | - | - | - |
| ៦ | មិនបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុថតចម្លង | - | - | - |


















### ៣.១.១.ការងារធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តកម្មចុះបញ្ជីពាណិជ្ជកម្ម

- បានបង្កើតប្រព័ន្ធចុះបញ្ជីកែប្រែថ្មី ដោយបានតភ្ជាប់ជាមួយថ្នាល CamDX ដែលមានមុខងារសម្រាប់ចុះបញ្ជីកែប្រែចំនួន ១០មុខងារ៖ (១)-ការស្នើសុំកែប្រែផ្លាស់ប្តូរអាសយដ្ឋានរបស់ក្រុមហ៊ុន ឬសហគ្រាស (២)-ការស្នើសុំកែប្រែសកម្មភាពអាជីវកម្ម (៣)-ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន (៤)-ការតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន (៥)-មុខងារការកែប្រែនាមករណ៍ក្រុមហ៊ុនសហគ្រាស (៦)-ការកែប្រែព័ត៌មានលម្អិតអភិបាល (៧)-ការកែប្រែព័ត៌មានលម្អិតម្ចាស់សហគ្រាស (៨)-ការកែប្រែព័ត៌មានលម្អិតម្ចាស់ភាគហ៊ុន (៩)-ការកែប្រែសមាសភាពអ្នកគ្រប់គ្រងសាខា ឬការិយាល័យតំណាងក្រុមហ៊ុនបរទេស (១០)-ការបញ្ឈប់អាជីវកម្មជាស្ថាពរសម្រាប់ការលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម ដោយអាចបង់កម្រៃសេវាតាមរយៈប្រព័ន្ធធនាគារ អេប៊ីអេ អេស៊ីលីដា កាណាឌីយ៉ា និងKHQR

- ប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្ម របស់ក្រសួងពាណិជ្ជកម្ម (អភិវឌ្ឍន៍ដោយ Foster Moore) បានធ្វើការអភិវឌ្ឍមុខងារទូទាត់កម្រៃសេវាតាមរយៈ KHQR បន្ថែមពីលើការទូទាត់តាមលេខគណនីធនាគារ
- បានដាក់ QR Code ស្តង់ដា ដែលអាចផ្ទៀងផ្ទាត់បានតាម «ថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.go.kh» នៅលើវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម។

### ៣.១.២.ការងារតាមដាន និងវាយតម្លៃហានិភ័យ

បានប្រមូលធាតុចូលរៀបចំរបាយការណ៍និងធ្វើបច្ចុប្បន្នភាពចម្លើយពីស្ថាប័នគាំទ្រលើកម្រងសំណួររបស់វិស័យទី១៣ នៃអនុគណៈកម្មាធិការវាយតម្លៃហានិភ័យថ្នាក់ជាតិស្តីពីការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

## ៣.២.ការងារកម្មសិទ្ធិបញ្ញា

### ៣.២.១.ការងារចុះបញ្ជីម៉ាកតាមប្រព័ន្ធជាតិ និងប្រព័ន្ធអន្តរជាតិ

ក្នុងរយៈពេល១១ខែ ឆ្នាំ២០២៤ ក្រសួងពាណិជ្ជកម្មបានទទួលការដាក់ពាក្យស្នើសុំចុះបញ្ជីម៉ាកសរុប ១១ ៧៨៩ម៉ាក ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ សរុប ១០ ១២៤ម៉ាក កើនឡើង ១៦,៤៥%។ ការចុះបញ្ជីម៉ាកសរុប ៩ ៤២១ម៉ាក ក្នុងនោះការចុះបញ្ជីតាមប្រព័ន្ធជាតិ ៣ ៩០២ម៉ាក និងប្រព័ន្ធអន្តរជាតិ ៥ ៥១៩ម៉ាក ប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ កើនឡើង ៩,២០%។ ការចុះបញ្ជីម៉ាកសារជាថ្មី ការបញ្ជាក់ការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក និងការផ្លាស់ប្តូរផ្សេងៗដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | បរិយាយ | ប្រៀបធៀប | | |
|---|---|---|---|---|
| | | ១១ខែ ២០២៣ | ១១ខែ ២០២៤ | % |
| ១ | **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធជាតិ** | | | |
| ១.១ | **ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាក** | **4,574** | **4,932** | **7.83%▲** |
| | ម៉ាកក្នុងស្រុក | 1,913 | 2,034 | 6.33%▲ |
| | ម៉ាកក្រៅស្រុក | 2,661 | 2,898 | 8.91%▲ |
| ១.២ | **ការចុះបញ្ជីម៉ាក** | **4,397** | **3,902** | **-11.26%▼** |
| | ម៉ាកក្នុងស្រុក | 1,933 | 1,602 | -17.12%▼ |
| | ម៉ាកក្រៅស្រុក | 2,464 | 2,300 | -6.66%▼ |

| ល.រ | បរិយាយ | ប្រៀបធៀប | | |
|---|---|---|---|---|
| | | ១១ខែ ២០២៣ | ១១ខែ ២០២៤ | % |
| ១.៣ | ការបញ្ជាក់ការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាក | 3,786 | 3,803 | 0.45%▲ |
| ១.៤ | ការចុះបញ្ជីម៉ាកសាជាថ្មី | 3,690 | 3,081 | -16.50%▼ |
| ១.៥ | ការកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខក្នុងការប្រើប្រាស់ម៉ាក | 83 | 104 | 25.30%▲ |
| ១.៦ | ការកត់ត្រាអជ្ញាបណ្ណឬអជ្ញាបណ្ណពិសេស | 50 | 7 | -86.00%▼ |
| ១.៧ | ការផ្លាស់ប្តូរផ្សេងៗ | 3,185 | 2,655 | -16.64%▼ |
| ១.៨ | ការធ្វើទុតិយតាវិញ្ញាបនបត្រ | 788 | 486 | -38.32%▼ |
| ១.៩ | ការផាកពិន័យមកបង់ប្រាក់ចុះបញ្ជីម៉ាកសារជាថ្មីយឺតយ៉ាវ | 410 | 223 | -45.61%▼ |
| **២** | **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ ( Madrid )** | | | |
| ២.១ | ការដាក់ពាក្យចុះបញ្ជីម៉ាកអន្តរជាតិ | 9 | 7 | -22.22%▼ |
| ២.២ | ការទទួលពាក្យស្នើសុំចុះបញ្ជីម៉ាកអន្តរជាតិ | 5,550 | 6,857 | 23.55%▲ |
| ២.៣ | ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ | 4,230 | 5,519 | 30.47%▲ |
| ២.៤ | ការបញ្ជាក់ការប្រើប្រាស់ ឬមិនប្រើប្រាស់ម៉ាកតាមប្រព័ន្ធអន្តរជាតិ | 904 | 1,328 | 46.90%▲ |
| ២.៥ | ការចុះបញ្ជីម៉ាកសាជាថ្មី តាមប្រព័ន្ធអន្តរជាតិ | 477 | 438 | -8.18%▼ |
| ២.៦ | ការកត់ត្រា ផ្លាស់ប្តូរផ្សេងពាក់ព័ន្ធនឹងម៉ាកតាមប្រព័ន្ធអន្តរជាតិ | 3,539 | 2,660 | -24.84%▼ |
| **៣** | **ការចុះបញ្ជីម៉ាកតាមប្រព័ន្ធជាតិ និងអន្តរជាតិសរុបរួម** | **8,627** | **9,421** | **9.20%**▲ |
| **៤** | **ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** | | | |
| ៤.១ | **ការទទួលពាក្យស្នើសុំ ចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ** | **26** | **184** | **607.69%**▲ |
| | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា | 3 | - | - |
| | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស | 23 | 184 | 700.00%▲ |
| ៤.២ | **ការចុះបញ្ជីម៉ាក** | **26** | **107** | **311.54%**▲ |
| | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញកម្ពុជា | 3 | - | - |
| | ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញបរទេស | 23 | 107 | 365.22%▲ |










## ៣.២.២.ការងារម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ




- ដាក់ពាក្យស្នើសុំកែតម្រូវសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ម្រេចកំពត»នៅសហភាពអឺរ៉ុប ដោយបានបន្ថែមនូវមុខទំនិញថ្មីៗ
- ដាក់ពាក្យស្នើសុំ ការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «អំបិលកំពតកែប» នៅសហភាពអឺរ៉ុប និងចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «អំបិលកំពតកែប» នៅបណ្តាប្រទេសសរុបចំនួន ៥៣ប្រទេស ជាសមាជិករបស់ប្រព័ន្ធច្បាប់ទីក្រុងហ្សឺណែវ និងរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកិច្ចការពារ និងប្រើប្រាស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «អំបិលកំពតកែប»
- សហការជាមួយ FAO ក្នុងការ៖ អនុវត្តគម្រោងស្តីពីការពង្រឹងប្រព័ន្ធម៉ាកសម្គាល់ភូមិសាស្ត្រទំនិញរបស់កម្ពុជា និងការអភិវឌ្ឍម៉ាកសម្គាល់ភូមិសាស្ត្រ

ទំនិញប្រកបដោយចីរភាព និងសិក្សាផលិតផលសក្តានុពល អង្ករ ស្វាយចន្ទី ស្វាយ និងទុរេន ដើម្បីរៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- សហការជាមួយ AFD ក្នុងការៈ រៀបចំកែតម្រូវសៀវភៅបន្ទុកទឹកឃ្មុំព្រៃមណ្ឌលគិរី និងសិក្សាស្រាវជ្រាវ អង្ករក្រអូបកំពង់ស្ពឺ ដើម្បីរៀបចំចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ
- លើកសំណើគម្រោងពាក់ព័ន្ធនឹង ការអភិវឌ្ឍម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ម្រេចកំពត និងទឹកឃ្មុំព្រៃមណ្ឌលគិរី ទៅអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ (KIPO)
- សិក្សាអំពីខ្សែច្រវាក់ផលិតកម្មប្រហុកសៀមរាប និងរៀបចំចងក្រងសៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ក្រោមជំនួយបច្ចេកទេសអង្គការUNIDO
- ជំរុញរៀបចំមហាសន្និបាតសមាគមអាជីវកម្ម និងបោះឆ្នោតជ្រើសរើសសមាសភាពគណៈកម្មាធិការប្រតិបត្តិនិងក្រុមប្រឹក្សាភិបាលចំនួន ២សមាគមៈ (១)-សមាគមលើកកម្ពស់ម្រេចកំពតអាណត្តិ ២០២៤-២០២៨ និង (២)-សមាគមអ្នកដាំក្រូចថ្លុងកោះទ្រង់ក្រចេះអាណត្តិ ២០២៤-២០២៨
- បានចុះបញ្ជីម៉ាកសមូហភាព «ចម្លាក់ប្រាក់ស្ពាន់ខេត្តកណ្ដាល»
- បានរៀបចំចុះបញ្ជីម៉ាកសមូហភាព «ថ្នាំជក់កម្ពុជា»។

### ៣.២.៣.ការងារវិវាទ

| ប្រភេទសេវា | ឆ្នាំ២០២៤ | | គិតត្រឹមឆ្នាំ ២០២៤ | ដោះស្រាយ | | នៅសល់ | |
|---|---|---|---|---|---|---|---|
| | ពាក្យបណ្ដឹង | ដោះស្រាយ | ពាក្យបណ្ដឹង | ចំនួន | % | ចំនួន | % |
| បណ្ដឹងសម្រុះសម្រួលវិវាទម៉ាក | 10 | 16 | 153 | 43 | 152 | 99,35 | 0,65 |
| បណ្ដឹងជំទាស់ការចុះបញ្ជីម៉ាក និងពាក្យបណ្ដឹងស្នើសុំលុបម៉ាក | 43 | 58 | 410 | 43 | 283 | 69,02 | 30,97 |

### ៣.២.៤.ការងារសហប្រតិបត្តិការ និងកិច្ចការច្បាប់

#### ៣.២.៤.១.ការងារសហប្រតិបត្តិការ

- រៀបចំសៀវភៅ «ការកសាងកេរ្តិ៍ឈ្មោះម៉ាក» ក្រោមជំនួយបច្ចេកទេសរបស់អង្គភាពប្រកាសនីយបត្រតក្កកម្មជប៉ុន និងវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចសម្រាប់អាស៊ាននិងអាស៊ីបូព៌ា
- បានអនុវត្តគម្រោង «កំណើនប្រកបដោយបរិយាបន្នៈ ការលើកកម្ពស់សហគ្រិន

កម្ពុជាមានពិការភាពតាមរយៈការអប់រំកម្មសិទ្ធិបញ្ញា និងការកសាងកេរ្តិ៍ឈ្មោះម៉ាកសម្រាប់ពាណិជ្ជកម្ម» និងបានចុះបញ្ជីម៉ាកជូនសហគ្រិនមានពិការភាពចំនួន ២០ម៉ាក ក្រោមជំនួយបច្ចេកទេសរបស់ប្រទេសអូស្ត្រាលី

- បណ្តុះបណ្តាលផ្នែកកម្មសិទ្ធិបញ្ញាសម្រាប់សាលាបណ្តុះបណ្តាលផ្នែករចនាជូននិស្សិតចំនួន ២៥រូប ក្រោមជំនួយបច្ចេកទេស Japan Fund Trust
- អនុវត្តគម្រោងស្តីពីធនធានពន្ធុ ចំណេះដឹងជាប្រពៃណី និងវិញ្ញត្តិវប្បធម៌ (GR TK TCE) ក្រោមជំនួយបច្ចេកទេសរបស់ប្រទេសអូស្ត្រាលី RT4D-RCEP-AANZFTA (ឆ្នាំ២០២៤-២០២៧)
- បានបញ្ចប់លទ្ធផលនៃការសិក្សាគម្រោងស្តីពី «មជ្ឈមណ្ឌលគ្រប់គ្រងម៉ាកពាណិជ្ជកម្មជាតិរបស់កម្ពុជា និងអភិវឌ្ឍប្រព័ន្ធព័ត៌មានធុរកិច្ចកម្មសិទ្ធិបញ្ញា» (Cambodia's National Trademark Management Center-NTMC and IP-Business Information System Development Project) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA)
- បានចូលរួមកិច្ចប្រជុំក្រុមការងារអាស៊ាន ស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា (AWGIPC)ចំនួន ៣លើក ដែលកម្ពុជាត្រូវធ្វើជាប្រធានក្រុមការងារអាស៊ានស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញានៅឆ្នាំ២០២៥។

### ៣.២.៤.២.អនុស្សរណៈ និងកិច្ចព្រមព្រៀងសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា

- ❖ **បានចុះហត្ថលេខាលើ**
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពី «ការពង្រឹងកិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា» រវាងក្រសួងពាណិជ្ជកម្ម និងអង្គភាពកម្មសិទ្ធិបញ្ញាកូរ៉េ
  - អនុស្សរណៈនៃការយោគយល់គ្នាស្តីពី «កិច្ចសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា» រវាងក្រសួងពាណិជ្ជកម្ម និងអង្គភាពកម្មសិទ្ធិបញ្ញាចិន
  - កិច្ចព្រមព្រៀងកិច្ចសហប្រតិបត្តិការអភិវឌ្ឍសេវាធុរកិច្ច សម្រាប់អង្គភាពកម្មសិទ្ធិបញ្ញារវាងក្រសួងពាណិជ្ជកម្ម និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

### ៣.២.៥.ការងារស្វ័យប្រវត្តកម្ម និងព័ត៌មានវិទ្យា

- ដាក់ឱ្យប្រើប្រាស់ថ្នាលសេវាឌីជីថលកម្មសិទ្ធិបញ្ញា ដំណាក់កាលទី១ សម្រាប់សេវាស្វែងរកទិន្នន័យម៉ាក ការជូនដំណឹងអំពីលក្ខខណ្ឌ ស្ថានភាព និងវឌ្ឍនភាពនៃការចុះបញ្ជីម៉ាក

- បន្ថែមប្រព័ន្ធ KHQR Code របស់ធនាគារ ACLEDA និងធនាគារ Wing សម្រាប់ការបង់កម្រៃសេវាម៉ាកតាមប្រព័ន្ធអេឡិចត្រូនិក
- ដាក់ឱ្យប្រើប្រាស់សាកល្បងប្រព័ន្ធអនឡាញសម្រាប់ការទទួលពាក្យស្នើសុំពីកម្ពុជាសម្រាប់ការចុះបញ្ជីម៉ាកតាមប្រព័ន្ធអន្តរជាតិ (Madrid E-Filing)
- អនុវត្តគម្រោងវិភាគធុរកិច្ច (Business Intelligence) ដំណាក់កាលទី២ ដោយធ្វើសមាហរណកម្មលើថ្នាលកម្មសិទ្ធិបញ្ញាអាស៊ាន។

## ៣.៣.ការងារនាំចេញ នាំចូល

### ៣.៣.១.ការផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ

ការនាំចេញតាមការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញក្រោម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម សម្រេចបានទឹកប្រាក់ចំនួន ២១,៨៧ប៊ីលានដុល្លារអាមេរិក កើនឡើង ១០,៤៦% ដូចមានក្នុងតារាងខាងក្រោម៖

(តម្លៃ៖ លានដុល្លារអាមេរិក)

| ល.រ | យថាប្រភេទ | ១១ខែ ឆ្នាំ២០២៣ | | ១១ខែ ឆ្នាំ២០២៤ | | បម្រែបម្រួល (%) | |
|---|---|---|---|---|---|---|---|
| | | ចំនួន CO | ទឹកប្រាក់ | ចំនួន CO | ទឹកប្រាក់ | ចំនួន CO | ទឹកប្រាក់ |
| ១ | For Internal Use | 280,748 | 7,771 | 329,436 | 8,947 | 17.34%▲ | 15.13%▲ |
| ២ | ASEAN-China Free Trade Area **(ACFTA)** | 34,422 | 2,571 | 48,721 | 3,801 | 41.54%▲ | 47.87%▲ |
| ៣ | ASEAN Trade in Goods Agreement **(ATIGA)** | 56,312 | 2,879 | 59,593 | 2,892 | 5.83%▲ | 0.45%▲ |
| ៤ | GSP scheme | 61,151 | 2,164 | 76,963 | 2,668 | 25.86%▲ | 23.28%▲ |
| ៥ | Non-Preferential | 44,493 | 3,404 | 46,892 | 2,462 | 5.39%▲ | -27.69%▼ |
| ៦ | Canadian GSP Scheme **(AB)** | 9,373 | 285 | 10,921 | 376 | 16.52%▲ | 31.72%▲ |
| ៧ | ASEAN-Korea Free Trade Area **(AKFTA)** | 6,235 | 187 | 6,945 | 211 | 11.39%▲ | 13.02%▲ |
| ៨ | ASEAN-Japan Comprehensive Economic Partnership **(AJCEP)** | 2,589 | 116 | 3,075 | 124 | 18.77%▲ | 7.60%▲ |
| ៩ | ASEAN-Australia-New Zealand Free Trade Area **(AANZFTA)** | 6,691 | 86 | 8,644 | 104 | 29.19%▲ | 20.35%▲ |
| ១០ | ASEAN-India Free Trade Area **(AIFTA)** | 5,168 | 232 | 6,085 | 103 | 17.74%▲ | -55.37%▼ |
| ១១ | Duty Free Tariff Preference **(DFTPI-LDC)** Scheme | 402 | 50 | 494 | 61 | 22.89%▲ | 23.13%▲ |
| ១២ | Cambodia-Korea Free Trade Agreement **(CKFTA)** | 1,022 | 21 | 1,902 | 50 | 86.11%▲ | 132.67%▲ |
| ១៣ | the Regional Comprehensive Economic Partnership **(RCEP)** | 643 | 14 | 814 | 20 | 26.59%▲ | 48.74%▲ |

| ល.រ | យថាប្រភេទ | ១១ខែ ឆ្នាំ២០២៣ | | ១១ខែ ឆ្នាំ២០២៤ | | បម្រែបម្រួល (%) | |
|---|---|---|---|---|---|---|---|
| | | ចំនួន CO | ទឹកប្រាក់ | ចំនួន CO | ទឹកប្រាក់ | ចំនួន CO | ទឹកប្រាក់ |
| ១៤ | Cambodia-China Free Trade Agreement **(CCFTA)** | 1 | 0 | 128 | 18 | 12700.00%▲ | 66172.72%▲ |
| ១៥ | The preferential tariff system of the Republic of Korea **(KLDC)** | 553 | 12 | 597 | 13 | 7.96%▲ | 5.09%▲ |
| ១៦ | Arrangement on the Bilateral Trade Enhancement between Cambodia and Viet Nam | 7 | 3 | 28 | 10 | 300.00%▲ | 269.83%▲ |
| ១៧ | Chile GSP Scheme **(CHILE)** | 267 | 5 | 431 | 6 | 61.42%▲ | 20.84%▲ |
| ១៨ | Cambodia-United Arab Emirates **(CAM-UAE)** | | | 724 | 3 | | |
| ១៩ | It is under Japanese GSP scheme with export to Japan and all Raw Materials from Japan **(ANNEX)** | 19 | 1 | 15 | 1 | -21.05%▼ | -10.06%▼ |
| ២០ | ASEAN-Hong Kong, China Free Trade Agreement **(AHKFTA)** | | | 2 | 0 | | |
| ២១ | Special Preference Treatment **(SPT)**, China | | | | | | |
| **សរុប** | | **510,096** | **19,801** | **602,410** | **21,872** | **18.10%▲** | **10.46%▲** |

## ៣.៣.២.ការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

ការចុះបញ្ជីសុំសិទ្ធិនាំចេញក្រោម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មសម្រេចបាន ៣៤៤ រោងចក្រ/ក្រុមហ៊ុន កើនឡើង ៤២,៧៤% ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រោងចក្រ-ក្រុមហ៊ុន | ១១ខែ ឆ្នាំ២០២៣ | | ១១ខែ ឆ្នាំ២០២៤ | | % |
|---|---|---|---|---|---|---|
| | | ចំនួនរោងចក្រ | ចំនួនកម្មករ | ចំនួនរោងចក្រ | ចំនួនកម្មករ | ចំនួនរោងចក្រ |
| ១ | រោងចក្រសម្លៀកបំពាក់ | 60 | 22,320 | 74 | 26,411 | 23.33%▲ |
| ២ | រោងចក្រស្បែកជើង | 14 | 11,761 | 15 | 6,031 | 7.14%▲ |
| ៣ | រោងចក្រកាបូប | 13 | 1,888 | 25 | 5,232 | 92.31%▲ |
| ៤ | រោងចក្រផ្សេងៗ | 61 | 7,780 | 107 | 8,538 | 75.41%▲ |
| ៥ | ក្រុមហ៊ុនផ្សេងៗ | 93 | - | 123 | - | 32.26%▲ |
| **សរុប** | | **241** | **43,749** | **344** | **46,212** | **42.74%▲** |

## ៣.៣.៣.ការចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិក

ការចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិក សម្រេចបាន ១ ៣៧២រោងចក្រឬក្រុមហ៊ុន កើនឡើង១៨,៤៨% ដូចខាងក្រោម៖

(ឯកតា៖ ចំនួនរោងចក្រ/ក្រុមហ៊ុន)

| ល.រ | យថាប្រភេទ | ១១ខែ ឆ្នាំ២០២៣ | ១១ខែ ឆ្នាំ២០២៤ | % |
|---|---|---|---|---|
| ១ | ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកថ្មី | 232 | 313 | 34.91%▲ |
| ២ | ចុះបញ្ជីស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញតាមប្រព័ន្ធអេឡិចត្រូនិកសារឡើងវិញ | 926 | 1059 | 14.36%▲ |
| សរុប | | **1,158** | **1,372** | **18.48%▲** |

### ៣.៣.៤.ប្រភេទអាជ្ញាបណ្ណ និងលិខិតជូនដំណឹងសុំដឹកជញ្ជូនទំនិញឆ្លងកាត់

ការផ្តល់អាជ្ញាបណ្ណនាំចេញឈើ អនុផលព្រៃឈើ និងឈើកែច្នៃ សម្រេចបាន ចំនួន ៣២អាជ្ញាបណ្ណ គិតជាទឹកប្រាក់ ៣,១៤លានដុល្លារអាម៉េរិក កើនឡើង ៥៤,៣២%។ ដោយឡែក ការផ្តល់អាជ្ញាបណ្ណនាំចូលឈើ អនុផលព្រៃឈើ និងឈើកែច្នៃ សម្រេចបាន ៣អាជ្ញាបណ្ណ គិតជាទឹកប្រាក់ ៣៧,៥០ម៉ឺនដុល្លារអាម៉េរិក ថយចុះ -១៩,៦៩% ដូចមានក្នុងតារាងខាងក្រោម៖

(តម្លៃ៖ ដុល្លារអាម៉េរិក)

| ល.រ | យថាប្រភេទ | ១១ខែ ឆ្នាំ២០២៣ | | ១១ខែ ឆ្នាំ២០២៤ | | ប្រៀបធៀប (%) | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| ១ | អាជ្ញាបណ្ណនាំចេញ | 31 | 2,033,649 | 39 | 3,138,384 | 25.81%▲ | 54.32%▲ |
| ២ | ពន្យាអាជ្ញាបណ្ណនាំចេញ | 6 | - | 16 | - | 166.67%▲ | - |
| ៣ | អាជ្ញាបណ្ណនាំចូល | 5 | 466,925 | 3 | 375,000 | -40.00%▼ | -19.69%▼ |
| ៤ | ពន្យាអាជ្ញាបណ្ណនាំចូល | 1 | | 2 | | 100.00%▲ | - |
| ៥ | លិខិតជូនដំណឹង | 15 | - | 13 | - | -23.08%▼ | - |

### ៣.៣.៥.ការនាំចេញ នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃ

ការផ្តល់អាជ្ញាបណ្ណនាំចេញត្បូងពេជ្រមិនទាន់កែច្នៃនិងសល់ពីការកែច្នៃ ចំនួន ៣៤អាជ្ញាបណ្ណ គិតជាទឹកប្រាក់ ២៩,៣៦លានដុល្លារអាម៉េរិក ថយចុះ -១៨,៧៥%។ ដោយឡែកការផ្តល់អាជ្ញាបណ្ណនាំចូលត្បូងពេជ្រមិនទាន់កែច្នៃនិងសល់ពីការកែច្នៃចំនួន ១១អាជ្ញាបណ្ណ គិតជាទឹកប្រាក់ ៣៦,២៨លានដុល្លារអាម៉េរិក ថយចុះ-៤៥% ដូចមានក្នុងតារាងខាងក្រោម៖

(តម្លៃ៖ ដុល្លារអាម៉េរិក)

| ល.រ | លិខិតបញ្ជាក់ | ១១ខែ ឆ្នាំ២០២៣ | | ១១ខែ ឆ្នាំ២០២៤ | | ប្រៀបធៀប (%) | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ | ចំនួន | ទឹកប្រាក់ |
| ១ | នាំចូល | 20 | 69,437,819 | 11 | 36,286,298 | -45.00%▼ | -47.74%▼ |
| ២ | នាំចេញ | 45 | 36,137,343 | 34 | 29,361,949 | -24.44%▼ | -18.75%▼ |

## ៣.៣.៦.ការធ្វើទំនើបកម្មប្រព័ន្ធស្វ័យប្រវត្តកម្ម

- បន្ថែមវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ថ្មី សម្រាប់កិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ រវាងកម្ពុជា និងអេមីរ៉ាតអារ៉ាប់រួម ក្នុងប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ
- ធ្វើបច្ចុប្បន្នភាពវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ ឌី ឱ្យស្របតាម MIG (Message Implementation Guideline) របស់ក្រុមការងារបញ្ជរតែមួយអាស៊ាន ក្នុងការបញ្ជូនវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី ជាអេឡិចត្រូនិកទៅបណ្តាប្រទេសជាសមាជិកអាស៊ាន
- បានចូលរួមអនុវត្តពេញលេញក្នុងការផ្តល់អាជ្ញាបណ្ណនាំចេញ នាំចូលផលិតផលឈើ អនុផលព្រៃឈើ និងឈើកែច្នៃ និងត្បូងពេជ្រមិនទាន់កែច្នៃនិងសល់ពីការកែច្នៃ ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ
- អភិវឌ្ឍថ្នាលព័ត៌មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA Portal) សម្រាប់ជួយសម្រួលដល់ការស្វែងរកព័ត៌មាន ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលកម្ពុជាជាសមាជិក។




FTA Portal មានមុខងារសំខាន់ៗ ដូចជា៖ (១)-ស្វែងរកអត្រាពន្ធគយ និងវិធានដើមកំណើតទំនិញ នៃផលិតផលជាក់លាក់ណាមួយ (២)-ប្រៀបធៀបអត្រាពន្ធគយ និងវិធានដើមកំណើតទំនិញ (៣)-ស្វែងរកព័ត៌មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលកម្ពុជាជាសមាជិក និង(៤)-ផ្តល់ព័ត៌មានទាក់ទងនឹងការដាក់ស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ។

## ៣.៣.៧.ស្ថានភាពពាណិជ្ជកម្មកម្ពុជា

ទំហំពាណិជ្ជកម្មកម្ពុជាសម្រេចបានទឹកប្រាក់ចំនួន ៥០,៤៥ប៊ីលានដុល្លារអាមេរិក កើនឡើង១៥,៩៥% ក្នុងនោះការនាំចេញសម្រេចបានទឹកប្រាក់ចំនួន ២៤,៣៤ប៊ីលានដុល្លារអាមេរិកកើនឡើង១៤,៣៦%និងការនាំចូលសម្រេចបានទឹកប្រាក់២៦,១០ប៊ីលានដុល្លារអាមេរិក កើនឡើង ១៧,៤៨% ដូចមានក្នុងតារាងខាងក្រោម៖

(តម្លៃ៖ លានដុល្លារអាមេរិក)

| ល.រ | ទិសដៅ | ១១ខែ ឆ្នាំ២០២៣ | | | ១១ខែ ឆ្នាំ២០២៤ | | | បម្រែបម្រួល (%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម | នាំចេញ | នាំចូល | ទំហំពាណិជ្ជកម្ម |
| ១ | **ពិភពលោក** | **21,292** | **22,223** | **43,516** | **24,349** | **26,108** | **50,457** | ▲ **14.36%** | ▲ **17.48%** | ▲ **15.95%** |
| ២ | **ប្រទេសអាស៊ាន** | **7,219** | **19,352** | **26,570** | **8,255** | **23,111** | **31,366** | ▲ **14.35%** | ▲ **19.43%** | ▲ **18.05%** |
| ៣ | **អាស៊ាន** | **4,244** | **8,436** | **12,680** | **4,620** | **9,689** | **14,309** | ▲ **8.87%** | ▲ **14.85%** | ▲ **12.85%** |
| | ព្រុយណេ ដារូសាឡឹម | 5 | 18 | 22 | 7 | 25 | 32 | ▲ 57.20% | ▲ 39.50% | ▲ 43.10% |
| | ឥណ្ឌូណេស៊ី | 71 | 895 | 965 | 87 | 915 | 1,002 | ▲ 23.11% | ▲ 2.30% | ▲ 3.82% |
| | ឡាវ | 4 | 177 | 181 | 16 | 220 | 236 | ▲ 312.81% | ▲ 24.66% | ▲ 30.70% |
| | ម៉ាឡេស៊ី | 92 | 486 | 578 | 128 | 649 | 777 | ▲ 39.24% | ▲ 33.60% | ▲ 34.49% |
| | មីយ៉ាន់ម៉ា | 1 | 31 | 32 | 1 | 31 | 31 | ▼ -52.00% | ▲ 0.36% | ▼ -1.47% |
| | ហ្វីលីពីន | 49 | 32 | 81 | 44 | 35 | 79 | ▼ -10.67% | ▲ 11.96% | ▼ -1.82% |
| | សិង្ហបុរី | 615 | 889 | 1,504 | 261 | 891 | 1,151 | ▼ -57.60% | ▲ 0.17% | ▼ -23.45% |
| | ថៃ | 797 | 2,643 | 3,440 | 780 | 3,132 | 3,912 | ▼ -2.14% | ▲ 18.50% | ▲ 13.72% |
| | វៀតណាម | 2,611 | 3,266 | 5,878 | 3,298 | 3,790 | 7,088 | ▲ 26.30% | ▲ 16.04% | ▲ 20.60% |
| ៤ | **អូស្ត្រាលី** | **325** | **127** | **452** | **444** | **102** | **547** | ▲ **36.66%** | ▼ **-19.33%** | ▲ **20.95%** |
| ៥ | **ចិន** | **1,315** | **9,763** | **11,078** | **1,608** | **12,155** | **13,762** | ▲ **22.27%** | ▲ **24.49%** | ▲ **24.23%** |
| ៦ | **ជប៉ុន** | **1,066** | **573** | **1,639** | **1,272** | **677** | **1,950** | ▲ **19.38%** | ▲ **18.13%** | ▲ **18.94%** |
| ៧ | **កូរ៉េ** | **253** | **430** | **683** | **288** | **474** | **762** | ▲ **13.77%** | ▲ **10.15%** | ▲ **11.49%** |
| ៨ | **នូវែលសេឡង់** | **16** | **22** | **38** | **22** | **15** | **36** | ▲ **37.64%** | ▼ **-33.62%** | ▼ **-3.78%** |
| ៩ | **សហភាពអឺរ៉ុប** | **3,348** | **898** | **4,246** | **4,032** | **854** | **4,887** | ▲ **20.45%** | ▼ **-4.85%** | ▲ **15.10%** |
| | បែលហ្ស៊ិក | 398 | 51 | 449 | 334 | 24 | 358 | ▼ -16.08% | ▼ -53.24% | ▼ -20.28% |
| | បារាំង | 333 | 147 | 479 | 368 | 99 | 467 | ▲ 10.81% | ▼ -32.58% | ▼ -2.48% |
| | អាល្លឺម៉ង់ | 742 | 185 | 927 | 828 | 139 | 967 | ▲ 11.56% | ▼ -24.83% | ▲ 4.28% |
| | ហូឡង់ | 509 | 40 | 549 | 729 | 33 | 763 | ▲ 43.19% | ▼ -15.73% | ▲ 38.95% |
| | អេស្ប៉ាញ | 648 | 22 | 670 | 953 | 23 | 976 | ▲ 46.99% | ▲ 5.53% | ▲ 45.64% |
| ១០ | **ចក្រភពអង់គ្លេស** | **727** | **74** | **801** | **886** | **47** | **932** | ▲ **21.82%** | ▼ **-36.71%** | ▲ **16.43%** |
| ១១ | **សហរដ្ឋអាមេរិក** | **8,144** | **223** | **8,367** | **9,063** | **244** | **9,308** | ▲ **11.28%** | ▲ **9.80%** | ▲ **11.24%** |
| ១២ | **កាណាដា** | **774** | **61** | **835** | **1,011** | **52** | **1,063** | ▲ **30.66%** | ▼ **-15.16%** | ▲ **27.30%** |
| ១៣ | **អេមីរ៉ាត់អារ៉ាប់រួម** | **65** | **12** | **78** | **62** | **22** | **83** | ▼ **-5.73%** | ▲ **73.80%** | ▲ **6.98%** |
| ១៤ | **ឥណ្ឌា** | **265** | **179** | **443** | **144** | **176** | **319** | ▼ **-45.73%** | ▼ **-1.68%** | ▼ **-27.97%** |
| ១៥ | **ផ្សេងៗ** | **751** | **1,425** | **2,176** | **897** | **1,602** | **2,499** | ▲ **19.44%** | ▲ **12.39%** | ▲ **14.82%** |


ស្ថានភាពពាណិជ្ជកម្មកម្ពុជា ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាមេរិក)
មករា
កុម្ភៈ
មីនា
មេសា
ឧសភា
មិថុនា
កក្កដា
សីហា
កញ្ញា
តុលា
វិច្ឆិកា
នាំចូល
ទំហំពាណិជ្ជកម្ម
នាំចេញ
តុល្យភាពពាណិជ្ជកម្ម


ស្ថិតិពាណិជ្ជកម្មកម្ពុជារយៈពេល ៥ឆ្នាំ
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាមេរិក)
២០២០
២០២១
២០២២
២០២៣
២០២៤ (១១ខែ)
នាំចេញ
នាំចូល
ទំហំពាណិជ្ជកម្ម
តុល្យភាពពាណិជ្ជកម្ម


ប្រៀបធៀបស្ថានភាពពាណិជ្ជកម្មកម្ពុជា
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាមេរិក)
នាំចេញ
នាំចូល
ទំហំពាណិជ្ជកម្ម
១១ខែ ឆ្នាំ២០២៣
១១ខែ ឆ្នាំ២០២៤


ស្ថិតិនាំចេញទៅកាន់ទីផ្សារសំខាន់ៗ ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាមេរិក)
សរុប៖
24,348.94
លានដុល្លារអាមេរិក
សហរដ្ឋអាមេរិក
អាស៊ាន
សហភាពអឺរ៉ុប
ចិន
ជប៉ុន
កាណាដា
ផ្សេងៗ
ចក្រភពអង់គ្លេស
អូស្ត្រាលី
កូរ៉េ
ឥណ្ឌា
អេមីរ៉ាត់អារ៉ាប់រួម
នូវែលសេឡង់


ស្ថិតិនាំចូលទំនិញពីទីផ្សារសំខាន់ៗ ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាមេរិក)
សរុប៖
26,107.90
លានដុល្លារអាមេរិក
ចិន
អាស៊ាន
ផ្សេងៗ
សហភាពអឺរ៉ុប
ជប៉ុន
កូរ៉េ
សហរដ្ឋអាមេរិក
ឥណ្ឌា
អូស្ត្រាលី
កាណាដា
ចក្រភពអង់គ្លេស
អេមីរ៉ាត់អារ៉ាប់រួម
នូវែលសេឡង់







### ៣.៣.៨.ការនាំចេញតាមមុខទំនិញសំខាន់ៗ

កម្ពុជានាំចេញមុខទំនិញសំខាន់ៗ រួមមាន៖ សម្លៀកបំពាក់ ៨,៩៤ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២៥,៨៤% សម្ភារធ្វើដំណើរ ១,៧៨ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២១,៥០% ស្បែកជើង ១,៥០ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២៤,៣០% និងស្រូវ ១,៥០ប៊ីលានដុល្លារអាម៉េរិក កើនឡើង ១៦,៤២% ដូចមានក្នុងតារាងខាងក្រោម៖

(តម្លៃ៖ លានដុល្លារអាម៉េរិក)

| ល.រ | មុខទំនិញ | ១១ខែ ឆ្នាំ២០២៣ | ១១ខែ ឆ្នាំ២០២៤ | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់នាំចេញ | (%) |
| ១ | សម្លៀកបំពាក់ | 7,106.06 | 8,942.52 | 1,836.47▲ | 25.84%▲ |
| ២ | សម្ភារធ្វើដំណើរ | 1,471.60 | 1,787.94 | 316.35▲ | 21.50%▲ |
| ៣ | ស្បែកជើង | 1,213.79 | 1,508.72 | 294.93▲ | 24.30%▲ |
| ៤ | ស្រូវ | 1,092.53 | 1,271.97 | 179.44▲ | 16.42%▲ |
| ៥ | គ្រឿងអេឡិចត្រូនិច | 975.20 | 938.36 | -36.84▼ | -3.78%▼ |
| ៦ | បន្ទះសូឡា | 1,968.59 | 830.44 | -1,138.16▼ | -57.82%▼ |
| ៧ | សំបកកង់រថយន្ត | 328.27 | 772.55 | 444.28▲ | 135.34%▲ |
| ៨ | ដំឡូងមី | 548.87 | 622.53 | 73.65▲ | 13.42%▲ |
| ៩ | ជ័រកៅស៊ូ | 451.96 | 523.43 | 71.47▲ | 15.81%▲ |

| | | | | | |
|---|---|---|---|---|---|
| ១០ | ស្វាយចន្ទី | 381.37 | 502.99 | 121.62▲ | 31.89%▲ |
| ១១ | វាយនភណ្ឌ | 386.05 | 452.45 | 66.40▲ | 17.20%▲ |
| ១២ | អង្ករ | 421.79 | 438.52 | 16.73▲ | 3.97%▲ |
| ១៣ | ទោចក្រយាន | 468.12 | 375.75 | -92.37▼ | -19.73%▼ |
| ១៤ | ក្តារកុងប្លាកេ | 174.69 | 212.49 | 37.80▲ | 21.64%▲ |
| ១៥ | ចេក | 156.20 | 138.71 | -17.49▼ | -11.20%▼ |
| ១៦ | ស្វាយ | 101.86 | 137.22 | 35.36▲ | 34.72%▲ |
| ១៧ | ស្ករអំពៅ | 104.67 | 87.08 | -17.60▼ | -16.81%▼ |
| ១៨ | ពោត | 28.56 | 45.43 | 16.86▲ | 59.04%▲ |
| ១៩ | ម្រេច | 13.95 | 34.83 | 20.88▲ | 149.68%▲ |
| ២០ | ផ្លែមៀន | 18.54 | 27.95 | 9.41▲ | 50.76%▲ |
| ២១ | ថ្នាំជក់ | 4.16 | 4.87 | 0.71▲ | 17.08%▲ |
| ២២ | ផលិតផលជលផល | 0.50 | 0.93 | 0.42▲ | 83.41%▲ |
| **សរុប** | | **21,292.40** | **24,348.94** | **3,056.54▲** | **14.36%▲** |




ស្ថិតិនាំចេញអង្ករ ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
ផ្សេងៗ 216.62 49.40%
បារាំង 69.00 15.74%
ចិន 51.08 11.65%
ម៉ាឡេស៊ី 42.12 9.60%
ហូឡង់ 36.77 8.38%
ចក្រភពអង់គ្លេស 22.93 5.23%
សរុប៖ 438.52 លានដុល្លារអាម៉េរិក


ស្ថិតិនាំចេញចេក ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
ចិន 131.41 94.74%
ជប៉ុន; 5.91; 4.26%
0.04; 0.03%
0.04; 0.03%
0.33; 0.24%
0.98; 0.71%
សរុប៖ 138.71 លានដុល្លារអាម៉េរិក
ចិន
ជប៉ុន
វៀតណាម
សាធារណរដ្ឋកូរ៉េ
ថៃ
ផ្សេងៗ


ស្ថិតិនាំចេញស្វាយចន្ទី ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
0.36; 0.07%
0.25; 0.05%
0.85; 0.17%
1.45; 0.29%
3.53; 0.70%
សរុប៖ 502.99 លានដុល្លារអាម៉េរិក
វៀតណាម 496.55 98.72%
វៀតណាម
ចិន
តៃវ៉ាន់, ខេត្តនៃប្រទេសចិន
សាធារណរដ្ឋកូរ៉េ
ថៃ
ផ្សេងៗ


ស្ថិតិនាំចេញស្វាយ ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
ថៃ 73.84 53.81%
សរុប៖ 137.22 លានដុល្លារអាម៉េរិក
4.09; 2.98%
2.12; 1.55%
2.18; 1.59%
2.62; 1.91%
វៀតណាម 52.37 38.17%
ថៃ
វៀតណាម
សាធារណរដ្ឋកូរ៉េ
ន័រវែស
ស៊ុយអែត
ផ្សេងៗ


ស្ថិតិនាំចេញជ័រកៅស៊ូ ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
4.83; 0.92%
4.41; 0.84%
4.62; 0.88%
13.54; 2.59%
សរុប៖ 523.43 លានដុល្លារអាម៉េរិក
វៀតណាម 457.30 87.37%
សិង្ហបុរី 38.72 7.40%
វៀតណាម
សិង្ហបុរី
ម៉ាឡេស៊ី
ចិន


ស្ថិតិនាំចេញផ្លែមៀន ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
0.00; 0.01%
0.04; 0.15%
0.09; 0.31%
សរុប៖ 27.95 លានដុល្លារអាម៉េរិក
ថៃ 27.82 99.53%
ថៃ
វៀតណាម
សាធារណរដ្ឋកូរ៉េ
ន័រវែស


ស្ថិតិនាំចេញផ្លែម្រេច ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
2.57; 7%
0.93; 3%
1.09; 3%
1.56; 5%
5.22; 15%
23.46; 67%
សរុប៖ 34.83 លានដុល្លារអាម៉េរិក
វៀតណាម
អាល្លឺម៉ង់
ថៃ
បារាំង
សាធារណរដ្ឋកូរ៉េ
ផ្សេងៗ


ស្ថិតិនាំចេញដំឡូងមី ១១ខែ ឆ្នាំ២០២៤
(ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, ឯកតា៖ លានដុល្លារអាម៉េរិក)
ថៃ 198.70 31.92%
ម៉ាឡេស៊ី; 0.03; 0.01%
ចិន; 0.83; 0.13%
សរុប៖ 622.53 លានដុល្លារអាម៉េរិក
វៀតណាម 422.96 67.94%














### ៣.៣.៩.ការនាំចូលទំនិញសំខាន់ៗ

កម្ពុជានាំចូលទំនិញសំខាន់ៗរួមមាន៖ វាយនភ័ណ្ឌ ៥,៧០ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២៣,៥២% គ្រឿងអេឡិចត្រូនិក ៣,៣២ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២៩,១៤% សម្ភារសំណង់ ១,៤៧ប៊ីលានដុល្លារអាម៉េរិក កើនឡើង ២២,៣៥% ប្រេងម៉ាស៊ូត ១,៣០ប៊ីលានដុល្លារអាម៉េរិក កើនឡើង ១០,១៦% និងរថយន្ត ៩០៧,៧៩លានដុល្លារអាម៉េរិក កើនឡើង ៧,២១% ដូចតារាងខាងក្រោម៖

(តម្លៃ៖ លានដុល្លារអាម៉េរិក)

| ល.រ | មុខទំនិញ | ១១ខែ ឆ្នាំ២០២៣ | ១១ខែ ឆ្នាំ២០២៤ | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់នាំចូល | (%) |
| ១ | វាយនភ័ណ្ឌ | 4,620.31 | 5,706.89 | 1,086.58▲ | 23.52%▲ |
| ២ | គ្រឿងអេឡិចត្រូនិច | 2,571.14 | 3,320.43 | 749.29▲ | 29.14%▲ |
| ៣ | សម្ភារសំណង់ | 1,209.00 | 1,479.21 | 270.21▲ | 22.35%▲ |
| ៤ | ប្រេងម៉ាស៊ូត (D.O) | 1,185.40 | 1,305.83 | 120.43▲ | 10.16%▲ |
| ៥ | រថយន្ត | 846.74 | 907.79 | 61.05▲ | 7.21%▲ |
| ៦ | ប្រេងសាំង (E.A) | 774.21 | 876.11 | 101.90▲ | 13.16%▲ |
| ៧ | ដែក និងដែកថែប | 447.23 | 739.31 | 292.07▲ | 65.31%▲ |

| ល.រ | មុខទំនិញ | ១១ខែ ឆ្នាំ២០២៣ | ១១ខែ ឆ្នាំ២០២៤ | ប្រៀបធៀប | |
|---|---|---|---|---|---|
| | | | | ទឹកប្រាក់នាំចូល | (%) |
| ៨ | ក្រដាស និងក្រដាសកាតុង | 507.17 | 625.85 | 118.68▲ | 23.40%▲ |
| ៩ | គ្រឿងឧបភោគ បរិភោគ | 513.63 | 593.46 | 79.83▲ | 15.54%▲ |
| ១០ | ជីកសិកម្ម និងថ្នាំស្មៅ | 435.07 | 564.51 | 129.44▲ | 29.75%▲ |
| ១១ | ធ្យូងថ្ម | 505.64 | 526.09 | 20.44▲ | 4.04%▲ |
| ១២ | អគ្គិសនី | 226.38 | 314.94 | 88.57▲ | 39.12%▲ |
| ១៣ | ឧស្ម័នសំរាប់ដុត | 208.15 | 308.15 | 99.99▲ | 48.04%▲ |
| ១៤ | ឱសថ និងអាហារបំប៉ន | 323.04 | 264.03 | -59.01▼ | -18.27%▼ |
| ១៥ | ទឹកសុទ្ធ | 214.47 | 248.43 | 33.96▲ | 15.84%▲ |
| ១៦ | គ្រឿងក្រអូប ឬគ្រឿងសម្អាង | 105.97 | 118.22 | 12.26▲ | 11.57%▲ |
| **សរុប** | | **22,223.45** | **26,107.90** | **3,884.45▲** | **17.48%▲** |



## ៣.៣.១០.ការនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម តាមតំបន់សេដ្ឋកិច្ចពិសេស




គម្រោងវិនិយោគតំបន់សេដ្ឋកិច្ចពិសេស ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មានចំនួន ៥៩គម្រោង ក្នុងនោះ តំបន់សេដ្ឋកិច្ចពិសេសដែលបានដំណើរការមានចំនួន២៦ ហើយតំបន់ដែលមានរដ្ឋបាលប្រចាំតំបន់ មានចំនួន២០។ ដោយឡែកក្រសួងពាណិជ្ជកម្មបានចាត់បញ្ជូនមន្ត្រីតំណាងក្រសួងពាណិជ្ជកម្មទៅប្រចាំការនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស មានចំនួន ១៩ ដូចតារាងខាងក្រោម៖

(តម្លៃ៖ ដុល្លារអាម៉េរិក)

| ល.រ | តំបន់សេដ្ឋកិច្ចពិសេស | ចំនួន CO | ទឹកប្រាក់នាំចេញ | ចំនួនរោងចក្រ | ចំនួនកម្មករ |
|---|---|---|---|---|---|
| ១ | ក្រុងព្រះសីហនុ | 17,460 | 1,493,065,788 | 109 | 29,115 |
| ២ | វ៉ីយ៉ាល់គ្រុបភ្នំពេញ | 46,090 | 1,083,133,275 | 122 | 42,095 |
| ៣ | ឈីលូជានពុចាយ | 12,502 | 787,678,797 | 11 | 14,043 |
| ៤ | មេនហាតធេន | 25,904 | 520,630,782 | 30 | 27,333 |
| ៥ | ខេមបូឌានចេជាងហ្គ័រដឹ | 6,260 | 328,910,311 | 23 | 9,969 |
| ៦ | ស្វាយរៀងហ្គីហ្គា-រីសស៍ | 5,371 | 305,462,024 | 33 | 14,073 |
| ៧ | តាយសេង-បាវិត | 5,602 | 302,760,112 | 43 | 10,467 |
| ៨ | នាងកុកកោះកុង | 7,856 | 179,706,664 | 5 | 10,638 |
| ៩ | សានដុងសាន់សៃល | 5,415 | 170,232,575 | 21 | 12,105 |
| ១០ | សានកូប៉ោយប៉ែត | 537 | 66,906,794 | 7 | 1,660 |
| ១១ | ស៊ីនបាវិត | 1,442 | 57,719,245 | 5 | 2,191 |

| ល.រ | តំបន់សេដ្ឋកិច្ចពិសេស | ចំនួន CO | ទឹកប្រាក់នាំចេញ | ចំនួនរោងចក្រ | ចំនួនកម្មករ |
|---|---|---|---|---|---|
| ១២ | យូប៊ីអ៊ីស្ទួល | 171 | 52,969,315 | 1 | 630 |
| ១៣ | ហាយផាក | 982 | 41,063,480 | 14 | 4,088 |
| ១៤ | ប៉ោយប៉ែតអូរនាង | 2,070 | 20,684,423 | 2 | 3,006 |
| ១៥ | ជ្រៃហ្គួនឃើង-បារិត | 242 | 12,998,945 | 3 | 2,144 |
| ១៦ | រ៉ូយ៉ាល់គ្រុបប៉ោយប៉ែត | 65 | 3,224,534 | 2 | 146 |
| ១៧ | ឃៃរីវើលដ៏ប្រ៊ីដឡូជីស្ទីក | - | - | - | - |
| ១៨ | កំពង់ផែក្រុងព្រះសីហនុ | - | - | - | - |
| ១៩ | អ៊ិនធើរៀអូតូម៉ូបាលអ៊ិនដាស្ទ្រីខមផ្លេកស៍ | - | - | - | - |
| សរុប | | 137,969 | 5,427,147,062 | 431 | 183,703 |



# ៤.កិច្ចការជំរុញពាណិជ្ជកម្ម

## ៤.១.ការងារកិច្ចការពិព័រណ៍

### ៤.១.១.ការងារកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្នុងប្រទេស




- ពិព័រណ៍ផលិតផលខ្មែរ និងបន្លែផ្លែឈើលើកទី១៧ នៅខេត្តសៀមរាប ដោយមានការចូលរួមពីក្រុមហ៊ុន/សហគ្រាសចូលរួមចំនួន ១១៣ និងមានស្តង់ពិព័រណ៍សរុបចំនួន ១២៥ស្តង់ ពីរាជធានី-ខេត្តចំនួន១៦
- ពិព័រណ៍ផលិតផលខ្មែរ ក្នុងឱកាសនៃការរៀបចំពិធីបុណ្យទន្លេ លើកទី៨ នៅខេត្តសៀមរាប មានស្តង់ក្រសួងពាណិជ្ជកម្មទំហំ ១៨ម៉ែត្រការ៉េ និងដាក់តាំងបង្ហាញផលិតផលសក្តានុពលកម្ពុជា រួមមាន៖ អង្ករ ម្រេច ស្ករត្នោត សូត្រ គ្រាប់ស្វាយចន្ទី ផ្កាអំបិល វត្ថុអនុស្សាវរីយ៍ ឯកសារផ្សព្វផ្សាយពីវិស័យពាណិជ្ជកម្ម និងវិនិយោគ សរុបប្រមាណជាង ៣០មុខ
- ការតាំងបង្ហាញផលិតផលសក្តានុពលកម្ពុជា ក្នុងព្រះរាជពិធីច្រត់ព្រះនង្គ័ល នៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ ដោយបានរៀបចំស្តង់ក្រសួងពាណិជ្ជកម្ម ដើម្បីដាក់តាំងបង្ហាញផលិតផលសក្តានុពលរបស់បណ្តាខេត្ត ដូចជា៖ អង្ករ ស្រូវ ស្ករត្នោត ស្វាយកែវរមៀត ដំណាប់ស្វាយ គ្រាប់ស្វាយចន្ទី បន្លែ ផ្លែឈើ សណ្តែក ពោត ល្ង និងផលិតផលកែច្នៃរបស់សហគមសហគ្រាស សិប្បកម្ម និងអ្នកកែច្នៃ

- តាំងបង្ហាញផលិតផលឧស្សាហកម្មកម្ពុជា ក្នុងពិធីអបអរសាទរខួប២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក
- ពិព័រណ៍ផលិតផលខ្មែរ និងទំនិញនាំចេញ នាំចូល លើកទី១៧ ឆ្នាំ២០២៤ ដែលប្តូរឈ្មោះទៅជា «ពិព័រណ៍ពាណិជ្ជកម្មកម្ពុជា» នៅរាជធានីភ្នំពេញ ដែលមានស្តង់ពិព័រណ៍ចំនួន២៥០ស្តង់ និងព្រឹត្តិការណ៍អមដូចជា វេទិកាពាណិជ្ជកម្មឌីជីថល វេទិកាពាណិជ្ជកម្មនិងវិនិយោគកម្ពុជា-កូរ៉េ ជំនួបពាណិជ្ជកម្ម កម្មវិធីជំរុញការនាំចេញ
- តាំងបង្ហាញផលិតផលសក្តានុពលក្នុងឱកាសពិធីបុណ្យសមុទ្រ ឆ្នាំ២០២៤ នៅខេត្តកំពត។

## ៤.១.២.ការងារកិច្ចការពិព័រណ៍ពាណិជ្ជកម្មក្រៅប្រទេស

- ដឹកនាំ និងសម្របសម្រួលក្រុមហ៊ុនឯកជន ចូលរួមព្រឹត្តិការណ៍ពិព័រណ៍ក្រៅប្រទេស ២១លើក សរុបចំនួន ៨០ក្រុមហ៊ុន រួមមានៈសាធារណរដ្ឋប្រជាមានិតចិន សាធាណរដ្ឋកូរ៉េ ជប៉ុន វៀតណាម ថៃ និងឡាវ ដែលផ្តោតលើវិស័យពាណិជ្ជកម្ម កសិ-ពាណិជ្ជកម្ម គ្រឿងអលង្ការ គ្រឿងសំណង់ គ្រឿងឧបភោគបរិភោគ ផលិតផលនាំចេញនាំចូល វត្ថុអនុស្សាវរីយ៍ សម្ភារប្រើប្រាស់ក្នុងគេហដ្ឋាន ភស្តុភារកម្ម យិនស៊ិន និងឱសថបុរាណ
- បានជូនដំណឹង និងផ្សព្វផ្សាយដល់វិស័យឯកជនអំពីពិព័រណ៍ពាណិជ្ជកម្មនៅក្រៅប្រទេស ចំនួន ៥៣ព្រឹត្តិការណ៍។

## ៤.១.៣.ការងារកិច្ចការពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិ និងពិភពលោក

- ចូលរួមពិព័រណ៍ចិន-អាស៊ាន លើកទី២១ ឆ្នាំ២០២៤ នៅទីក្រុងណាននីង តំបន់ស្វយ័តក្វាងស៊ី សាធារណរដ្ឋប្រជាមានិតចិន ដែលគណៈប្រតិភូកម្ពុជា ដឹកនាំដោយ **ឯកឧត្តម វង្សី វិស្សុត ឧបនាយករដ្ឋមន្ត្រី ប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជាតំណាង



ដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ក្នុងនោះក្រសួងពាណិជ្ជកម្ម៖

- ក្រុមហ៊ុន សហគ្រាសកម្ពុជាចំនួន ៥៨ក្រុមហ៊ុន សរុបចំនួន ៨៩ស្តង់ និងមានអាជីវករ ពាណិជ្ជករ និងវិនិយោគិនចំនួន ៣០៤នាក់ ចូលរួមតាំងបង្ហាញផលិតផល និងសេវាកម្មសក្តានុពលរបស់កម្ពុជា
- សាងសង់ផ្ទះរួម ( Common House ) ទំហំ ៥៤ម៉ែត្រការ៉េ ដើម្បីតាំងបង្ហាញផលិតផលចម្រុះរបស់កម្ពុជា ព្រមទាំងផ្សព្វផ្សាយអំពីថ្នាល CambodiaTrade.com
- បានផ្សព្វផ្សាយយ៉ាងទូលំទូលាយអំពីវប្បធម៌ អរិយធម៌ខ្មែរ សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ និងវិនិយោគ ក្នុងព្រឹត្តិការណ៍នេះ ដោយទទួលបានអ្នកចូលទស្សនាសរុបចំនួន ២២០ ០០០នាក់ និងមានក្រុមហ៊ុន សហគ្រាស ចូលរួមតាំងបង្ហាញផលិតផល សេវាកម្មចំនួន ៣ ៣០០ក្រុមហ៊ុន ក្នុងនោះមានចំនួន ៧៤០ ជាក្រុមហ៊ុនដែលមកពីប្រទេសជាសមាជិកអាស៊ាន
- ទទួលពានរង្វាន់ចំនួន ៥គ្រឿង ពីគណៈកម្មការរៀបចំពិព័រណ៍ រួមមាន៖
  - ពានរង្វាន់ ក្នុងការរៀបចំពន្លាជាតិស្រស់ឆើតឆាយ
  - ពានរង្វាន់ ក្នុងការរៀបចំអ្នកតាំងពិព័រណ៍
  - ពានរង្វាន់ ក្នុងការកៀរគរក្រុមហ៊ុនឯកជន ចូលរួមពិព័រណ៍អនឡាញ
  - ពានរង្វាន់ ក្នុងការជំរុញកិច្ចសហប្រតិបត្តិការវិនិយោគ
  - ពានរង្វាន់ ក្នុងការរៀបចំផលិតផលតាំងពិព័រណ៍តាមផ្នែកបានល្អ



- វិស័យឯកជនកម្ពុជា-ចិន បានចុះអនុស្សរណៈនៃការយោគយល់គ្នាលើគម្រោងកិច្ចសហប្រតិបត្តិការ និងគម្រោងធុរកិច្ចចំនួន ១៤គម្រោង
- ក្រុមហ៊ុនកម្ពុជាចំនួន៣ ទទួលពានរង្វាន់ក្រោមកម្មវិធី «ពានរង្វាន់ពិព័រណ៍ចិន-អាស៊ាន លើកទី២១ សម្រាប់អ្នកចូលរួមតាំងបង្ហាញ» មានដូចជា៖ (១)-ក្រុមហ៊ុន Rithy 2Thnou Investment Co., LTD ទទួលពាន

រង្វាន់មាស (CAEXPO Gold Award) (២)-ក្រុមហ៊ុន Hanuman Beverages Co., LTD ទទួលពានរង្វាន់ប្រាក់ (CAEXPO Silver Award) (៣)-ក្រុមហ៊ុន Apsara Rice (Cambodia) Co., LTD ទទួលពានរង្វាន់ប្រជាប្រិយភាព (CAEXPO Popularity Award)។

- ពិព័រណ៌ទំនិញនាំចូលអន្តរជាតិចិន លើកទី៧ នៅទីក្រុងសៀងហៃ ដោយសាងសង់ពន្លាជាតិកម្ពុជាទំហំ ១៣២ម៉ែត្រការ៉េ និងមានក្រុមហ៊ុនចំនួន ១១ បានតាំងបង្ហាញផលិតផលក្នុងពន្លាជាតិ និងស្តង់ពាណិជ្ជកម្ម ដែលមានផលិតផលសំខាន់ៗដូចជា៖ អង្ករ ទឹកឃ្មុំ សម្ភារធ្វើដំណើរនិងកាបូប ម្រេចមីជាតិ កាហ្វេ ស្វាយចន្ទី ដំណាប់ផ្លែឈើ ផលិតផលកែច្នៃពីសំណល់ប្លាស្ទិក
- ត្រៀមរៀបចំចូលរួមពិព័រណ៌ពិភពលោក ២០២៥ អូសាកា កាន់សៃ ប្រទេសជប៉ុន ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៣ ខែមេសា ដល់ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២៥ ដោយជារួមសម្រេចបានការងារបច្ចេកទេស ៣០%។

### ៤.១.៤.ការងារកិច្ចការទូទៅ និងគ្រប់គ្រងព្រឹត្តិការណ៍ពិព័រណ៍ពាណិជ្ជកម្ម

- ប្រទីបរបស់ក្រសួងពាណិជ្ជកម្ម ចូលរួមក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៤




- ចេញលិខិតអនុញ្ញាតរៀបចំពិព័រណ៍ ជូនក្រុមហ៊ុនឯកជន ៣២ច្បាប់ និងក្រសួង ស្ថាប័ន ៨ច្បាប់ សរុបចំនួន ១ ៣៥១ស្តង់។

## ៤.២.ការងារអភិវឌ្ឍន៍ទីផ្សារ

### ៤.២.១.ការងារសហប្រតិបត្តិការដៃគូពាណិជ្ជកម្ម

- ការងារបង្កើតសួនឧស្សាហកម្មកម្ពុជា-ចិន៖ គណៈកម្មការចម្រុះសាងសង់សួនឧស្សាហកម្មកម្ពុជា-ចិន បានជួបប្រជុំពិភាក្សា និងរៀបចំកិច្ចជំនួបជំរុញពាណិជ្ជកម្ម និងវិនិយោគទ្វេភាគី សម្រាប់គម្រោងសួនឧស្សាហកម្ម កម្ពុជា-ចិន នៅរាជធានីភ្នំពេញ
- ការងារបង្កើតមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស៖
  - សម្ពោធជាផ្លូវការមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា ១ទីតាំង នៅទីក្រុងអាប៊ូដាប៊ី អេមីរ៉ាតអារ៉ាប់រួម
  - ចេញលិខិតទទួលស្គាល់ជាផ្លូវការចំនួន ១០ទីតាំង៖ (១)-ទីក្រុងស៊ិនយ៉ាង ខេត្តលាវនីង (២)-ទីក្រុងណានចាង ខេត្តជាំងស៊ី (៣)-ទីក្រុងជឹងចូវ ខេត្តហឺណាន (៤)-ទីក្រុងតៃយ័ន ខេត្តសានស៊ី (៥)-ទីក្រុងណានជីង ខេត្តជាំងស៊ូ (៦)-ទីក្រុងហាប៊ីន ខេត្តហេឡុងជាំង (៧)-ទីក្រុងឆាងឈុន ខេត្តជីលីន (៨)-ទីក្រុងស៊ិនជិន ខេត្តក្វាងតុង (៩)-ទីក្រុងឆាងសា ខេត្តហូណាន និង (១០)-ទីក្រុងឈឹងតាវ ខេត្តសានតុង
  - ចេញលិខិតអនុញ្ញាតបណ្តោះអាសន្នចំនួន ១ទីតាំង នៅតំបន់រដ្ឋបាលពិសេសម៉ាកាវ សាធារណរដ្ឋប្រជាមានិតចិន
  - ចេញសេចក្តីណែនាំ ស្តីពីពង្រឹងការគ្រប់គ្រងមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជានៅក្រៅប្រទេស ជាភាសាខ្មែរ អង់គ្លេស និងចិន
  - កំពុងពិនិត្យ និងផ្តល់យោបល់ចំនួន ៤ទីតាំង៖
    - រដ្ឋធានីប៉េកាំង ស្នើដោយក្រុមហ៊ុន Universal Capital Co., Ltd.
    - ទីក្រុងឆុងឈីង ស្នើដោយក្រុមហ៊ុន ហ្វូរី ឧបភើរសិន ឯ.ក
    - ទីក្រុងជូហៃ ស្នើដោយក្រុមហ៊ុនហ្វូអៅ (ខេមបូឌា) អ៊ិនវ៉ាយរិនម៉ិន ប្រឺថេកសិន អេនជីនារីង ឯ.ក
    - ទីក្រុងវូហាន ស្នើដោយក្រុមហ៊ុន (ខេមបូឌា) យ៉ុង ឡុង អ៊ិនជើណេសិនណល គ្រុប
- ជំរុញការដាក់លក់គ្រាប់ស្វាយចន្ទីកែច្នៃចូលទៅកាន់ផ្សារទំនើប ម៉ាត សណ្ឋាគារ នៅលើយន្តហោះ និងភោជនីយដ្ឋាននានា ជាលទ្ធផលបានសម្របសម្រួលជូន

ក្រុមហ៊ុនកែច្នៃគ្រាប់ស្វាយចន្ទីកម្ពុជា បានដាក់លក់ក្នុងផ្សារទំនើបចំនួន ៤ (SuperStore ផ្សារម៉ាក្រូ តេលាម៉ាត និងផ្សារ Big C Mini Mart) ក្នុងបរិមាណសរុបប្រមាណ ១១តោន/ឆ្នាំ សមាគមសណ្ឋាគារទទួលទិញក្នុងបរិមាណសរុបប្រមាណ ២៩០តោន/ឆ្នាំ សម្រាប់តាំងលក់ និងយកទៅកែច្នៃម្ហូបអាហារ និងភេសជ្ជៈក្នុងបរិមាណសរុប ២១០តោន/ឆ្នាំ

- សម្របសម្រួលជាមួយហាង 7-Eleven នៅប្រទេសថៃ ដាក់លក់គ្រាប់ស្វាយចន្ទីកែច្នៃរួចតាមបណ្តាហាង 7-Eleven ក្នុងបរិមាណ ៤៣តោន/ឆ្នាំ
- ជួបពិភាក្សាការងារ ជាមួយគណៈប្រតិភូជាតិចំនួន ២លើក និងអន្តរជាតិចំនួន ៩លើក (ចិន ៧លើក អូស្ត្រាលី ១លើក និងជប៉ុន ១លើក) ដើម្បីផ្សព្វផ្សាយពីកាលានុវត្តភាពពាណិជ្ជកម្ម និងវិនិយោគនៅកម្ពុជា។

### ៤.២.២.ការងារយុទ្ធសាស្ត្រជំរុញទីផ្សារ

- ការផ្សព្វផ្សាយស្តីពី«ការលើកកម្ពស់ផលិតផលខ្មែរ»«តម្រូវការនាំចូលផលិតផលរបស់ប្រទេសជប៉ុន ម៉ាឡេស៊ី និងសាធារណរដ្ឋកូរ៉េ» និង «តម្រូវការនាំទំនិញទៅទីផ្សារប្រទេសចិន សិង្ហបុរី និងតួកគី» ជូនដល់វិស័យឯកជន និងភាគីពាក់ព័ន្ធចំនួន ៧ដង ដោយមានអ្នកចូលរួមសរុប ៧៣០នាក់
- កិច្ចពិគ្រោះប្រឹក្សាយោបល់ស្តីពី «ការពង្រឹងសមត្ថភាពអ្នកផលិត និងកែច្នៃផលិតផល» ក្នុងការស្វែងរកទីផ្សារក្នុង និងក្រៅប្រទេស បានចំនួន ៥ខេត្ត រួមមាន៖ ខេត្តប៉ៃលិន បាត់ដំបង តាកែវ ស្ទឹងត្រែង និងត្បូងឃ្មុំ ដែលមានអ្នកចូលរួមសរុប ៤២០នាក់។
- ការងារសិក្សាលទ្ធភាពបង្កើតផ្សារលក់ដុំទំនិញ៖
    - ទស្សនកិច្ចសិក្សាផ្សារលក់ដុំនៅប្រទេសថៃផ្សារលក់ដុំនៅរាជធានីភ្នំពេញ និងបណ្តាខេត្តពាក់ព័ន្ធ ដើម្បីស្វែងយល់ពីស្ថានភាពផលិត ការនាំចូល ការផ្គត់ផ្គង់បន្លែ ផ្លែឈើ ត្រីសាច់ និងពិនិត្យលទ្ធភាពបង្កើតផ្សារលក់ដុំទំនិញនៅកម្ពុជា
    - រៀបចំឯកសារទស្សនទាន ស្តីពីគម្រោងបង្កើតផ្សារលក់ដុំទំនិញនៅតាមបណ្តារាជធានីខេត្តក្រោមការគ្រប់គ្រងរបស់ក្រសួងពាណិជ្ជកម្ម ដើម្បីពិភាក្សាបន្ថែមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៤.២.៣.ការងារផ្តល់សេវាព័ត៌មានទីផ្សារ និងផ្សព្វផ្សាយ

ប្រមូល និងចងក្រងទិន្នន័យផលិតផលសក្តានុពលកម្ពុជា ១០មុខ រួមមានៈ ស្រូវ-អង្ករ ជំទ្បូងមី ម្រេច ចេកអំបូងលឿង មៀនប៉ៃលិន ស្វាយចន្ទី ដូង ស្វាយ ទឹកឃ្មុំ និង អំបិល សម្រាប់ជំរុញការដាក់លក់ក្នុងថ្នាលពាណិជ្ជកម្មអេទ្បិចត្រូនិក។

### ៤.៣.ការងារគោលនយោបាយពាណិជ្ជកម្ម

### ៤.៣.១.ការងារបរិយាកាសធុរកិច្ច និងទីផ្សារ

- សន្និសីទស្វាយចន្ទីពិភពលោកលើកទី១០ នៅថ្ងៃទី១-៣ ខែកុម្ភៈ ឆ្នាំ២០២៤ នៅខេត្តសៀមរាប ក្រោមអធិបតី ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** ដោយមានការចូលរួមពីភ្ញៀវជាតិ និងអន្តរជាតិប្រមាណ ៥០០នាក់ មកពី ៤០ប្រទេស




- ប្រមូល ចងក្រងព័ត៌មាននិងទិន្នន័យពាក់ព័ន្ធ និងធ្វើបច្ចុប្បន្នភាពឯកសារកម្រងព័ត៌មានស្តីពីបរិយាកាសពាណិជ្ជកម្មនៅកម្ពុជា កាលានុវត្តភាពវិស័យស្វាយចន្ទី វិស័យជំទ្បូងមី និងវិស័យម្រេចកម្ពុជា
- បានកំពុងធ្វើបច្ចុប្បន្នភាពឯកសារស្តីពីកម្ពុជា និងការបើកទីផ្សារពិភពលោកតាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងចងក្រងគោលការណ៍ណែនាំពីការជំរុញការនាំចេញស្វាយចន្ទីទៅទីផ្សារអន្តរជាតិ។

### ៤.៣.២.ការកសាងគោលនយោបាយ និងពិនិត្យតាមដានការអនុវត្ត

បានរៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយពាក់ព័ន្ធនានា និងបានសហការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធដូចជាៈ UNDP, Arise Plus, EU-German GATE, FAO, HEKs, CIRD, Harvest II, Grow ASIA ក្នុងការអនុវត្ត

គោលនយោបាយដូចខាងក្រោម៖

- **គោលនយោបាយជាតិស្តីពីជំឡងមី ២០២០-២០២៥**
    - ការកែសម្រួលសមាសភាពក្រុមការងារអន្តរស្ថាប័នសម្រាប់ពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡងមី២០២០-២០២៥
    - រៀបចំកិច្ចប្រជុំក្រុមការងារអន្តរស្ថាប័នសម្រាប់ពិនិត្យ តាមដាន វាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីជំឡងមី ២០២០-២០២៥ ដោយបញ្ចប់ការរៀបចំរបាយការណ៍វឌ្ឍនភាព និងម៉ាទ្រីសវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិ គោរពជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី**
    - សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់តំបន់ ដើម្បីតាមដានវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពីជំឡងមី ២០២០-២០២៥ ចំនួន ៤លើក នៅខេត្តត្បូងឃ្មុំ ឧត្តរមានជ័យ ព្រះវិហារ និងកំពង់ធំ មានអ្នកចូលរួមសរុបប្រមាណ ៣៥០នាក់។
- **គោលនយោបាយជាតិស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧**
    - កែសម្រួលសមាសភាពគណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិ ស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ (គ.ត.គ.ស.) និងលេខាធិការដ្ឋាននៃ គ.ត.គ.ស.
    - កិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ដោយអនុម័តលើតារាងសូចនាករវាស់វែងសមិទ្ធកម្ម
    - សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីជំរុញការអនុវត្តគោលនយោបាយជាតិ ស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ ចំនួន ៦លើក រួមមាន៖ ខេត្តសៀមរាប ព្រះសីហនុ ស្ទឹងត្រែង ក្រចេះ មណ្ឌលគីរី និងត្បូងឃ្មុំ មានអ្នកចូលរួមសរុប ៥០០នាក់។
- **គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥**
    - កែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសក្រសួងពាណិជ្ជកម្ម សម្រាប់តាមដាន ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥
    - ផ្តល់យោបល់លើការរៀបចំរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តផែនការ

សកម្មភាពរបស់ក្រសួងពាណិជ្ជកម្មក្នុងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្ពុជាឆ្នាំ ២០១៥-២០២៥ (IDP) សម្រាប់ឆ្នាំ២០២៣

- សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លើការប្រមូលទិន្នន័យបន្ថែម និងការវិភាគទិន្នន័យបឋម និងផ្តល់ធាតុចូលលើសេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្ត IDP ក្នុងឆ្នាំ២០២១-២០២៣។

❖ **សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មឆ្ពោះទៅឆ្នាំ២០៣០**

បានប្រមូលធាតុចូលនិងទិន្នន័យពីក្រសួង ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីរៀបចំតាក់តែងសម្រេចបានជាសេចក្តីព្រាងឯកសារបឋម អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា (CTIS) ផ្អែកលើសសរស្តម្ភចំនួន ៦រួមមាន៖

- សសរស្តម្ភទី១ ការធ្វើសមាហរណកម្មពាណិជ្ជកម្មទៅក្នុងសេដ្ឋកិច្ចពិភពលោក
- សសរស្តម្ភទី២ ការពង្រឹងភាពប្រកួតប្រជែងពាណិជ្ជកម្មក្នុងទីផ្សារសកល
- សសរស្តម្ភទី៣ ការលើកកម្ពស់ពាណិជ្ជកម្មប្រកបដោយបរិយាបន្ន និងចីរភាព
- សសរស្តម្ភទី៤ ការជំរុញ និងការអភិវឌ្ឍពាណិជ្ជកម្មឌីជីថល
- សសរស្តម្ភទី៥ ការអភិវឌ្ឍពាណិជ្ជកម្មតាមវិស័យគោលដៅ
- សសរស្តម្ភទី៦ ការត្រៀមខ្លួនសម្រាប់ការចាកចេញពី LDCs។

❖ **សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយជាតិស្តីពីម្រេច**

បានរៀបចំក្រុមការងារ ដើម្បីរៀបចំតាក់តែងគោលនយោបាយជាតិស្តីពីម្រេចក្នុងគោលដៅជំរុញការលើកកម្ពស់ផលិតផលម្រេចកម្ពុជាសម្រាប់បម្រើការនាំចេញ។

❖ **សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសូត្រកម្ពុជា**

បញ្ចប់សេចក្តីព្រាងបឋម និងផ្ញើជូនក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីផ្តល់ធាតុចូល និងយោបល់បន្ថែម។

❖ **សេចក្តីព្រាងគោលនយោបាយពាណិជ្ជកម្មឌីជីថល**

ក្រោយពីទទួលបានធាតុចូល និងយោបល់បន្ថែមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រុមការងារបានបញ្ចប់សេចក្តីព្រាងបឋមគោលនយោបាយនេះ ដើម្បីបន្តនីតិវិធីបញ្ចប់។

❖ **សេចក្តីព្រាងយុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារអង្ករកម្ពុជា ឆ្នាំ២០២៥-២០៣០**

បានបញ្ចប់សេចក្តីព្រាងឯកសារយុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា ឆ្នាំ២០២៥-២០៣០ និងគ្រោងដាក់សម្ពោធជាផ្លូវការនៅឆ្នាំ២០២៥។

❖ **សេចក្តីព្រាងផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំស្រូវ**

បានបញ្ចប់សេចក្តីព្រាងបឋមឯកសារផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍខ្សែច្រវាក់ផលិតកម្មដំណាំស្រូវនៅកម្ពុជា ក្រោមការគាំទ្របច្ចេកទេសរបស់អង្គការ FAO។

**៤.៣.៣.ក្រុមការងារជំរុញចលនាភូមិ១ ផលិតផល១**

ចូលរួមបំពេញបេសកកម្ម និងសកម្មភាពការងារជាមួយគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ (គ.ណ.ជ.ភ១.ផ១)ដូចជា៖

- ជំរុញអនុវត្ត និងរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តការងារចលនាភូមិមួយផលិតផលមួយវិស័យពាណិជ្ជកម្មផ្ញើជូន គ.ណ.ជ.ភ១.ផ១
- ចូលរួមអបអរសាទរ និងថ្លែងសុន្ទរកថាស្វាគមន៍ក្នុងកម្មវិធីទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរលើកទី៧ នៅខេត្តពោធិ៍សាត់ ដោយមាន៖ អ្នកចូលរួម ២០០នាក់ ស្តង់ដាក់លក់ផលិតផល ១៨០ស្តង់ និងមានផលិតផលភូមិមួយផលិតផលមួយរាជធានីខេត្តចូលរួមដូចជា៖អង្ករ ម្រេច គ្រាប់ស្វាយចន្ទី ទឹកត្រី ទឹកស៊ីអ៊ីវ ម្ហូបអាហារ វត្ថុអនុស្សាវរីយ៍ ផលិតផលកសិកម្មនិងផលិតផលកែច្នៃ និងផលិតផលទូទៅ
- ចូលរួមកិច្ចប្រជុំពិនិត្យវាយតម្លៃគុណវុឌ្ឍិជ្រើសរើសផលិតផល និងសេវាដែលគណៈកម្មការ ភ១.ផ១ ថ្នាក់រាជធានី ខេត្ត ស្នើសុំចុះឈ្មោះចូលជាផលិតផល ភ១.ផ១ ក្នុងផែនការសកម្មភាពការងារឆ្នាំ២០២៣ ជាលទ្ធផលបានសម្រេចទទួលស្គាល់ផលិតផលនិងសេវាថ្មីចំនួន ៣៣៤មុខ ក្នុងចំណោមផលិតផលសរុបចំនួន ៤០៥មុខ។

**៤.៣.៤.ការងារជំរុញការនាំចេញផលិតផលសក្តានុពលកម្ពុជា**

ដើម្បីជួយវិស័យឯកជនពីលើយន្តការនានាដែលមានស្រាប់ ឬជាការជំរុញគំនិតផ្តួចផ្តើមថ្មី ក្នុងការសម្របសម្រួលលើយុទ្ធសាស្ត្រនាំចេញផលិតផលសក្តានុពលកម្ពុជាដែលមានគុណភាពខ្ពស់ (Cambodia GI Products) ទៅកាន់ទីផ្សារអន្តរជាតិ (Specific Markets) និងក៏ជាចំណុចកណ្តាលរួមមួយក្នុងតួនាទីជាអ្នកផ្សារភ្ជាប់រវាងអ្នកផលិត អ្នកផ្គត់ផ្គង់ និងទៅនឹងទីផ្សារតម្រូវការ ដើម្បីបង្កើតកិច្ចសន្យាទិញ-លក់ ក្រសួងបានអនុវត្តការងារ និងសម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- ជួបពិភាក្សាជាមួយបណ្តាក្រុមហ៊ុនក្នុងប្រទេសចំនួន ១៦ ដើម្បីសិក្សាស្វែងយល់អំពីកម្រិតស្តង់ដា អនុលោមភាព ផលិតភាពនិងច្រវាក់ផលិតកម្ម

និងជួបពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការជំរុញពាណិជ្ជកម្មអន្តរជាតិ ដើម្បីជំរុញការនាំចេញ ស្វែងរកកិច្ចសហប្រតិបត្តិការ បង្កើតបណ្តាញទំនាក់ទំនងចូលទៅក្នុងទីផ្សារអ្នកទិញ និងឱកាសក្នុងការចាប់ដៃគូធុរកិច្ចជូនអ្នកនាំចេញកម្ពុជា

- ជួបជាមួយបណ្តាក្រុមហ៊ុន និងដៃគូអភិវឌ្ឍក្រៅប្រទេស ចំនួន ១១ ក្នុងការពង្រឹងទំនាក់ទំនង កិច្ចសហការ ស្វែងរកឱកាសភាពជាដៃគូ ដើម្បីពង្រីកវត្តមានផលិតផលកម្ពុជា និងជំរុញការនាំចេញផលិតផលសក្តានុពលកម្ពុជា ទៅកាន់ប្រទេសគោលដៅ និងកិច្ចសហការបន្តនាពេលអនាគត
- ទស្សនកិច្ចសិក្សាទីផ្សារនៅសហភាពអឺរ៉ុបចំនួន ២ដង តាមរយៈការចូលរួមពិព័រណ៌ពាណិជ្ជកម្មស្បាល់ប៉ារីស (SIAL Paris) នៅប្រទេសបារាំង និងកម្មវិធីផ្គូផ្គងធុរកិច្ចនៅប្រទេសហូឡង់ ក្រោមការរៀបចំ និងឧបត្ថម្ភដោយកម្មវិធីភាពជាដៃគូកម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយ ភាពធន់ (CAPRED) ដោយមានការចូលរួមពីបណ្តាក្រុមហ៊ុនដូចជា៖ ក្រុមហ៊ុន IBIS Rice, ក្រុមហ៊ុន Confirel, ក្រុមហ៊ុន Top Planning Japan, ក្រុមហ៊ុន White Gold, ក្រុមហ៊ុន Sela Pepper, ក្រុមហ៊ុន HESED Agriculture, ក្រុមហ៊ុន Thaung Enterprise, ក្រុមហ៊ុន Khmer Jyoryu និងអ្នកជំនាញការផ្នែកកសិកម្មនិងកសិ-ឧស្សាហកម្ម សរុប ១៦រូប
- សម្ពោធដាក់ឱ្យដំណើរការ «មជ្ឈមណ្ឌលសេវានាំចេញ (Export Service Center)» ដែលបង្កើតឡើងក្នុងគោលបំណងដើម្បីជំរុញដល់ការនាំចេញរបស់កម្ពុជា និងពង្រីកសក្តានុពលផលិតផលកម្ពុជា (Product of Cambodia) ទៅកាន់ទីផ្សារអន្តរជាតិ និងរៀបចំប្រព័ន្ធទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលសេវានាំចេញតាមរយៈ៖ (១)-ប្រព័ន្ធ MoC Call Center 1266 និង(២)-គេហទំព័រ www.exportservicecenter.moc.gov.kh
- សម្របសម្រួលចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន Tropicam Fruit and Irrigation Solution Co., Ltd. និងក្រុមហ៊ុន SMART EDEN ដើម្បីបង្កើតភាពជាដៃគូក្នុងការជំរុញផលិតផលកម្ពុជា រួមមាន៖ អង្ករ ស្វាយសម្ងួត និងគ្រាប់ស្វាយចន្ទី ទៅប្រទេសបារាំង និងសហភាពអឺរ៉ុបនៅតាមបណ្តាផ្សារទំនើបរបស់ SMART EDEN ជាង ៦ ០០០ទីតាំង

- ក្រុមហ៊ុន MIRARTH Agri Tech Co., Ltd នឹងនាំចេញស្វាយចន្ទីទៅកាន់ទីផ្សារសហភាពអឺរ៉ុប ជាពិសេសប្រទេសហូឡង់ ក្នុងបរិមាណ ២៥០តោន
- ចុះអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីភ្ជាប់ទំនាក់ទំនង ជាមួយទីផ្សារដៃគូ ដែលមានអ្នកផ្គត់ផ្គង់ និងអ្នកបញ្ជាទិញផលិតផលជាច្រើនប្រភេទចូលទៅកាន់ទីផ្សារទំនិញ ផ្សារទំនើប ភោជនីយដ្ឋាន និងសណ្ឋាគារប្រមាណជាង ១ ០០០កន្លែង នៅទូទាំងទីក្រុងម៉ាកាវ និងហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន
- ចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយ Hong Kong Trade Development Council ដើម្បីបញ្ជាក់ការប្តេជ្ញាចិត្ត និងគោលបំណងរួមគ្នាក្នុងការលើកកម្ពស់នូវទំនាក់ទំនងសេដ្ឋកិច្ច និងពាណិជ្ជកម្មទ្វេភាគី តាមរយៈការចូលរួម និងការរៀបចំរាល់ព្រឹត្តិការណ៍ពាណិជ្ជកម្មសំខាន់ៗ ក្រោមក្របខ័ណ្ឌនៃគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ។ កិច្ចសហប្រតិបត្តិការនេះគឺជាកិច្ចខិតខំក្នុងការបង្កើតឱកាស ដល់ការទាក់ទាញវិនិយោគិនពីហុងកុងមកកម្ពុជា និងជាឱកាសក្នុងការនាំយក ផលិតផលសក្តានុពលពីកម្ពុជាទៅកាន់ទីផ្សារហុងកុង និងទៅកាន់សកលលោក។

# ៥.កិច្ចការរដ្ឋបាលទូទៅ

## ៥.១.ការងាររដ្ឋបាល

- ដំណើរការទូទៅដោយបានចាត់ចែងចុះលេខលិខិតរដ្ឋបាលពាក់ព័ន្ធ និងទទួលលិខិតចូលពីបណ្តាអន្តរក្រសួង ស្ថាប័ន បញ្ជូនទៅបណ្តាអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ដើម្បីជានាឱ្យបានការឆ្លើយតបតាមតម្រូវការ និងទទួលបានព័ត៌មានទាន់ពេលវេលា ជាលទ្ធផលៈ
    - ចុះលេខលិខិតចេញ ៣ ៨៥៩លិខិត
    - ចុះលេខលិខិតចូល និងចរាចរលិខិតជូនអង្គភាពពាក់ព័ន្ធ ៩ ០១២លិខិត
    - ចុះលេខលិខិតរដ្ឋបាលពាក់ព័ន្ធផ្សេងៗសរុបចំនួន ១ ៨៥៣លិខិត
- បានចងក្រងរបាយការណ៍ពាណិជ្ជកម្មជូនទីស្តីការគណៈរដ្ឋមន្ត្រី និងចម្លងជូនស្ថាប័នពាក់ព័ន្ធនានា
- កំពុងរៀបចំបង្កើតបណ្ណសារដ្ឋានក្រសួង ដោយអនុវត្តដំណាក់កាលដំបូងបង្កើតក្រុមការងារបណ្ណសារពីអង្គភាពពាក់ព័ន្ធ ដើម្បីទទួលរៀបចំស្តេនឯកសារ

ដែលមានតម្លៃជាបណ្ណសារតាមអង្គភាពរៀងៗខ្លួន

- សម្របសម្រួល រៀបចំកន្លែងសម្រាប់កិច្ចប្រជុំនៅក្នុងទីស្ដីការក្រសួងរៀបចំ និងចូលរួមកម្មវិធីផ្សេងៗតាមការចាត់តាំង របស់គណៈកម្មាធិការរៀបចំបុណ្យជាតិ និងអន្តរជាតិ ព្រមទាំងចាត់ចែងពិធីសាសនាផ្សេងៗ។

### ៥.២.ការងារបុគ្គលិក

បានធ្វើបច្ចុប្បន្នភាពស្ថានភាពមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យាក្នុងក្របខ័ណ្ឌក្រសួង សម្រាប់ឆ្នាំ២០២៤ ទទួលលទ្ធផលដូចខាងក្រោម៖

| ល.រ | ប្រភេទការងារ | | ចំនួន (រូប) | ស្ត្រី (រូប) |
|---|---|---|---|---|
| បច្ចុប្បន្នភាពមន្ត្រីរាជការ (ឆ្នាំ២០២៤)<br>❖ សរុប ២ ១៩៤រូប<br>❖ ស្រី ៦៩៤រូប | | ❖ ថ្នាក់កណ្ដាល | ១ ៥១៦ | ៤១៨ |
| | | ❖ មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត | ៤១៤ | ១៥៧ |
| | | ❖ ក្រុមហ៊ុនហ្វ្រីនត្រេដ | ៥៩ | ១៧ |
| | | ❖ មន្ត្រីជាប់កិច្ចសន្យា | ២០៥ | ១០២ |
| ១ | តែងតាំង និងផ្ទេរភារកិច្ចមន្ត្រីរាជការ | | ៤១ | ៩ |
| ២ | តែងតាំង និងសម្រួលភារកិច្ចមន្ត្រីតំណាងពាណិជ្ជកម្មនៅបរទេស | | ១១ | ២ |
| ៣ | បណ្ដុះបណ្ដាលក្នុងប្រទេស | | ២៣៤ | ៨១ |
| ៤ | បណ្ដុះបណ្ដាលក្រៅប្រទេស | | ២២ | ៥ |
| ៥ | សិស្សមន្ត្រី និស្សិត ចុះកម្មសិក្សា | | ២៤ | ១១ |
| ៦ | ចាត់មន្ត្រីចូលរួមក្នុងយន្តការផ្សេងៗ | | ២៦ | ៥ |
| ៧ | **ដំឡើងថ្នាក់ និងឋានន្តរស័ក្តិ (សរុប)** | | **៨៤៤** | **២១៦** |
| | - តាមវេន | | ៧៣៥ | ១៩៨ |
| | - តាមកម្រិតសញ្ញាបត្រ | | ៨៣ | ៨ |
| | - ថ្នាក់កិត្តិយស (មុនពេលចូលនិវត្តន៍) | | ២៦ | ១០ |
| ៨ | ផ្ដល់គ្រឿងឥស្សរិយយស | | ៤៦៣ | ១៣៦ |
| ៩ | មន្ត្រីចូលនិវត្តន៍ | | ១៤ | ៨ |
| ១០ | មន្ត្រីកម្មសិក្សា | | ៧ | ៣ |
| ១១ | មន្ត្រីជាប់កិច្ចសន្យា | | ២០៥ | ១០៣ |
| ១២ | អនុញ្ញាតឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស | | ៨ | ២ |
| ១៣ | អនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារវិញ | | ១៦ | ៥ |
| ១៤ | អនុញ្ញាតឱ្យមន្ត្រីរាជការនៅក្របខ័ណ្ឌដើម | | ១៤ | ៤ |
| ១៥ | ទទួលស្គាល់ក្របខ័ណ្ឌមន្ត្រីរាជការផ្ទេរពីក្រសួង ស្ថាប័នផ្សេង | | ២ | - |

| ល.រ | ប្រភេទការងារ | ចំនួន (រូប) | ស្ត្រី (រូប) |
|---|---|---|---|
| ១៦ | ផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល | ៤ | - |
| ១៧ | ដាក់ទណ្ឌកម្មខាងវិន័យតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ | ១០ | - |
| ១៨ | លុបឈ្មោះមន្ត្រីរាជការពីក្របខ័ណ្ឌ (បោះបង់ និងលាឈប់) | ២ | - |
| ១៩ | លុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ (មរណភាព) | ៤ | - |
| ២០ | លុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌ | ៦ | - |
| | - មានប្រាក់ឧបត្ថម្ភ | ៥ | - |
| | - គ្មានប្រាក់ឧបត្ថម្ភ | ១ | - |

បន្ថែមលើបច្ចុប្បន្នភាពខាងលើក្រសួងក៏មានការលើកទឹកចិត្តមន្ត្រីរាជការតាមរយៈ (១)-ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ (តាមវេនអតីតភាពប្រចាំឆ្នាំ តាមកម្រិតសញ្ញាបត្រ ថ្នាក់កិត្តិយសមុនពេលចូលនិវត្តន៍) (២)-ការផ្តល់ឥស្សរិយយសជូនមន្ត្រីរាជការដែលមានស្នាដៃក្នុងការបម្រើការងារជូនក្រសួង ស្ថាប័ន សង្គម និងប្រទេសជាតិ (៣)-ការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត និង(៤)-ការរៀបចំស្នើសុំបណ្ណសមាជិកបេឡាជាតិសន្តិសុខសង្គមជូនមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងអ្នកក្នុងបន្ទុក។

### ៥.៣.ការងារគណនេយ្យ និងហិរញ្ញវត្ថុ

- អនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានៈ (១)-គ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) (២)-ការគ្រប់គ្រង និងការកត់ត្រាចំណូល (៣)-ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើពន្ធទ្រព្យសម្បត្តិរដ្ឋ (SARMIS) (៤)-ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់(CMS)លើផ្នែកចំណូលបានកត់ត្រាចំណូលតាមផែនការឆ្នាំដោយរលូន
- បានស្នើសុំចុះបញ្ជីដី និងធ្វើវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលើទ្រព្យសម្បត្តិរដ្ឋចំនួន ២ទីតាំង និងទទួលបានបណ្ណកម្មសិទ្ធិ ១ទីតាំង
- ទទួលអតីតអគារហ្វេកាន់ ២ល្វែង ពីអតីតសភាពាណិជ្ជកម្មរាជធានីភ្នំពេញ
- ការដោះស្រាយវិវាទដីធ្លីទាក់ទងនឹងអចលនទ្រព្យរបស់ក្រសួង ២៨ទីតាំង
- ស្នើកែសម្រួលទំហំផ្ទៃដី ស្របតាមទិន្នន័យក្នុងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យ ៤ទីតាំង
- ស្នើជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋដែលខូចខាត និងបាត់បង់នៅរដ្ឋបាលកណ្តាល និងមន្ទីររាជធានី ខេត្តចំនួន ៦គ្រឿង ស្មើនឹងទឹកប្រាក់ ៣១៨ ៨៤០ ០០០រៀល
- បានអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្មរវាងក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តថវិកាកម្មវិធី ឬសមិទ្ធកម្មឆ្នាំ២០២៤

- បានផ្សព្វផ្សាយព័ត៌មានថវិកាសង្ខេបក្រសួង លើគេហទំព័រផ្លូវការរបស់ក្រសួង ស្របតាមការណែនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការពង្រឹងតម្លាភាពថវិកាប្រជាពលរដ្ឋ (Citizen Budget)
- បានសិក្សាលក្ខណៈសម្បត្តិរបស់អង្គភាពថវិកានៃរដ្ឋបាលកណ្តាល ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្តល់នីតិសម្បទាឱ្យទៅជា អង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិមិនពេញលេញ
- បានអនុវត្តថវិកាឆ្នាំ២០២៤ តាមគោលការណ៍ណែនាំ និងនីតិវិធីហិរញ្ញវត្ថុតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាព ដោយបានអនុវត្តលើការងារចំណូល ចំណាយដូចខាងក្រោម៖

| ចំណូល ចំណាយប្រចាំឆ្នាំ២០២៤ | | |
|---|---|---|
| ល.រ | បរិយាយ | ទឹកប្រាក់ |
| | **<u>អំពីចំណូល</u>** | |
| ១ | ជំពូក៧៣ ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | ៥៤ ៩០៤ ៨០៤ ០៧២ |
| ២ | ជំពូក៧៤ ចំណូលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម | ៥ ០៣០ ៥៩០ ០០០ |
| ៣ | ជំពូក៧៦ ផលហិរញ្ញវត្ថុ | ១៣ ៩៩៧ ០០០ |
| ៤ | ជំពូក៧៧ ផលផ្សេងៗ និងផលពិសេស | ១ ២៩៩ ៥២០ |
| | **<u>ចំណូលថវិកាជាតិសរុបរួម</u>** | **<u>៥៩ ៩៥០ ៦៩០ ៥៩២</u>** |
| | **<u>អំពីចំណាយ</u>** | |
| ១ | ជំពូក៦០ ការទិញ | ៩ ៦៥២ ៥៧៤ ២០២ |
| ២ | ជំពូក៦១ សេវាកម្ម | ២០ ៥២៩ ០៦៨ ២៩៥ |
| ៣ | ជំពូក៦២ ពន្ធ និងអាករ | ៤៥ ៧៥០ ០០០ |
| ៤ | ជំពូក៦៤ បន្ទុកបុគ្គលិក | ៦២ ៦១០ ៣៨០ ១១៩ |
| ៥ | ជំពូក៦៥ ឧបត្ថម្ភធន | ៩១៣ ៣១៦ ២៥៣ |
| | **<u>ចំណាយថវិកាជាតិសរុបរួម</u>** | **<u>៩៣ ៧៥១ ០៨៨ ៨៦៩</u>** |

## កំណត់សម្គាល់

- ❖ **ការងារប្រមូលចំណូល**
  - ក្នុងរយៈពេល១១ខែដើមឆ្នាំ២០២៤នេះ ស្ថានភាពនៃការប្រមូលចំណូលតាមរយៈ ការបង់កម្រៃសេវាសាធារណៈរបស់ក្រសួង ការផាកពិន័យជាសាច់ប្រាក់ និងថ្លៃឈ្នួលអចលនទ្រព្យមាន ៥៩ ៩៩០ ៦៩០ ៥៩២រៀល ស្មើនឹង១១២,៥៩% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។
- ❖ **ការងារគ្រប់គ្រងចំណាយ**
  - ក្នុងរយៈពេល១១ខែដើមឆ្នាំ២០២៤ ស្ថានភាពចំណាយតាមការបោះផ្សាយអាណត្តិបាន២៤០ ដែលមានទឹកប្រាក់ ៩៣ ៧៥១ ០៨៨ ៨៦៩រៀល ស្មើនឹង៨៦,២៣% ធៀបនឹងច្បាប់ថវិកាឆ្នាំ២០២៤។

### ៥.៤.ការងារបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ

#### ៥.៤.១.ការងារបណ្តុះបណ្តាល

| ល.រ | វគ្គបណ្តុះបណ្តាល/សិក្ខាសាលា | សិក្ខាកាម(រូប) |
|---|---|---|
| ក.បណ្តុះបណ្តាលនៅថ្នាក់កណ្តាល | | |
| ១ | ការផ្តល់សុពលភាពលើរបាយការណ៍វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល | ៦០ |
| ២ | ការយល់ដឹងពីវិស័យពាណិជ្ជកម្មក្នុងយុទ្ធសាស្ត្របញ្ចកោណ | ៨០ |
| ៣ | ការសរសេរសុន្ទរកថា និងការធ្វើបទបង្ហាញសាធារណៈភាសាអង់គ្លេស | ២៨ |
| ៤ | វិធានអនាម័យនិងភូតគាមអនាម័យ និងរបាំងបច្ចេកទេសពាណិជ្ជកម្ម | ៦០ |
| ៥ | វិធានដើមកំណើតទំនិញ និងនីតិវិធីនៃការនាំចេញ | ១៤០ |
| ៦ | បទពិសោធន៍នៃការនាំចេញរបស់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា | ២៥ |
| ៧ | ការកសាងជំនាញបច្ចេកទេសក្នុងការអភិវឌ្ឍពាណិជ្ជកម្ម វគ្គ១ | ៧៥ |
| ៨ | ការវិភាគ និងវាយតម្លៃទិន្នន័យសម្រាប់ទីផ្សារពាណិជ្ជកម្ម | ៨០ |
| ៩ | ការគ្រប់គ្រង និងអភិវឌ្ឍបណ្ណាល័យកម្រិត២ | ១១៨ |
| ១០ | ច្បាប់ពាណិជ្ជកម្មអន្តរជាតិ | ៨០ |
| ១១ | កម្មសិទ្ធិបញ្ញា និងច្បាប់កម្មសិទ្ធិបញ្ញាអន្តរជាតិ | ៨០ |

| ល.រ | វគ្គបណ្តុះបណ្តាល/សិក្ខាសាលា | សិក្ខាកាម(រូប) |
|---|---|---|
| ក.បណ្តុះបណ្តាលនៅថ្នាក់កណ្តាល | | |
| ១២ | ការចរចាពាណិជ្ជកម្ម | ៨០ |
| ១៣ | អនុរលោមភាពឯកសារចុះបញ្ជីពន្ធដា | ១២០ |
| ខ.បណ្តុះបណ្តាលនៅថ្នាក់រាជធានី ខេត្ត | | |
| ១ | ការផ្តល់សុពលភាពលើផែនការយុទ្ធសាស្ត្រអាជីវកម្ម២០២៤-២០២៨ | ៦៧ |
| ២ | ការផ្តល់សុពលភាពលើរបាយការណ៍វាយតម្លៃតម្រូវការវគ្គបណ្តុះបណ្តាល | ៦៤ |
| ៣ | ការយល់ដឹងពីវិស័យពាណិជ្ជកម្មក្នុងយុទ្ធសាស្ត្របញ្ចកោណ | ១៥៥ |
| ៤ | វិធានអនាម័យ និងភូតគាមអនាម័យ | ១៥៥ |
| ៥ | ជំនាញគ្រូបង្គោលសម្រាប់ការអភិវឌ្ឍពាណិជ្ជកម្ម | ៧៥ |
| ៦ | លក្ខខណ្ឌការចុះបញ្ជីពាណិជ្ជកម្ម និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ | ២២០ |

### ៥.៤.២.ការងារស្រាវជ្រាវពាណិជ្ជកម្ម

ចេញផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មអេឡិចត្រូនិក (iTrade Bulletin) បានចំនួន ៩លើក ដែលជាទម្រង់ Infographics ទាក់ទងនឹងលិខិតបទដ្ឋានគតិយុត្តវិស័យពាណិជ្ជកម្ម ព័ត៌មានពាណិជ្ជកម្មជាតិនិងអន្តរជាតិ ដើម្បីងាយស្រួលក្នុងការស្វែងយល់ និងស្រាវជ្រាវ។

## ៦.កិច្ចការអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

### ៦.១.ការងារអគ្គាធិការដ្ឋាន

- **ការងារចុះធ្វើអធិការកិច្ច**
  - ចុះធ្វើអធិការកិច្ចតាមអង្គភាពបានចំនួន ១២អង្គភាព ជាលទ្ធផលរកឃើញចំណុចខ្វះខាតចំនួន ៤១ករណី រួមមាន៖
    - ការគ្រប់គ្រងគណនេយ្យ-ហិរញ្ញវត្ថុ ចំនួន ២០ករណី
    - កិច្ចលទ្ធកម្មសាធារណៈ ចំនួន ១ករណី
    - ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ចំនួន ៦ករណី
    - ការគ្រប់គ្រងសេវាសាធារណៈ ចំនួន ១ករណី

- ការអនុវត្តតួនាទីភារកិច្ច ចំនួន ១ករណី
- ការគ្រប់គ្រងរដ្ឋបាល-បុគ្គលិក ចំនួន ១២ករណី

- ធ្វើអធិការកិច្ចដោយមិនជូនដំណឹងមុន ( Spot Check ) បានចំនួន ២ករណី។

❖ **ការងារតាមដានការកែលម្អតាមអនុសាសន៍**

ពិនិត្យឃើញថា អង្គភាព១២ បានកែលម្អតាមអនុសាសន៍ណែនាំរបស់បណ្តាប្រតិភូត្រួតពិនិត្យចំនួន ៦៣ករណី ក្នុង ៧៩ករណី ស្មើនឹង៨០% និងបន្តកែលម្អបន្ថែមទៀតចំពោះករណីដែលនៅសេសសល់។

❖ **ការងារទទួលពាក្យបណ្តឹង**

បានទទួលពាក្យបណ្តឹងតវ៉ា បណ្តឹងបរិហារ និងវិវាទចំនួន ៣ករណី និងបានដោះស្រាយបញ្ចប់ជាស្ថាពរ។

**៦.២.ការងារសវនកម្មផ្ទៃក្នុង**

❖ **ការងារចុះធ្វើសវនកម្ម**

បានចុះធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង ផ្នែកគណនេយ្យនិងហិរញ្ញវត្ថុ ផ្នែករដ្ឋបាល ការគ្រប់គ្រងនិងការពារទ្រព្យសម្បត្តិរដ្ឋ វាយតម្លៃភាពសន្សំសំចៃ និងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធាន ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងការអនុវត្តអនុលោមភាពច្បាប់ បទប្បញ្ញត្តិនានារាល់ប្រតិបត្តិការគ្រាមុន( ឆ្នាំ២០២៣និងឆ្នាំពាក់ព័ន្ធ )បាន១៥សវនដ្ឋាន។ ជាលទ្ធផលបានរកឃើញចំណុចខ្វះខាត និងផ្តល់ជាអនុសាសន៍កែលម្អចំនួន ៣២ចំណុច ក្នុងនោះរួមមាន៖

- កិច្ចបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទាន ចំនួន ១៥ចំណុច
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ចំនួន ៣ចំណុច
- ការអនុវត្តតួនាទីភារកិច្ច ចំនួន ៨ចំណុច
- អនុវត្តកិច្ចលទ្ធកម្មសាធារណៈ ចំនួន ៦ចំណុច។

❖ **ការងារតាមដានអនុសាសន៍គ្រាមុន**

ពិនិត្យតាមដានការកែលម្អតាមអនុសាសន៍សវនកម្មគ្រាមុន (ការិយបរិច្ឆេទ ២០២៣និងឆ្នាំពាក់ព័ន្ធ) និងវាយតម្លៃលើវឌ្ឍនភាពការកែលម្អបាន ១៥សវនដ្ឋាន។ ជាលទ្ធផលក្នុងចំណោមអនុសាសន៍គ្រាមុនចំនួន ៤៣ចំណុច បានអនុវត្តពេញលេញ ៣៥ចំណុច ស្មើនឹង៨១% និងបន្តកែលម្អបន្ថែមទៀតចំពោះករណីដែលនៅសេសសល់។

## ៧.កិច្ចការយេនឌ័រ

### ៧.១.សហគ្រិនស្ត្រី

រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ការលើកកម្ពស់សមភាពយេនឌ័រ និងការបង្កើនភាពអង់អាចរបស់ស្ត្រីនៅគ្រប់វិស័យជាអាទិភាពក្នុងរបៀបវារៈគោលនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដោយបានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និងសង្គមជាតិ តាមរយៈការបង្កើនការវិនិយោគទៅលើការលើកកម្ពស់សិទ្ធិ ឋានៈ តួនាទី និងស្ថានភាពសេដ្ឋកិច្ច-សង្គមរបស់ស្ត្រី និងក្រុមគ្រួសារ។ ជាក់ស្តែង ផ្អែកតាមស្ថិតិចុះបញ្ជីពាណិជ្ជកម្ម ក្នុងឆ្នាំ២០២៤ សហគ្រិនស្ត្រី មានចំនួន ៣ ៦១៩រូប។

### ៧.២.ស្ថិតិមន្ត្រីរាជការជាស្ត្រី

បច្ចុប្បន្នកំណើនការចូលរួមរបស់ស្ត្រីក្នុងវិស័យពាណិជ្ជកម្ម មានការកើនឡើងគួរជាទីមោទក ទន្ទឹមនេះ ការបញ្ជ្រាបមន្ត្រីរាជការជាស្ត្រីឱ្យកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ជាក់ស្តែងក្នុងចំណោមមន្ត្រីរាជការសរុប ២ ១៩៨រូប មានស្ត្រី ៦៩៤រូប ក្នុងនោះមន្ត្រីរាជការជាស្ត្រីត្រូវបានតែងតាំងក្នុងមុខតំណែងចាប់ពីអនុប្រធានការិយាល័យ ដល់មុខតំណែងជារដ្ឋមន្ត្រី មានដូចខាងក្រោម៖

| ល.រ | មុខតំណែង | ចំនួនមន្ត្រីជាស្ត្រី (រូប) |
|---|---|---|
| ក. ថ្នាក់កណ្តាល | | |
| ១ | រដ្ឋមន្ត្រី | ១ |
| ២ | រដ្ឋលេខាធិការ | ៧ |
| ៣ | អនុរដ្ឋលេខាធិការ | ៦ |
| ៤ | ទីប្រឹក្សាក្រសួង | ១១ |
| ៥ | ជំនួយការក្រសួង | ៤ |
| ៦ | សមាជិកគណៈកម្មាធិការប្រកួតប្រជែងកម្ពុជា ជាបុគ្គលឯករាជ្យ | ១ |
| ៧ | អគ្គាធិការ | ១ |
| ៨ | អគ្គាធិការរង | ២ |
| ៩ | អគ្គនាយករង | ៥ |
| ១០ | អនុប្រធាននាយកដ្ឋាន | ៥០ |
| ១១ | អនុប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្ម និងស្រាវជ្រាវ | ៤ |

| ល.រ | មុខតំណែង | ចំនួនមន្ត្រីជាស្ត្រី (រូប) |
|---|---|---|
| ក. ថ្នាក់កណ្តាល | | |
| ១២ | អនុប្រធានសាខា ក.ប.ប. រាជធានី ខេត្ត | ៨ |
| ១៣ | ប្រធានការិយាល័យ | ៥៦ |
| ១៤ | អនុប្រធានការិយាល័យ | ១៧៥ |
| សរុប | | ៣៣១ |
| ខ. មន្ត្រីតំណាងក្រសួងពាណិជ្ជកម្មអមស្ថានតំណាង នៃព្រះរាជាណាចក្រកម្ពុជានៅបរទេស | | |
| ១ | អនុព័ន្ធពាណិជ្ជកម្ម | ៤ |
| គ. មន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត | | |
| ១ | ប្រធានមន្ទីរ | ១ |
| ២ | អនុប្រធានមន្ទីរ | ១៩ |
| ៣ | ប្រធានការិយាល័យ | ២២ |
| ៤ | អនុប្រធានការិយាល័យ | ៤៨ |
| សរុប | | ៩០ |
| សរុបរួម (ក+ខ+គ) | | ៤២៥ |

## ៧.៣.ការលើកកម្ពស់យេនឌ័រក្នុងវិស័យពាណិជ្ជកម្ម



ឆ្លើយតបទៅនឹងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្រសួងបានចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រវិស័យពាណិជ្ជកម្ម៖

- ប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៤ ខួបលើកទី១១៣

ក្រោមប្រធានបទ «ស្ត្រី និងក្មេងស្រីក្នុងបរិវត្តកម្មឌីជីថល»

- រៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ របស់ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០២៤-២០២៨
- សិក្សាលទ្ធភាពបង្កើតបន្ទប់ទារកដ្ឋាន ដើម្បីសម្រាលបន្ទុកមន្ត្រីរាជការ ដែលមានកូនតូចៗក្រោមអាយុ ៦ឆ្នាំ
- សំណេះសំណាលជាមួយមន្ត្រីរាជការជាស្ត្រីចូលនិវត្តន៍ ចំនួន ៥៧រូប
- រៀបចំសិក្ខាសាលាចំនួន ២លើក និងចូលរួមសហការរៀបចំវគ្គបណ្តុះបណ្តាល និងសិក្ខាសាលាចំនួន ៨៥លើក ក្នុងគោលបំណងបញ្ជ្រាបសមភាពយេនឌ័រ អំណាច កត្តាជំរុញភាពជោគជ័យ និងការលើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យពាណិជ្ជកម្ម
- រៀបចំរបាយការណ៍ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្តីពីវឌ្ឍនភាពការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន (COB) ៥៧ចំណុច របស់គណៈកម្មាធិការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) របស់អង្គការសហប្រជាជាតិលើរបាយការណ៍លើកទី៦ របស់កម្ពុជា ក្នុងការអនុវត្តអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។

# ៨.កិច្ចការកែទម្រង់

## ៨.១.ការងារកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

- ចេញប្រកាសស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាច ទៅឱ្យមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តក្នុងការពិនិត្យផ្តល់យោបល់ និងសម្រេចលើកិច្ចការនានាពាក់ព័ន្ធនឹងការចុះបញ្ជីគម្រោងវិនិយោគ ដែលក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់អនុគណៈកម្មាធិការវិនិយោគរាជធានី ខេត្ត
- ស្នើសុំកែសម្រួលបញ្ជីកម្រងសេវាវិស័យពាណិជ្ជកម្ម នៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ តាមរយៈការកំណត់ទំហំសេវាអាជីវកម្ម និងកម្រៃលើការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម និងការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្ម លោហធាតុត្បូងថ្មមានតម្លៃ ជាគ្រឿងអលង្ការគ្រប់ប្រភេទ តាមសំណើរបស់អគ្គលេខាធិការដ្ឋានកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការ គ.ជ.អ.ប.
- រៀបចំសេចក្តីព្រាងផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ ស្តីពីការងារកំណែ

ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ស្របតាមផែនការអនុវត្ត៥ឆ្នាំ (២០២១-២០២៥) ដើម្បីអនុវត្តសកម្មភាពចំនួន ៧ រួមមានៈ (១)-រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង និងព្រឹត្តិការណ៍នានាស្តីពីការងារកំណែទម្រង់របស់ក្រសួង (២)-អភិវឌ្ឍសមត្ថភាពអង្គភាព ឬគណៈកម្មការដឹកនាំកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួង ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន (៣)-អភិវឌ្ឍសមត្ថភាពអំពីបរិយាបន្ន និងសមធម៌សង្គមដល់មន្ត្រីពាក់ព័ន្ធការងារយេនឌ័រក្រសួង (៤)-សិក្សា និងវិភាគតួនាទីរបស់ក្រសួងដើម្បីពិនិត្យ និងកែសម្រួលរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងរបស់ក្រសួងសម្រាប់គាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការផ្តល់សេវា (៥)-រៀបចំគោលការណ៍ណែនាំសម្រាប់មុខងារដែលបានផ្ទេរឱ្យ រដ្ឋបាល ក្រុង ស្រុក ខណ្ឌ (៦)-រៀបចំការផ្សព្វផ្សាយ និងបណ្តុះបណ្តាលអំពីគោលការណ៍ នីតិវិធី និងបែបបទនៃការអនុវត្តមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និង(៧)-គាំទ្រ តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តមុខងារជាកាតព្វកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៨.២.ការងារកែទម្រង់រដ្ឋបាលសាធារណៈ

ក្នុងគោលបំណងអនុវត្តស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្តោតលើការធ្វើទំនើបកម្មស្ថាប័នរដ្ឋឱ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ និងដោយឈរលើអភិក្រម «ពង្រឹងនិងការរៀបចំផ្ទះរបស់ខ្លួនឱ្យរៀបរយ» ក្រសួងសម្រេចបានសមិទ្ធផលសំខាន់ៗដូចខាងក្រោមៈ

- បង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ នៃក្រសួងពាណិជ្ជកម្ម
- បញ្ជូនរបាយការណ៍លទ្ធផលស្តីពីការពិនិត្យឡើងវិញ ការវិភាគមុខងារ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ជូនក្រសួងមុខងារសាធារណៈ
- បានបញ្ជូនរបាយការណ៍វឌ្ឍនភាព ស្តីពីដំណើរការនៃការពិនិត្យឡើងវិញ ការវិភាគមុខងារនិងរចនាសម្ព័ន្ធ និងការធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការសម្រាប់ឆមាសទី១ ឆ្នាំ២០២៤ ជូនក្រសួងមុខងារសាធារណៈ

- កែសម្រួលរចនាសម្ព័ន្ធក្រសួង និងបញ្ចប់សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម និងបានស្នើសុំកំណត់កាលបរិច្ឆេទ ដើម្បីពិគ្រោះយោបល់អនុលោមបទប្បញ្ញត្តិ ជាមួយក្រសួងមុខងារសាធារណៈ
- សម្របសម្រួលជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងក្នុងការបំពេញប្រវត្តិរូប តាមគំរូថ្មីដែលចេញដោយក្រសួងមុខងារសាធារណៈ និងបន្តធ្វើបច្ចុប្បន្នភាព ទិន្នន័យមន្ត្រីរាជការក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានមន្ត្រីរាជការ (HRMIS) របស់ក្រសួងមុខងារសាធារណៈ។

**៨.៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- រៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ និងជំរុញការអនុវត្តឱ្យបានតាមផែនការដែលបានដាក់ចេញ
- រៀបចំសេចក្តីព្រាងគោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានរៀបចំសេចក្តីព្រាងផែនការរជ្ជទេយ្យបុរេប្រទាន និងសេចក្តីព្រាងផែនការលទ្ធកម្ម ដើម្បីផ្តល់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មុនពេលចរចាថវិកាកម្រិតជំនាញឆ្នាំ២០២៥
- ជំរុញ និងបង្កើនប្រសិទ្ធភាពការបើកផ្តល់ប្រាក់បេសកកម្មទាំងក្នុងនិងក្រៅប្រទេសតាមប្រព័ន្ធធនាគារ
- ជំរុញការទូទាត់ថវិកាបុរេប្រទានឱ្យបានទាន់ពេលវេលា
- ចូលរួមអនុវត្តការធ្វើស្វ័យប្រវត្តកម្មនីតិវិធី លើមុខងារលទ្ធកម្មពេញលេញតាមប្រព័ន្ធ FMIS
- ពង្រឹងការប្រើប្រាស់វិធីសាស្ត្រកិច្ចលទ្ធកម្មប្រកួតប្រជែង លើចំណាយថវិកាចរន្តនៅរដ្ឋបាលកណ្តាល
- ពង្រឹងការរៀបចំរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មប្រចាំត្រីមាស
- ពង្រឹងការធ្វើស្វ័យប្រវត្តកម្មប្រតិបត្តិការហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS លើគ្រប់មុខសញ្ញាចំណាយចរន្តទាំងអស់នៅរដ្ឋបាលកណ្តាល
- ជំរុញរៀបចំរបាយការណ៍សម្រេចទូទាត់ចំណាយឆ្នាំ២០២៣ និងរបាយការណ៍ផ្ទៀងផ្ទាត់ចំណូលឆ្នាំ២០២៣
- ជំរុញការធ្វើបញ្ជីកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ទាំងរដ្ឋបាលកណ្តាល និងនៅតាមមន្ទីរពាណិជ្ជកម្មរាជធានី ខេត្តទាំងអស់

- សម្របសម្រួលជាមួយគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ឱ្យប្រើប្រាស់ប្រព័ន្ធ SARMIS សម្រាប់កត់ទិន្នន័យទ្រព្យសម្បត្តិរដ្ឋតាមអង្គភាព និងរៀបចំសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះឆ្នាំ២០២៣
- សម្របសម្រួលជាមួយគ្រប់អង្គភាពថវិកា ដើម្បីកាត់តម្រឹមសេចក្តីព្រាងផែនការចំណាយ ឆ្នាំ២០២៥ ធៀបនឹងសារាចរស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០២៥-២០២៧ មកក្នុងរង្វង់ +/-១០%
- សិក្សាលក្ខណសម្បត្តិរបស់អង្គភាពថវិកានៅរដ្ឋបាលកណ្តាល ដើម្បីវាយតម្លៃដាក់ឱ្យទៅជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងមិនពេញលេញ
- សម្រេចបានការចុះកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៤៖
  - រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម
  - រវាងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងប្រធានអង្គភាពថវិកានីមួយៗ
  - រវាងអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- រៀបចំរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ២០២៣ និងឆមាសទី១ ឆ្នាំ២០២៤
- សម្របសម្រួលជាមួយអង្គភាពសវនកម្មផ្ទៃក្នុង ដើម្បីឱ្យសាកល្បងធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យា និងការធ្វើសវនកម្មសមិទ្ធកម្ម
- ផ្សព្វផ្សាយព័ត៌មានស្តីពីថវិកាដើម្បីផ្លាស់ប្តូរព័ត៌មាន ជាមួយសាធារណជនដែលហៅថាថវិកាពលរដ្ឋ (Citizen Budget) លើគេហទំព័រផ្លូវការរបស់ក្រសួង
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាង Financial Management Manual របស់ក្រសួង និងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា។

### ៨.៤.ការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

- ទទួលបន្ទុកដឹកនាំការអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ(KPIs)សម្រាប់ក្របខ័ណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់ទី១ ចំនួន ២រួមមាន៖
  - សូចនាករទី៣១ «ចំនួនសហគ្រាសធុនតូច និងមធ្យម (SMEs) ផ្លូវការដែលធ្វើការនាំចេញ»

- សូចនាករទី៣៤ «ការយល់ឃើញរបស់ធុរជន និងសាធារណជនលើការអនុវត្តច្បាប់ស្តីពីការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ»

- ទទួលបន្ទុកចូលរួមអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះចំនួន ៧រួមមានៈ
  - សូចនាករទី៣ «អត្រាអតិផរណា (ការប្រែប្រួលមធ្យមប្រចាំឆ្នាំ)»
  - សូចនាករទី១១«ការយល់ឃើញរបស់ធុរជនលើប្រសិទ្ធភាពនិងគុណភាពនៃការផ្តល់សេវាសាធារណៈ»
  - សូចនាករទី២៤«ចំណែកទំហំទុនវិនិយោគបរទេសក្នុងវិស័យឧស្សាហកម្មគន្លឹះថ្មីៗ ធៀបនឹងទំហំទុនវិនិយោគបរទេសសរុបក្នុងវិស័យឧស្សាហកម្ម»
  - សូចនាករទី២៦ «ពិន្ទុនៃសន្ទស្សន៍ត្រៀមខ្លួនរួចរាល់សម្រាប់ធុរកិច្ច»
  - សូចនាករទី៣៥ «សមាមាត្រ នៃផលិតផលកសិកម្មកែច្នៃធៀបនឹងផលិតផលកសិកម្មក្នុងស្រុកសរុប»
  - សូចនាករទី៣៦ «សមតុល្យពាណិជ្ជកម្មកសិកម្ម»
  - សូចនាករទី៣៧ «អនុបាត ដែលអាចផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់ដោយខ្លួនឯង»។

## ៩.កិច្ចការមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត

មន្ទីរពាណិជ្ជកម្ម ជាសេនាធិការថ្នាក់ក្រោមជាតិ ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសរបស់ក្រសួងពាណិជ្ជកម្ម ដែលបានបំពេញតួនាទីយ៉ាងសកម្មចូលរួមអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ តាមរយៈការជំរុញអភិវឌ្ឍន៍វិស័យពាណិជ្ជកម្មទាំងក្នុង និងក្រៅប្រទេស ដោយជំរុញផ្សារភ្ជាប់ទំនាក់ទំនងជិតស្និទ្ធរវាងប្រភពផ្គត់ផ្គង់នឹងទីផ្សារ សម្រួលបំពេញតម្រូវការអ្នកប្រើប្រាស់ ចូលរួមជំរុញលើកកម្ពស់សុវត្ថិភាពទំនិញ និងសេវា និងតាមដានថ្លៃ និងប្រភពផ្គត់ផ្គង់ទំនិញប្រើប្រាស់ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃក្នុងភូមិសាស្ត្ររបស់ខ្លួន ហើយសម្រេចបានលទ្ធផលដូចខាងក្រោមៈ

### ៩.១.ការគ្រប់គ្រងស្ថានភាពទីផ្សារ និងអង្គភាពអាជីវកម្ម

ស្ថានភាពទីផ្សារ និងអង្គភាពអាជីវកម្មនៅតាមបណ្តាភូមិសាស្ត្ររាជធានី ខេត្ត មានការរីកចម្រើនគួរជាទីកត់សម្គាល់។ បណ្តាទីរួមខេត្តសំខាន់ៗបានក្លាយជាបណ្តុំអភិវឌ្ឍន៍ពាណិជ្ជកម្ម ដែលមានសកម្មភាពអាជីវកម្មរស់រវើក ក្នុងនោះមាន (១)-ស្ថិតិផ្សារសរុបមានចំនួន ២ ២៤២ (២)-ស្ថិតិសហគ្រាស ក្រុមហ៊ុនមានចំនួន ៥៧ ២២៣ (៣)-រោង

ម៉ាស៊ីនកិនស្រូវមានចំនួន ១៤០ និង(៤)-សហគ្រាសកែច្នៃកសិផលមានចំនួន ៤៦៣ ដូចមានក្នុងក្រាហ្វិកខាងក្រោម៖













## ៩.២.ការអនុវត្តការងារប្រតិភូកម្ម និងការងារពាក់ព័ន្ធតំបន់សេដ្ឋកិច្ចពិសេស

ក្នុងគោលបំណងបង្កលក្ខណៈងាយស្រួលសម្រាប់រោងចក្រ សហគ្រាស ស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញដើម្បីធ្វើការនាំចេញទំនិញក្រសួងបានធ្វើប្រតិភូកម្មការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់ឌី (CO Form D) ទៅបណ្តាមន្ទីរពាណិជ្ជកម្មខេត្តជាប់ព្រំដែន ដែលជាលទ្ធផលមន្ទីរពាណិជ្ជកម្មបានចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញបានចំនួន ២ ៧៣៧វិញ្ញាបនបត្រ។



### ៩.៣.កិច្ចសហការជាមួយសាខា ក.ប.ប.

ដើម្បីលើកកម្ពស់ការយល់ដឹងរបស់អាជីវករ ពាណិជ្ជករ សិស្សានុសិស្ស និងសាធារណជន លើច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ ច្បាប់ស្ដីពីការប្រកួតប្រជែង ច្បាប់ស្ដីពីសុវត្ថិភាពម្ហូបអាហារ និងបទប្បញ្ញត្តិពាក់ព័ន្ធ មន្ទីរពាណិជ្ជកម្ម បានសហការជាមួយសាខា ក.ប.ប ក្នុងការអនុវត្តសកម្មភាពចុះផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីសុវត្ថិភាពម្ហូបអាហារនៅតាមគ្រឹះស្ថានសិក្សា សកម្មភាពឃ្លាំពិនិត្យទីផ្សារ និងការចុះបង្ក្រាបទំនិញក្លែងបន្លំដើម្បីការពារ និងធានាបាននូវសុខុមាលភាពរបស់អ្នកប្រើប្រាស់។

### ៩.៤.ការអនុវត្តគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច

ក្រោមកិច្ចសហប្រតិបត្តិការជាមួយ មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ក្រសួងពាណិជ្ជកម្ម ក្នុងនាមជាអ្នកដឹកនាំប្រតិបត្តិគម្រោងជំរុញទីផ្សារកសិកម្មខ្នាតតូច (AIMS) ដែលមានមន្ទីរពាណិជ្ជកម្ម ជាអ្នកសម្របសម្រួលការអនុវត្តគម្រោងក្នុងខេត្តគោលដៅទាំង១៨។ ដើម្បីជំរុញការវិនិយោគលើទំនិញកសិ-ពាណិជ្ជកម្មឈានមុខចំនួន ៥មុខ រួមមាន៖ បន្លែ មាន់ស្រែ ស្រូវ ដំឡូងមី និងសូត្រធៅ។ ក្នុងឆ្នាំ២០២៤ គម្រោង AIMS បានផ្ដល់មូលនិធិអភិវឌ្ឍន៍តាមវិស័យ (SDF) ចំនួន ៩៣ទីតាំង រួមមាន៖ កន្លែងប្រមូលផ្ដុំបន្លែ កន្លែងលាងសម្អាត និងវេចខ្ចប់បន្លែ កន្លែងប្រមូលផ្ដុំមាន់ស្រែ ទីសត្តឃាតមាន់ កន្លែងប្រមូលផ្ដុំផលិតផលចម្រុះ អណ្ដូងបំពាក់សូឡា និងអណ្ដូងម៉ូទ័រ។ គម្រោងនេះក៏បានផ្ដល់មូលនិធិនវានុវត្តន៍ច្រវ៉ាក់តម្លៃ (VCIF) ដែលជាហិរញ្ញប្បទានឥតសំណងជូនដល់កសិករក្រីក្រដែលដាំបន្លែចំនួន ៧០៩គ្រួសារ។



## ១០.កិច្ចការគណៈកម្មាធិការជាតិពាក់ព័ន្ធវិស័យពាណិជ្ជកម្ម

### ១០.១.ការងារគណៈកម្មាធិការជាតិការពារអ្នកប្រើប្រាស់ «គ.ជ.ក.ប.»

- រៀបចំកិច្ចប្រជុំចំនួន ៦លើក ក្នុងនោះមានកិច្ចប្រជុំសាមញ្ញចំនួន ៣លើក និងកិច្ចប្រជុំវិសាមញ្ញចំនួន ៣លើក
- ធ្វើជាម្ចាស់ផ្ទះរៀបចំសន្និសីទស្តីពីកិច្ចការពារអ្នកប្រើប្រាស់អាស៊ានលើកទី៤ ស្តីពីការពង្រឹងសិទ្ធិអំណាចរបស់អ្នកប្រើប្រាស់នៅក្នុងសេដ្ឋកិច្ចឌីជីថល និងសេដ្ឋកិច្ចបៃតង ក្រោមប្រធានបទ «ការច្នៃប្រឌិត កិច្ចការពារនិងនិរន្តភាព»
- ចូលរួមក្នុងកិច្ចប្រជុំ និងសិក្ខាសាលា ដែលរៀបចំដោយគណៈកម្មាធិការការពារអ្នកប្រើប្រាស់អាស៊ាន និងគណៈកម្មាធិការការពារអ្នកប្រើប្រាស់នៃបណ្តាប្រទេសចំនួន ២៤លើក
- ផ្តល់យោបល់លើទិដ្ឋភាពច្បាប់ និងតម្រូវការលិខិតបទដ្ឋានគតិយុត្តៈ ប្រកាសស្តីពីការអនុវត្តមិនសុចរិតក្នុងធុរកិច្ចពាក់ព័ន្ធនឹងការផ្សាយពាណិជ្ជកម្ម និងការជំរុញការលក់ និងសេចក្តីព្រាងគោលការណ៍ស្តីពីការដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការ (ADR & ODR)។

### ១០.២.គណៈកម្មាធិការប្រកួតប្រជែងកម្ពុជា «គ.ប.ក»

- រៀបចំកិច្ចប្រជុំចំនួន ៤លើក ក្នុងនោះមានកិច្ចប្រជុំសាមញ្ញចំនួន ៣លើក និងកិច្ចប្រជុំវិសាមញ្ញចំនួន ១លើក
- ទស្សនកិច្ចសិក្សានៅស្ថាប័នប្រកួតប្រជែងនៃប្រទេសអាល្លឺម៉ង់ និងហូឡង់
- ចូលរួមកិច្ចប្រជុំនិងសិក្ខាសាលា ដែលរៀបចំដោយគណៈកម្មាធិការប្រកួតប្រជែងអាស៊ាន និងស្ថាប័នប្រកួតប្រជែងរបស់បណ្តាប្រទេសចំនួន ២៧លើក
- ផ្តល់យោបល់លើទិដ្ឋភាពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តៈសេចក្តីសម្រេចស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការស្នើសុំការអនុញ្ញាតលើកលែងក្រោមច្បាប់ស្តីពីការប្រកួតប្រជែង និងសេចក្តីសម្រេចស្តីពីលក្ខខណ្ឌ និងនីតិវិធី នៃគោលការណ៍អនុគ្រោះក្រោមច្បាប់ស្តីពីការប្រកួតប្រជែង។

### ១០.៣.គណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា «គ.ត.ផ.ហ.ក»

- រៀបចំកិច្ចប្រជុំ ២លើក ដើម្បីពិនិត្យវឌ្ឍនភាពការងាររបស់ គ.ត.ផ.ហ.ក និងពិនិត្យអនុម័តលើឯកសារគតិយុត្តចំនួន ២លើក

- ចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌជាតិ ចំនួន ២លើក៖ (១)-កិច្ចប្រជុំជាមួយសភាពាណិជ្ជកម្មម៉ាឡេស៊ីប្រចាំប្រទេសកម្ពុជា (២)-កិច្ចប្រជុំក្រុមការងារអន្តរក្រសួងសិក្សាជំរុញការអភិវឌ្ឍផលិតផលឧស្សាហកម្ម និងចំណីអាហារហាឡាលនៅកម្ពុជាដោយប្រើប្រាស់ក្របខ័ណ្ឌតំបន់សេដ្ឋកិច្ចពិសេស
- ចូលរួមកិច្ចប្រជុំក្នុងក្របខ័ណ្ឌអន្តរជាតិចំនួន ២លើក៖ (១)-កិច្ចប្រជុំក្រុមការងារអាស៊ានស្តីពីម្ហូបអាហារហាឡាល និង(២)-កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងឧស្សាហកម្ម និងបច្ចេកវិទ្យាទំនើប អេមីរ៉ាតអារ៉ាប់រួម
- ទស្សនកិច្ចសិក្សា និងវគ្គបណ្តុះបណ្តាលស្តីពីបទប្បញ្ញត្តិ នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មនៅប្រទេសតួកគី
- ផ្តល់យោបល់លើទិដ្ឋភាពច្បាប់ និងតម្រូវការលិខិតបទដ្ឋានគតិយុត្តលើការស្នើសុំតែងតាំងសមាសភាពលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា និងស្នើសុំតែងតាំងសមាសភាពក្រុមឯកទេសផលិតផលហាឡាល នៃគ.ត.ផ.ហ.ក។

## ១០.៤.គណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញា

- ចុះហត្ថលេខា លើផែនការសម្មភាពសម្រាប់ឆ្នាំ២០២៤-២០២៥ ជាមួយអង្គភាពប្រកាសនីយបត្រតក្កកម្មអឺរ៉ុប (EPO)
- កិច្ចសហប្រតិបត្តិការទ្វេភាគី ស្តីពីកម្មសិទ្ធិបញ្ញាជាមួយ អង្គភាពរដ្ឋបាលកម្មសិទ្ធិបញ្ញា នៃសាធារណរដ្ឋប្រជាមានិតចិន និងចុះបញ្ជីទទួលស្គាល់ប្រកាសនីយបត្រតក្កកម្មចិននៅកម្ពុជា ព្រមទាំងរៀបចំផែនការសកម្មភាពសម្រាប់កិច្ចសហប្រតិបត្តិការស្តីពីកម្មសិទ្ធិបញ្ញាឆ្នាំ២០២៤-២០២៥
- ជំរុញកិច្ចសហប្រតិបត្តិជាមួយក្រុមការងារអាស៊ាន ស្តីពីសហប្រតិបត្តិការកម្មសិទ្ធិបញ្ញា
- ផ្តល់យោបល់លើទិដ្ឋភាពច្បាប់ និងតម្រូវការលិខិតបទដ្ឋានគតិយុត្ត៖ សេចក្តីព្រាងច្បាប់ស្តីពីការសម្ងាត់ពាណិជ្ជកម្ម និងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិអ្នកបង្កាត់ពូជដំណាំ
- ជំរុញការអនុវត្តគោលនយោបាយកម្មសិទ្ធិបញ្ញា និងផ្សព្វផ្សាយចំណេះដឹងក្នុងវិស័យកម្មសិទ្ធិបញ្ញា។

១០.៥.គណៈកម្មការរៀបចំឯកសារត្រួតពិនិត្យការអនុវត្តគោលនយោបាយពាណិជ្ជកម្ម ក្រោមក្របខ័ណ្ឌអង្គការពាណិជ្ជកម្មពិភពលោក

- សម្របសម្រួលការត្រៀមទាំងលក្ខណៈបច្ចេកទេស និងបែបបទសម្រាប់រៀបចំកិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជា លើកទី៣ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៦ និង២៨ ខែមីនា ឆ្នាំ២០២៥ នៅទីក្រុងហ្សឺណែវ ជាលទ្ធផល បានបញ្ចប់សេចក្តីព្រាងឯកសាររបស់លេខាធិការដ្ឋាន WTO និងសេចក្តីព្រាងឯកសាររបស់រាជរដ្ឋាភិបាល និងបញ្ជូនតាមនីតិវិធី
- លេខាធិការដ្ឋាន WTO បានបញ្ចប់បេសកកម្មលើកទី២ ដើម្បីប្រមូលទិន្នន័យស្ថិតិ និងឯកសារផ្សេងៗ បញ្ចូលក្នុងសេចក្តីព្រាងរបាយការណ៍
- បញ្ចប់សេចក្តីព្រាងរបាយការណ៍រាជរដ្ឋាភិបាល និងដាក់ជូនកិច្ចប្រជុំអន្តរក្រសួងផ្តល់ការឯកភាពលើរបាយការណ៍ មុនបញ្ជូនទៅលេខាធិការដ្ឋាន WTO។

## ១១.សកម្មភាពក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន

ក្នុងឆ្នាំ២០២៤ នេះ គ្រប់ថ្នាក់ដឹកនាំក្រសួង រួមជាមួយមន្ត្រីដឹកនាំតាមអង្គភាពចំណុះក្រសួង ក្នុងនាមក្រុមការងាររាជរដ្ឋាភិបាល បានបន្តយកចិត្តទុកដាក់ខ្ពស់ចូលរួមបំពេញភារកិច្ច និងធ្វើសកម្មភាពនៅតាមមូលដ្ឋានរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីចូលរួមគាំទ្រ និងជំរុញការអនុវត្តកម្មវិធីនយោបាយ យុទ្ធសាស្ត្របញ្ចកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គោលនយោបាយនិងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលយ៉ាងសកម្ម និងផុលផុសនៅតាមមូលដ្ឋាន។ ក្នុងអាណត្តិនេះ ថ្នាក់ដឹកនាំក្រសួងត្រូវបានរាជរដ្ឋាភិបាលចាត់តាំងឱ្យចុះមូលដ្ឋាននៅគ្រប់រាជធានី ខេត្ត និងទទួលផ្ទាល់មូលដ្ឋានខេត្តកែប ស្រុក១នៃខេត្តកំពង់ចាម និងស្រុក២នៃខេត្តកំពត។

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន បានធ្វើសកម្មភាពដោយសហការដឹកនាំ និងទទួលខុសត្រូវគ្រប់គ្រងក្រុមការងារ ក្នុងសកម្មភាពត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយនានា និងយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលខ្លួនទទួលបន្ទុក រួមមានចំណុចសំខាន់ៗៈ

- ផ្សារភ្ជាប់ទំនាក់ទំនង រវាងរាជរដ្ឋាភិបាលជាមួយប្រជាពលរដ្ឋ តាមរយៈការផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រផែនការយុទ្ធសាស្ត្រ គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព កម្មវិធីកំណែទម្រង់តាមវិស័យ ក៏ដូចជាសភាពការណ៍នានារបស់ប្រទេសជាតិ និងសភាពការណ៍

រីកចម្រើនថ្មីៗនៅមូលដ្ឋាន

- សមាជិកក្រុមការងារគ្រប់ថ្នាក់ បន្តរួមចំណែកថែរក្សាការពារសុខសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍនានា និងលើកកម្ពស់ស្ថានភាពសង្គម សេដ្ឋកិច្ច និងអភិវឌ្ឍន៍នៅមូលដ្ឋាន ជាមួយនឹងការចូលរួមបរិច្ចាគធនធាន ថវិកា សម្ភារៈ ជួយគាំទ្រដល់មូលដ្ឋានផងដែរ
- សហការជំរុញ និងលើកកម្ពស់គណនេយ្យភាពរបស់ក្រសួង ស្ថាប័ន និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការផ្តល់សេវាសាធារណៈ ពិសេសសេវាតម្រូវការដូចជា៖ ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ សំបុត្រមរណភាព លិខិតរដ្ឋបាលផ្សេងៗ។ល។ តាមរយៈការពង្រឹងយន្តការច្រកចេញចូលតែមួយនៅថ្នាក់ឃុំ សង្កាត់
- សហការរៀបចំវេទិកាសាធារណៈនៅមូលដ្ឋាន និងការចុះជួបប្រាស្រ័យដោយផ្ទាល់ជាមួយប្រជាពលរដ្ឋតាមខ្នងផ្ទះ តាមគ្រួសារ ដើម្បីស្តាប់ក្តីកង្វល់សំណូមពរ និងសំណើរបស់ប្រជាពលរដ្ឋ ព្រមទាំងយកចិត្តទុកដាក់ជំរុញការដោះស្រាយនូវរាល់ក្តីកង្វល់ សំណូមពរ និងសំណើទាំងក្នុងកម្រិតថ្នាក់ក្រោមជាតិ និងទាំងកម្រិតថ្នាក់ជាតិ។ ចំណុចមួយចំនួនក្រុមការងារបានដោះស្រាយនៅនឹងកន្លែង និងបានឆ្លើយតបជូនប្រជាពលរដ្ឋនៅក្នុងវេទិកាសាធារណៈតែម្តង
- សហការដោះស្រាយបញ្ហាប្រឈម និងការលំបាកនានារបស់ប្រជាពលរដ្ឋ គ្រួសារក្រីក្រ ជនងាយរងគ្រោះ ជនចាស់ជរា ជនពិការ និងគ្រួសារងាយរងហានិភ័យពីគ្រោះមហន្តរាយ និងកម្មវិធីជំនួយសង្គមមួយចំនួនទៀតជាប្រយោជន៍ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះទូទាំងប្រទេស ក៏ដូចជា គោលនយោបាយគាំពារ និងទ្រទ្រង់ជីវភាពបងប្អូនកម្មករ សិស្ស និស្សិត និងស្រទាប់យុវជននៅមូលដ្ឋាន
- នៅឆ្នាំ២០២៤នេះ ក្រសួងបានកែសម្រួល និងចាត់តាំងសមាសភាពក្រុមការងារ និងបានចាត់បញ្ជូនថ្នាក់ដឹកនាំ ចាប់ពីថ្នាក់អគ្គនាយករងឡើងទៅចំនួន ១១៧នាក់ និងមន្ត្រីមួយចំនួនផ្សេងទៀតឱ្យបន្តចូលរួមក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ជាមួយអាទិភាពគន្លឹះចំនួន ៥ រួមមាន៖ មនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា។

## IV. **បញ្ហាប្រឈម**

ទន្ទឹមនឹងការសម្រេចបាននូវសមិទ្ធផលការងារយ៉ាងច្រើនក្នុងឆ្នាំ២០២៤ កន្លងមក ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា លើការដឹកនាំ គ្រប់គ្រងវិស័យពាណិជ្ជកម្ម ក្នុងការអនុវត្តគោលនយោបាយរាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដែលបាន ដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលជាកំណែទម្រង់ស៊ីជម្រៅឆ្ពោះ ទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់ ជាមួយ គ្នានេះក្រសួងក៏បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

- ចំនួនមន្ត្រីរាជការបម្រើការងារ តាមអង្គភាពមួយចំនួនមិនទាន់ឆ្លើយតបទៅនឹង ទំហំការងារ និងតាមមុខជំនាញបច្ចេកទេសនៅឡើយ ជាពិសេសសមត្ថភាព អនុវត្តការងារនៅមានកម្រិតទាំងសមត្ថភាពចំណេះដឹង ជំនាញ និងការគ្រប់គ្រង
- ពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅពុំទាន់មានប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព ដែលចាំបាច់តម្រូវឱ្យមានការយកចិត្តទុកដាក់លើការពង្រឹង ចំណេះដឹងមន្ត្រីរាជការក្នុងការប្រើប្រាស់ និងបញ្ចូលព័ត៌មានទ្រព្យសម្បត្តិរដ្ឋក្នុង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (State Asset Register Management Information System-SARMIS)។ បន្ថែមលើនេះ ត្រូវជំរុញការស្នើសុំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (បណ្ណកម្មសិទ្ធិ) និង ដោះស្រាយបញ្ចប់បញ្ហាវិវាទដីធ្លីឱ្យបានរួចរាល់ជាស្ថាពរ
- អគារ បន្ទប់ធ្វើការ ឃ្លាំងផ្ទុកឯកសារ និងហេដ្ឋារចនាសម្ព័ន្ធនៅពុំទាន់ឆ្លើយតប ទៅនឹងតម្រូវការជាក់ស្តែងរបស់ក្រសួងនៅឡើយ
- ការផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹង វិស័យពាណិជ្ជកម្ម នៅពុំទាន់មានភាពទូលំទូលាយ ដែលតម្រូវឱ្យមានការបញ្ជ្រាប ការយល់ដឹងបន្ថែមទៀតដល់មន្ត្រីអនុវត្តច្បាប់ ធុរជន និងសាធារណជន។

## V. ទិសដៅការងារអនុវត្តឆ្នាំ២០២៥

### ១.កិច្ចការពាណិជ្ជកម្មអន្តរជាតិ

- បន្តកសាងសហគមន៍សេដ្ឋកិច្ចអាស៊ាន តាមរយៈការអនុវត្តផែនការលម្អិតរបស់សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៥ និងផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយឆ្នាំ២០២៥
- បន្តចូលរួមចំណែកក្នុងកិច្ចពិភាក្សាក្រោមយន្តការពិគ្រោះយោបល់ ជាមួយដៃគូសន្ទនារបស់អាស៊ាន ដើម្បីពង្រឹងមជ្ឈភាពអាស៊ាន និងលើកកម្ពស់ចក្ខុវិស័យអាស៊ានសកល ( Global ASEAN )
- បន្តចូលរួមចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មថ្មី និងដំឡើងកម្រិតកិច្ចព្រមព្រៀងជាមួយដៃគូអាស៊ាន រួមមាន៖ ចិន កាណាដា ឥណ្ឌា និងសាធារណរដ្ឋកូរ៉េ
- បន្តចូលរួមចំណែកក្នុងកិច្ចសហប្រតិបត្តិការអនុតំបន់ទាំងអស់រួមមាន៖ GMS, ACMECS, AMEICC, Mekong-Lancang,និង Mekong-Japan ។ល។
- បន្តលើកកម្ពស់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មទ្វេភាគី ជាមួយប្រទេសក្នុងទ្វីបអាម៉េរិក អឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- បន្តកៀរគរជំនួយហិរញ្ញប្បទាន និងជំនួយបច្ចេកទេស តាមរយៈយន្តការកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍
- ជំរុញការរៀបចំក្របខ័ណ្ឌគោលនយោបាយពាណិជ្ជកម្មកម្ពុជាឆ្ពោះទៅឆ្នាំ២០៣០
- បន្តតាមដាន សម្របសម្រួល និងអនុវត្តកាតព្វកិច្ចកម្ពុជាក្រោមក្របខ័ណ្ឌ WTO
- រៀបចំ សម្របសម្រួលកិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី៣ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅឆ្នាំ២០២៥
- សហការជាមួយក្រុមប្រទេស LDCs លើការងារចរចាពីសំណើស្តីពីការចាកចេញពីឋានៈប្រទេស LDCs វិស័យកសិកម្ម ឧបត្ថម្ភធនជលផល ដំណោះស្រាយវិវាទ WTO និងលើបញ្ហាអាទិភាពផ្សេងទៀត។

### ២.កិច្ចការពាណិជ្ជកម្មក្នុងប្រទេស

- បន្តរៀបចំបទប្បញ្ញត្តិ ច្បាប់ពាក់ព័ន្ធនឹងវិស័យពាណិជ្ជកម្ម និងបន្តតាមដានវាយតម្លៃផលប៉ះពាល់នៃការអនុវត្តលិខិតបទដ្ឋានគតិយុត្ត
- បន្តធ្វើទំនើបកម្មប្រព័ន្ធតម្កល់លិខិតជូនដំណឹងនៃប្រតិបត្តិការដែលមានកិច្ចធានា

- បន្តពិនិត្យតាមដានស្ថានភាពថ្លៃទំនិញចាំបាច់បម្រើជីវភាព ទំនិញយុទ្ធសាស្ត្រ និងបរិមាណសន្និធិប្រេងឥន្ធនៈ
- បន្តផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ
- បន្តបង្កើតសភាពាណិជ្ជកម្មរាជធានី ខេត្ត សម្រាប់អាណត្តិថ្មី និងអាណត្តិបន្ត និង សម្រាប់ខេត្តដែលត្រូវផ្តាច់ចេញពីមណ្ឌលសភាពាណិជ្ជកម្ម
- បន្តតាមដានវឌ្ឍនភាពការអនុវត្តអនុស្សរណៈ នៃការយោគយល់គ្នាជាមួយ ក្រុមហ៊ុនប្រមូលទិញកសិផល
- ជំរុញការអនុវត្តគម្រោង AMIS ដំណាក់កាលទី២ តាមគោលដៅដែលបានកំណត់
- បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកទេសព័ត៌មានវិទ្យា និងរៀបចំផែនការមេបច្ចេកវិទ្យា ឌីជីថល
- បន្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយ របស់ក្រសួង
- បន្តស្រាវជ្រាវ ប្រមូល និងចងក្រង បោះពុម្ពផ្សាយព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្ម
- បន្តពង្រឹង និងជំរុញការផ្សព្វផ្សាយ ការអប់រំ និងការណែនាំអំពីការប្រើប្រាស់ ស្លាកសញ្ញាហាឡាល
- បន្តតាមដានវិបានសុវត្ថិភាពផលិតផលម្ហូបអាហារ ដែលកើតឡើងក្នុង និង ក្រៅប្រទេស
- បន្តលើកកម្ពស់ការយល់ដឹងរបស់ធុរជន និងសាធារណជនលើការអនុវត្តច្បាប់ស្តីពី ការប្រកួតប្រជែង ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធ
- បន្តប្រមូល វិភាគ និងធ្វើបច្ចុប្បន្នភាពព័ត៌មានអំពីហានិភ័យលើទំនិញដែល ចរាចរលើទីផ្សារ។

## ៣.កិច្ចការសេវាពាណិជ្ជកម្ម

- បន្តធ្វើការថែទាំនិងធ្វើទំនើបកម្មលើប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ ដើមកំណើតទំនិញ ប្រព័ន្ធស្វ័យប្រវត្តកម្មចុះបញ្ជីពាណិជ្ជកម្ម និងប្រព័ន្ធ ស្វ័យប្រវត្តកម្មចុះបញ្ជីម៉ាក ព្រមទាំងភ្ជាប់ប្រព័ន្ធទាំងនេះជាមួយនឹងធនាគារដៃគូ សម្រាប់ទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក (E-payment)
- ផ្ទេរទិន្នន័យ និងប្រព័ន្ធចុះបញ្ជីពាណិជ្ជកម្មពី Cloud Service Provider នៅបរទេសមកដំណើរការ និងរក្សាទុកនៅក្នុងមជ្ឈមណ្ឌលទិន្នន័យរបស់ក្រសួង

- ដាក់ដំណើរការមុខងារបន្តសុពលភាព ការកែប្រែ និងការបញ្ឈប់ប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិករបស់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណលើប្រព័ន្ធស្វ័យប្រវត្តកម្ម
- បន្តរៀបចំវគ្គបណ្តុះបណ្តាល ដល់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម កម្មសិទ្ធិបញ្ញា និងឯកសារនាំចេញ-នាំចូល ព្រមទាំងពង្រឹងការគ្រប់គ្រងអ្នកតំណាងស្របច្បាប់ឱ្យមានប្រសិទ្ធភាព
- តភ្ជាប់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់AK ជាមួយប្រព័ន្ធបញ្ចូរតែមួយជាតិ ក្នុងការបញ្ជូន CO ជាទម្រង់អេឡិកត្រូនិច (e-Form AK) ទៅប្រព័ន្ធស្វ័យប្រវត្តកម្មរបស់សាធារណរដ្ឋកូរ៉េ
- ធ្វើបច្ចុប្បន្នភាពផ្ទាលព័ត៌មានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (FTA Portal)
- បន្តផ្សព្វផ្សាយបែបបទ នីតិវិធី និងលិខិតបទដ្ឋានគតិយុត្តតាមរយៈការធ្វើសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលនានា
- រៀបចំការចុះបញ្ជីម៉ាកសមូហភាព៖ ក្រូចពោធិ៍សាត់ និងសំបុកត្រចៀកកាំ
- ជំរុញការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ៖ អង្ករកម្ពុជា ស្វាយចន្ទីកំពង់ធំ និងទុរេនកំពត
- ធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការកម្មសិទ្ធិបញ្ញាអាស៊ាន (AWGIPC) លើកទី៧៥
- រៀបចំមជ្ឈមណ្ឌលលើកកម្ពស់ចំណេះដឹងកម្មសិទ្ធិបញ្ញា របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅកម្ពុជា
- បន្តត្រួតពិនិត្យ តាមដាន និងទប់ស្កាត់ការក្លែងបន្លំ និងជំរុញការលើកកម្ពស់ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ និងម៉ាកសមូហភាពរបស់កម្ពុជា។

**៤.កិច្ចការជំរុញពាណិជ្ជកម្ម**

- បន្តរៀបចំពិព័រណ៍ផលិតផលខ្មែរ និងតាំងបង្ហាញផលិតផលសក្តានុពលកម្ពុជាក្នុងឱកាសពិធីផ្សេងៗ
- បន្តចូលរួម និងរៀបចំពិព័រណ៍ពិភពលោក២០២៥ និងពិព័រណ៍អន្តរជាតិនានា
- បន្តសិក្សាលទ្ធភាពបង្កើតផ្សារលក់ដុំទំនិញនៅតាមរាជធានី ខេត្ត និងជំរុញការអនុវត្តកិច្ចសហប្រតិបត្តិការរួមគ្នាក្នុងការសាងសង់ស្ទួនឧស្សាហកម្មកម្ពុជា-ចិន

- បន្តគ្រប់គ្រងការបង្កើត និងពង្រឹងដំណើរការមជ្ឈមណ្ឌលពាណិជ្ជកម្មឯកជនកម្ពុជា នៅក្រៅប្រទេស
- បន្តរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ផលិតផលខ្មែរ
- តាមដាន និងជំរុញការចូលរួមអនុវត្តគោលនយោបាយជាតិ ស្តីពីជំឡូងមី ២០២០-២០២៥ និងគោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥
- បន្តជំរុញការរៀបចំយុទ្ធសាស្ត្រពង្រីក និងពិពិធកម្មទីផ្សារនាំចេញអង្ករកម្ពុជា ឆ្នាំ២០២៥-២០៣០
- បន្តរៀបចំយុទ្ធសាស្ត្រម្រេចកម្ពុជា និងគោលនយោបាយពាក់ព័ន្ធ
- បន្តប្រមូល ចងក្រង និងបច្ចុប្បន្នទិន្នន័យពាក់ព័ន្ធនឹងស្វាយចន្ទី ដំឡូងមី និងម្រេច
- បន្តចូលរួម និងគាំទ្រការរៀបចំទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ
- បន្តចូលរួមក្នុងការវាយតម្លៃជ្រើសរើសផលិតផលនិងសេវាដើម្បីស្នើសុំចូលជា ផលិតផលភូមិមួយផលិតផលក្នុងសកម្មភាពការងារឆ្នាំ២០២៤។

## ៥.កិច្ចការរដ្ឋបាលទូទៅ

- ធ្វើទំនើបកម្មប្រព័ន្ធរដ្ឋបាលឱ្យមានរបៀបរៀបរយ ប្រសិទ្ធភាព និងគណនេយ្យភាព តាមរយៈការកសាងប្រព័ន្ធបញ្ជូន និងរក្សាឯកសារទុកតាមប្រព័ន្ធឌីជីថល (e-Doc)
- បង្កើតបណ្ណសារដ្ឋានក្រសួង ឱ្យស្របតាមបទដ្ឋានបច្ចេកទេសបណ្ណសារដ្ឋានជាតិ
- បូកសរុបរបាយការណ៍ក្រសួងប្រចាំខែ ត្រីមាស ឆមាស នព្វមាស និងឆ្នាំ
- រៀបចំសំណើសុំដំឡើងថ្នាក់ និងឋានន្តរស័ក្តិតាមវេនអតីតភាពនិងថ្នាក់កិត្តិយស និងតាមកម្រិតសញ្ញាបត្រ ជូនមន្ត្រីរាជការ
- បន្តធ្វើផែនការក្របខ័ណ្ឌ ការវិភាគមុខងារ និងការពិព័រណ៌នាមុខតំណែង
- រៀបចំគម្រោងថវិកាចំណាយបន្ទុកបុគ្គលិក និងតារាងវិភាជន៍ចំណាយប្រាក់ បៀវត្សប្រចាំឆ្នាំតាមកម្មវិធីនីមួយៗ
- ពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងចំណូល និងចំណាយថវិការបស់រដ្ឋ
- បន្តរៀបចំការចុះបញ្ជីដីធ្លី និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនទ្រព្យលើទ្រព្យ សម្បត្តិរដ្ឋ
- បន្តរៀបចំគម្រោងកម្មវិធីសិក្សា និងវគ្គបណ្តុះបណ្តាលឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព

- បន្តស្រាវជ្រាវ និងចងក្រងព្រឹត្តិបត្រព័ត៌មានពាណិជ្ជកម្មអេឡិចត្រូនិក ( iTrade Bulletin )
- រៀបចំបង្កើតបណ្ណាល័យអេឡិចត្រូនិករបស់ក្រសួងពាណិជ្ជកម្ម។

## ៦.កិច្ចការអគ្គាធិការដ្ឋាន និងសវនកម្មផ្ទៃក្នុង

### ៦.១.អគ្គាធិការដ្ឋាន

- បន្តចុះធ្វើអធិការកិច្ច និងអធិការកិច្ចដោយមិនជូនដំណឹងជាមុន នៅតាមអង្គភាពក្រោមឱវាទក្រសួងតាមការណែនាំ និងចាត់តាំង
- ទទួល និងដោះស្រាយពាក្យបណ្ដឹងតវ៉ា បណ្ដឹងបរិហារ និងវិវាទតាមករណីជាក់ស្ដែង និងតាមការណែនាំ
- បន្តពង្រឹងសមត្ថភាពមន្ត្រីចុះធ្វើអធិការកិច្ចឱ្យមានការយល់ដឹងពីជំនាញវិជ្ជាជីវៈពាក់ព័ន្ធ។

### ៦.២.សវនកម្មផ្ទៃក្នុង

- បន្តចុះធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុង គណនេយ្យនិងហិរញ្ញវត្ថុ ផ្នែករដ្ឋបាល ការគ្រប់គ្រងការពារទ្រព្យសម្បត្តិរដ្ឋ វាយតម្លៃភាពសន្សំសំចៃ និងស័ក្តិសិទ្ធភាពនៃការប្រើធនធាន ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងអនុលោមភាពតាមច្បាប់ បទប្បញ្ញត្តិនានារាល់ប្រតិបត្តិការឆ្នាំ២០២៣ និងឆ្នាំពាក់ព័ន្ធ
- បន្តពិនិត្យតាមដានការកែលម្អតាមអនុសាសន៍សវនកម្មគ្រាមុន និងវាយតម្លៃលើវឌ្ឍនភាពនៃការកែលម្អ។

## ៧.កិច្ចការយេនឌ័រ

- បន្តរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រឆ្នាំ២០២៤-២០២៨ របស់ក្រសួង
- បន្តជំរុញសហគ្រិន ពាណិជ្ជករ និងសេវាករជាស្ត្រីឱ្យចូលរួមព្រឹត្តិការណ៍នានាក្នុងវិស័យពាណិជ្ជកម្ម
- បន្តជំរុញការបង្កើនសមត្ថភាពដល់មន្ត្រីរាជការជាស្ត្រី ឱ្យកាន់តែប្រសើរឡើងតាមរយៈការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា វេទិកាសាធារណៈ និងកម្មវិធីផ្សេងៗទាំងក្នុង និងក្រៅប្រទេស។

## ៨.កិច្ចការងារកែទម្រង់

### ៨.១.ការងារវិមជ្ឈការ និងវិសហមជ្ឈការ

- រៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២៥ ស្ដីពីការងារកំណែទម្រង់វិមជ្ឈការ

និងវិសហមជ្ឈការរបស់ក្រសួង ឱ្យស្របតាមផែនការអនុវត្ត៥ឆ្នាំ ដំណាក់កាលទី១

- បន្តរៀបចំបញ្ចប់សេចក្តីសម្រេចរួមឆ្នាំ២០២៤ និងសេចក្តីសម្រេចរួមឆ្នាំ២០២៥ រវាង គ.ជ.អ.ប. ជាមួយក្រសួងពាណិជ្ជកម្ម ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកា
- បន្តតាមដាន វិភាគ និងវាយតម្លៃការអនុវត្តមុខងារដែលបានផ្ទេរទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តាមសេចក្តីសម្រេចរួមឆ្នាំ២០២៤ រវាង គ.ជ.អ.ប. ជាមួយក្រសួងពាណិជ្ជកម្មនិងសេចក្តីសម្រេចលេខ១០០សសរចុះថ្ងៃទី១៣ខែកញ្ញាឆ្នាំ២០២៣ របស់រាជរដ្ឋាភិបាលស្តីពីការផ្អាកការផ្តល់សេវារដ្ឋបាលមួយចំនួនរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

**៨.២.ការងារកែទម្រង់រដ្ឋបាលសាធារណៈ**

- ចូលរួមកិច្ចប្រជុំការពារសេចក្តីព្រាងអនុក្រឹត្យស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម ជាមួយក្រសួងមុខងារសាធារណៈ និងកិច្ចប្រជុំនានាដែលរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីទទួលបានការពិនិត្យ និងផ្តល់យោបល់ពីគ្រប់ក្រសួង ស្ថាប័ន
- បន្តចូលរួមអនុវត្ត វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។

**៨.៣.ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល ស្របតាមផែនការយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាលកម្ពុជា
- បន្តពង្រឹងប្រសិទ្ធភាពនៃការរៀបចំនិងការអនុវត្តកម្មវិធីចំណូលចំណាយប្រចាំត្រីមាស ឆមាស និងឆ្នាំ
- ជំរុញបញ្ចប់គោលការណ៍ណែនាំរួម ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងដើម្បីដាក់ឱ្យប្រើប្រាស់ជាផ្លូវការ
- បន្តពង្រឹងការរៀបចំផែនការថវិកា និងការអនុវត្តថវិកាឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តពង្រឹងការបើកផ្តល់ប្រាក់បេសកកម្មតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា
- បន្តជំរុញការអនុវត្តយុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥
- បន្តចូលរួមប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បន្តជំរុញធ្វើប្លង់កម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋទាំងថ្នាក់កណ្តាល និងមន្ទីរពាណិជ្ជកម្ម
- ជំរុញការប្រើប្រាស់ប្រព័ន្ធ SARMIS និងរៀបចំបញ្ជីសារពើភណ្ឌឆ្នាំគោល
- បន្តពិនិត្យលក្ខណសម្បត្តិអង្គភាពថវិកា ដើម្បីផ្តល់នីតិសម្បទាជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ
- បន្តជំរុញការចុះកិច្ចព្រមព្រៀងសមិទ្ធកម្មឆ្នាំ២០២៥ ឱ្យបានទាន់ពេលវេលា
- បន្តជំរុញអង្គភាពសវនកម្មផ្ទៃក្នុង លើការធ្វើសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យា និងការធ្វើសវនកម្មសមិទ្ធកម្ម
- បន្តពង្រឹងការផ្សព្វផ្សាយព័ត៌មាន ស្តីពីថវិកាជូនសាធារណជនគ្រប់មធ្យោបាយ
- បន្តរៀបចំសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធ SARMIS v2 ការរៀបចំសូចនាករសមិទ្ធកម្ម និងផ្សព្វផ្សាយស្តីពីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**៨.៤.ការងារតាមដាន ត្រួតពិនិត្យ វាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**

- កំណត់ឆ្នាំមូលដ្ឋាន បន្ទាត់មូលដ្ឋាន និងចំណុចដៅ ចំពោះសូចនាករ ដែលក្រសួងទទួលបន្ទុកដឹកនាំ
- ដាក់ចេញផែនការសកម្មភាពសម្រាប់ដឹកនាំអនុវត្ត និងចូលរួមអនុវត្តសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) របស់ក្រសួង
- រៀបចំរបាយការណ៍វឌ្ឍនភាពសង្ខេបប្រចាំឆមាស ប្រចាំឆ្នាំ ពាក់កណ្តាលអាណត្តិ និងចុងអាណត្តិជូន គ.យ.ប ឱ្យបានទៀងទាត់ និងទាន់ពេលវេលា។

## VI. សេចក្តីសន្និដ្ឋាន

ស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្រសួងពាណិជ្ជកម្មបានចូលរួមអនុវត្តយ៉ាងសកម្ម ក្នុងការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងជំរុញឱ្យអស់សក្តានុពលនូវប្រភពបច្ចុប្បន្ន និងប្រភពថ្មីនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងគោលដៅបង្កើតនិងបង្កើនការងារដែលមានតម្លៃបន្ថែមខ្ពស់ និងចាប់យកឱ្យបាននូវកាលានុវត្តភាពថ្មីដែលកំពុងលេចឡើង ស្របនឹងនិន្នាការតំបន់និងសកលតាមរយៈ៖ (១)-ការអភិវឌ្ឍគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តវិស័យពាណិជ្ជកម្ម (២)-ការជំរុញកិច្ចសហប្រតិបត្តិការ និងសមាហរណកម្មសេដ្ឋកិច្ច ពាណិជ្ជកម្ម តំបន់ និងសកល (៣)-ការរក្សាស្ថិរភាពទីផ្សារ ពង្រឹងខ្សែច្រវាក់ផ្គត់ផ្គង់ និងចូលរួមគ្រប់គ្រងសន្និធិទំនិញជាយុទ្ធសាស្ត្រនិងសន្តិសុខស្បៀង (៤)-ការអភិវឌ្ឍវិស័យឯកជន ជំរុញកិច្ចសម្រួលពាណិជ្ជកម្ម និងពង្រឹងការផ្តល់សេវា (៥)-ការអភិវឌ្ឍនិងគ្រប់គ្រងវិស័យកម្មសិទ្ធិបញ្ញា និងជំរុញការធ្វើពាណិជ្ជូបនីយកម្មទ្រព្យកម្មសិទ្ធិបញ្ញា (៦)-ការជំរុញពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងបរិវត្តកម្មពាណិជ្ជកម្មឌីជីថល (៧)-ការលើកកម្ពស់កិច្ចការពារអ្នកប្រើប្រាស់ ការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (៨)-ការធ្វើទំនើបកម្មស្ថាប័ន គ្រប់គ្រងប្រតិបត្តិការទូទៅ និងពង្រឹងយន្តការប្រមូលចំណូល និង (៩)-ការលើកកម្ពស់សមត្ថភាពធនធានមនុស្ស និងអភិវឌ្ឍការស្រាវជ្រាវវិស័យពាណិជ្ជកម្ម។ កិច្ចការទាំងនេះបានឆ្លុះបញ្ចាំងតាមរយៈលទ្ធផលសម្រេចបានជាវិជ្ជមាននៃការអនុវត្តការងារពាណិជ្ជកម្មឆ្នាំ២០២៤ ដោយមានការចូលរួមយ៉ាងសកម្មពីមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ និងបានដាក់ចេញទិសដៅការងារពាណិជ្ជកម្មឆ្នាំ២០២៥ សំដៅរួមចំណែកក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភាបានប្រកបដោយជោគជ័យ។

ថ្ងៃ ចន្ទ ៩ កើត ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ២០២៤

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce

ស្កេនដើម្បីទទួលបាន
ព័ត៌មានពាណិជ្ជកម្ម

ប្រព័ន្ធទូរស័ព្ទសាធារណៈ
ក្រសួងពាណិជ្ជកម្ម
1266

ស្កេនដើម្បីទាញយក
ឯកសារ